# ស៊ីអាស់, ខ្សែបន្ទាត់ តមកពីព្រះសាស្ដា ពីដើមកំណើត

(ការសិក្សាស្រាវជ្រាវអំពីវីឡាយ៉ាស៉ុ)

**មូហ៊ាំម៉ាដ់ បាគៀរ អាល់-ស្វដ៉ុរ៍**

បកប្រែ, អារម្ភកថា, កំណត់និងអក្ខរានុក្រមដោយ៖
**អ៊ុប់បាស់ អាស៊ុម៉ាដ់ អាល់-បុសតានី**

# អារម្ភកថារបស់អ្នកបោះពុម្ព

លោកអ្នកនិពន្ធសៀវភៅ "សេដ្ឋកិច្ចយើង" (សេដ្ឋកិច្ចអ៊ីស្លាម), "ទស្សនៈយើង", "ធនាគារអ៊ីស្លាមឥតចងការ" ជាមុច្ចតាហ៊ីដ្ធអ៊ីស្លាមនិយមដែលល្បីល្បាញពេញពិភពលោកមុស្លីម ដែលព្យាយាមស្តារអ៊ីស្លាមឲ្យរុងរឿងឡើងវិញនៅក្នុងស្ថានការណ៍ប្រវត្តិសាស្ត្រមួយ ដែលទស្សនៈសម្ភារៈនិយមលេចឡើងជាច្រើននៅក្នុងប្រទេសអ៊ីស្លាមប្រេះឆា និងទទួលរងវិមគ្គកម្ម (គឺការវៀចវេចេញពីមាគ៌ាល្អ) អស់រយៈពេលច្រើនសតវត្សមកហើយនោះ ។

គេតែងតែឃើញមូហាំម៉ាដ់ បាគៀរ អាល់-ស្វាដ់រ៍ (محمد باقر الصدر) យកចិត្តទុកដាក់ជាចម្បង នៅក្នុងវណ្ណៈកម្មទូទៅរបស់លោក អំពីការលើកយកការយកលំនាំតាមគេមកធ្វើការប្រៀបធៀប ហើយយកច្បាប់អ៊ីស្លាមស្ហារីអ៊ុាស់[1] (الشَّرِيعَة) ដែលមិនប្រែប្រួលនិងប្រកបដោយអង្គផ្សំនានាដែលចល័តនិងបត់បែនបានដែលធ្វើឲ្យច្បាប់ស្ហារីអ៊ុាស់នេះរស់រវើក និងស្របទៅតាមតម្រូវការក្នុងសម័យកាលនិងកាលៈទេសៈទាំងអស់នោះ មកដាក់ប្រឈមទល់មុខនឹងការយកលំនាំតាមគេនេះ ។

តែនិយាយអំពីការព្រួយបារម្ភអំពីការអភិរក្សអ៊ីស្លាម ត្រូវនិយាយអំពីការព្រួយបារម្ភអំពីអង្គភាពអ៊ីស្លាមដែរ ។ ការព្រួយបារម្ភអំពីអង្គភាពអ៊ីស្លាមនេះមិនដែលដាច់ពីមាត់ម្ចាស់សារអំពាវនាវដ៏ល្បីល្បាញ គួរឲ្យរំភើបចិត្តថា៖ "បងប្អូនស៊ូនីត បងប្អូនស្ហ៊ីអ៊ីតអឺយ" ដែលលោកបានប្រកាសនៅឯ

[1] ស្ហារីអ៊ុាស់ គឺច្បាប់អ៊ីស្លាម នីតិអ៊ីស្លាម ។

ប្រទេសអ៊ីរ៉ាក់ ក្នុងពេលជោគវាសនាអ៊ីស្លាមរងគ្រោះថ្នាក់នាប្រទេសនេះ ។

ទោះជាដូច្នេះក្តី តើត្រូវចាត់ទុកសៀវភៅនេះ[2] "ស៊្វីអ៊្រុស្ស៊ុំ ខ្សែបន្ទាត់តមកពីព្រះសាស្តាពីកំណើត" ជាអញ្ញត្រកម្មក្នុងកង្វល់របស់លោកអ្នកនិពន្ធនិងក្នុងដំណើរទៅមុខនៃវណ្ណៈកម្មរបស់លោកទេ ? ដោយចងក្រងសៀវភៅនេះឡើង លោក *មុច្ចតាហ្វ៊ីដ្ឋ* អាល់-ស្វដ្ឋ៌រ មិនខ្លាចគេចាត់ទុកលោកជាអ្នកប្រកាន់បក្សពួក ហើយលំអៀងចេញពីខ្សែបន្ទាត់ដែលលោកតែងតែអនុវត្តិតាមជានិច្ចទេ គឺខ្សែបន្ទាត់អ៊ីស្លាមសាកលដែលធំជាងនិន្នាការនិងចរន្តគំនិតទាំងឡាយនោះ ?
សំណួរឥតប្រយោជន៍ !

សៀវភៅនេះមិនលើកយកអង្គភាពនិងនិរន្តរភាពនៃវណ្ណៈកម្ម និងកង្វល់របស់លោកអ្នកនិពន្ធមកជាចំណោទបញ្ហាទេ តែសៀវភៅនេះអះអាងបន្ថែមពីលើខទាំងនេះ ។

មែន ត្រង់នេះនិងត្រង់កន្លែងផ្សេងទៀតដែរ សេចក្តីបារម្ភចម្បងរបស់លោកអ្នកនិពន្ធគឺអភិរក្សព្រះរាជសារអ៊ីស្លាម ការអភិរក្សនេះ ដូចយើង

[2] សៀវភៅនេះ កាលពីដើមជាអារម្ភកថាដែលលោកអ្នកនិពន្ធបានសរសេរសម្រាប់សៀវភៅលោកបណ្ឌិត អ៊្រុប់ឌុលឡោះហ្វ៍ អាល់-ហ្វៃយ៉ាដ្ឋ៌ ដែលមានចំណងជើងថា "តារិក្ហ អាល់-អ៊ីម៉ាមីយ៉ាស្ស៊ុំ វ៉ា អាស់ឡាហ្វឺហ្វ៊ីម អាល់-ស៊្វីអ៊្រុស្ស៊ុំ" (ប្រវត្តិរបស់អ្នកនិយមអ៊ីមុាំនិងស៊្វីអ៊្រីតមុនពួកគេ) ។ ក្រោយមកអារម្ភកថានេះត្រូវបានបោះពុម្ពជាសៀវភៅមួយដោយឡែក ។

# បញ្ជីមាតិកា


អារម្ភកថារបស់អ្នកបោះពុម្ព ........ ៣

កថាមុខ ........ ១៣

វគ្គ ១ - តើស៊្វីអ៊្រុស្ស៊ុំកើតឡើងដូចម្តេច ? ........ ១៦

វគ្គ ២ - តើអ្នកស៊្វីអ៊្រុស្ស៊ុំនិយមកើតឡើងដូចម្តេច ? ........ ៦៥

អក្ខរានុក្រម ........ ៨៨

គាំទ្រព្រះសាស្តា ។



បានអធិប្បាយហើយ មានឯកភាពជាមូលដ្ឋាន ។ តែឯកភាពអ៊ីស្លាមមិនមែនសម្ដីដែលឥតខ្លឹមសារនោះទេ ។ គ្រាន់តែប្រកាសដើម្បីនឹងឲ្យវាបានសម្រេចនោះមិនគ្រប់គ្រាន់ទេ ។ ឯកភាពអ៊ីស្លាមបានសម្រេចជារូបជារាងឡើងអាស្រ័យលើការបំបាត់ការយល់ខុស និងអាស្រ័យលើការកម្ចាត់មតិឥតពិចារណា ការប៉ាន់ស្មានជាមុន និងការនិយាយមិនពិតដែលស៊ីរ៉ូងអ៊ុមម៉ាត្ត៍ (គឺប្រជាជាតិអ៊ីស្លាម) ។ គោលដៅដ៏ថ្លៃថ្លានេះឯងដែលអាល់-ស្វង់រ៍ព្យាយាមឆ្ពោះទៅរកនៅក្នុងសៀវភៅនេះ ដោយមិនខ្លាចទាស់ចិត្តនិកាយិក (គឺអ្នកប្រកាន់និកាយ) មួយចំនួនដែលបារម្ភតែគោរពបូជាទំនៀមទម្លាប់ខ្លះជាជាងចង់ស្គាល់ការពិតរបស់សាសនាអ៊ីស្លាម ។

សព្វថ្ងៃ មុស្លីមច្រើនចង់ដឹងមូលហេតុដែលធ្វើឲ្យអ៊ុមម៉ាត្ត៍ដុនដាប ចម្រើនល្ងូតលាស់តិចទៅៗ អ៊ុមម៉ាត្ត៍ដែលជាស្នងព្រះរាជសារដ៏មហារុងរឿងដែលចាត់ទុកការស្វែងរកការពិតនិងចំណេះវិជ្ជាជាសំខាន់ ដល់ថ្នាក់ចាត់ទុកទង្វើទាំងពីរនេះជាទង្វើដែលគួរឲ្យបូជា ។

ប្រាកដណាស់ បណ្ដាអ្នកសង្ស័យ បណ្ដាអ្នកប្រកបដោយព្យាបាទនិងបណ្ដាអ្នកបង្អាប់គុណូបការជំនឿខិតខំទម្លាក់ការដុនដាបអាប់ឱននេះទៅលើព្រះរាជសារផ្ទាល់តែម្ដង ដោយមិនបើកឲ្យដឹងព្រះប្រកាសិតរបស់ព្រះរាជសារនេះដែលបានប្រកាសសាហើយសាទៀតនោះ ឲ្យចាប់យកវិជ្ជាដែលបានបិទបាំងចោល នូវការដាស់តឿនឥតស្រាកស្រាន្តរបស់ព្រះរាជសារនេះឲ្យស្វែងរកការចេះដឹង ។ តែអ្នកមានសទ្ធានោះវិញ ដែលត្រូវពន្លឺជំនឿបំភ្លឺនិងត្រូវព្រះធម៌ព្រះរាជសារដឹកនាំនោះ មិនត្រូវឈ្លាសវៃគ្រាន់បើឡើងទេ ដើម្បីស្វែងរកដើមកំណើតវិបត្តិនិងមូលហេតុនៃការអាប់ឱនដុនដាបនៅក្នុងវិមគ្គកម្មនានាដែលខ្សែបន្ទាត់អ៊ីស្លាមបានជួបប្រទះ ខ្សែបន្ទាត់

ដែលព្រះសាស្តាបានគូសហើយនោះ និងនៅក្នុងការអនុវត្តិខុសព្រះរាជសារ ។

អកុសលគឺវិមគ្គកម្មទាំងនេះចាក់ឫស (ព្រោះតែមានចិរភាព ដោយសារការឃោសនាព័ត៌មានមិនពិតដឹកនាំដោយពួក "ឃោសនាមកពីវាំង" ដែលត្រូវពួកអ្នក "ប្រវត្តិសាស្រ្ត" ចាប់ធ្វើតទៅទៀត ហើយត្រូវបូជា - ដោយចេតនា ឬដោយអចេតនា - គឺពួកអ្នកប្រវត្តិសាស្រ្តដែលគិតតែស្រាវជ្រាវយក "ចម្លើយសាក្សី" និង "ឯកសារ" - ទោះបីចម្លើយសាក្សីនិងឯកសារទាំងនេះលម្អៀងក៏ដោយ - មិនគិតស្វែងរកការពិតទេ) គឺចាក់ឫសមាំដល់ថ្នាក់មុស្លីជាច្រើនមើលមិនឃើញអ្វីដែលពិត អ្វីដែលខុស អ្វីដែលស្របច្បាប់ អ្វីដែលខុសច្បាប់ អ្វីដែលជាមតិឥតពិចារណា នៅក្នុងឧប្បត្តិហេតុក្នុងប្រវត្តិវិសោធនការអ៊ីស្លាមដ៏យូរអង្វែង ។

កាលពីមុន សន្តតិវង្សនានាដែលបានគ្រប់គ្រងអ៊ុមម៉ាត់ក្នុងនាមអ៊ីស្លាមបារម្ភតែការពារអំណាច ជាជាងគោរពបញ្ញត្តិនៃព្រះរាជសារយ៉ាងហ្មត់ចត់ និងដោយឥតល្អៀង ។ ដោយដឹងថារាជ្យរបស់ខ្លួនមានភាពស្របច្បាប់អ៊ីស្លាមមិនប្រាកដនោះ ពួកសន្តតិវង្សទាំងនេះមិនបានប្រតិបត្តិការអ្វីមួយឡើយដើម្បីកែតម្រូវវិមគ្គកម្មទាំងនេះ ដើម្បីបញ្ចប់ការផ្សាយព័ត៌មានមិនពិត និងការនិយាយបង្ខូចសំដៅទៅកាន់ចរន្តអ៊ីស្លាមស៊្ញុីអ៊ុស្ស៊ុំដែលបរិសុទ្ធនិងស្របច្បាប់នោះ ។ តែសព្វថ្ងៃនេះ ខណៈដែលអ៊ុមម៉ាត់បានដកថយពីការងប់នឹងអំណាចគួរឲ្យខ្ពើម ហើយដឹងខ្លួនថាត្រូវតែត្រឡប់មកកាន់ប្រភពដើមវិញនិងមករកខ្សែបន្ទាត់អ៊ីស្លាម ដូចដែលត្រូវគូសដោយគួរអាននិងស៊្ញណាស់ព្រះសាស្តា លោកអាល់-ស្វាដ្ឋ័រ ដោយគិតតែរឿងអ៊ីស្លាមតែម្យ៉ាង មិនមានបំណងបង្កសង្គ្រាមប៉ាកកាឬពិភាក្សាឥតទល់



បានធ្វើសេចក្តីប្រកាសជាឱឡារិកមួយ ។

**ហ៊ីរ៉អ៊ំ** (حراء រូងភ្នំ)- កន្លែងដែលព្រះសាស្តាបានទទួលវ៉ាហ៊ី ។

**ហៃយ៉ា អាឡា ខ៉យរីល អ៊ាម៉ាល់** (حي على خير العمل) - ចូរប្រញាប់ប្រញាល់ធ្វើល្អ ។ នេះគឺឃ្លាមួយក្នុងការប្រកាសស្វ៉ឡាត់ (អាស្សាន) ។

**ហ៊ូដៃប៊ីយ៉ាស់** (الحديبية ការសម្រុះសម្រួល)- កន្លែងដែលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនៅហ៊ូដៃប៊ីយ៉ាស់ ជិតស្រុកម៉ាក់កាស់ ។

**អ៊ីជ្ទីហាដ់** (اِجْتِهاد) - មតិផ្ទាល់ខ្លួនដែលមុជ្តាហ៊ីដ្ ឬបុគ្គលដែលថាខ្លួនជាមុជ្តាហ៊ីដ្ធនោះបញ្ចេញឲ្យប្រើ ។

**អ៊ីសទៀហ៊្សាន** (اِسْتِحْسَان) - ការលម្អៀងដើម្បីធ្វើល្អ គឺប៉ែកមួយនៃអ៊ីជ្ទីហាដ់ ។

**អត្ថបទ** - មើល *ណាស្ស៍ ។*

**អ៊ុមម៉ាត់** - ប្រជាជាតិអ៊ីស្លាម ។

**អ៊ូឡាម៉ាអ៊ំ** (عُلَماء ពហុវចនៈ *អ៊ាលិម)* - បណ្ឌិតខាងច្បាប់អ៊ីស្លាម ។

**អាស្សាន** (أَذَان) - ការប្រកាសស្វ៉ឡាត់ ។

**អាស់លុល-បៃត៍** - ព្រះរាជកុលដ្ឋាន (របស់ព្រះសាស្តា) ។ សមាជិកគ្រួសាររបស់ព្រះសាស្តានិងបណ្តាកូនចៅរបស់ព្រះសាស្តាខាង អ៊ាលី-ហ្វាទីម៉ាស់ ។

**អាស់ឡាល់-គីតាប់** (اهل الكتاب) - ជនគម្ពីរ គឺបណ្តាអ្នកកាន់សាសនាដែលព្រះតែមួយគត់ គឺពួកគ្រិស្តនិងពួកយ៉ាហ៊ូឌី ។

**អ៊ាឡាវី** ឬ **អ៊ាឡាវីយ៉ាស់** (عَلَوِيّ **ឬ** علوية) - មកពាក្យអារ៉ាប់ អាឡាវីយូនឯកវចនៈ អាឡាវី គឺបណ្តាកូនចៅរបស់អាស់លុល-បៃត៍ ។

**អាលី មូហ៊ាំម៉ាដ់** - គ្រួសារនិងបណ្តាកូនចៅរបស់ព្រះសាស្តាមូហ៊ាំម៉ាដ់ ។

**អាន់ស្វារ** (أنصار) - បណ្តាអ្នកគាំទ្រ គឺបណ្តាអ្នកស្រុកម៉ាឌីណាស់ដែល

**សញ្ជ័យ** - ពាក្យអារ៉ាប់ ហ្វាត់ហ៍ (فتح) គឺការច្បាំងយកនគរម៉ាក់កាស់ ។

**ស៊ូរ៉ (شورى)** - ការពិភាក្សា ការពិគ្រោះក្នុងចំណោមពួកមុស្លីម ។

**សាវក** - មកពីពាក្យអារ៉ាប់ ស្ហាប៊ី ពហុវចនៈ ស្ហាបាស់ គឺបណ្ដាសាវករបស់ព្រះសាស្ដា គឺមុស្លីមដំបូងដែលរួមមានពួកមូហ្ជាយ៉ីរីននិងពួកអាន់ស្វារ (គឺពួកអ្នកគាំទ្រនិងពួកអ្នកភៀសខ្លួន) ។

**សាសនៈទូត** - គឺព្រះសាស្ដាﷺ ។

**សម្រុះសម្រួល** នៅហ៊្វដៃប៊ីយ៉ាស់- គឺសន្ធិសញ្ញាសន្តិសុខរវាងពួកមុស្លីមនិងពួកពហុទេពនិយមស្រុកម៉ាក់កាស់ ក្នុងឆ្នាំទី ៦ សករាជហ៊ីជ្រ៉ោះត៍ ។

**ស្ហ៊ិះហ៍** (صحيح) **ពហុវចនៈ ស្ហ៊ីហាស់** (صِحاح) - ការហៅតម្រាទាំងឡាយដែលសន្មតថាកត់ត្រាតែហាឌីស្សពិតប្រាកដឥតក្លែងក្លាយ ។

**សាគីហ្វាស់** (السقيفة) - សាគីហ្វាស់របស់ បានូ សាអ៊ីដាស់ (سقيفة بني ساعدة) គឺផ្ទះ ឬ ជំរំសំពត់របស់កុលសម្ព័ន្ធ បានូ សាអ៊ីដាស់ ។ ទីនេះឯងដែលពួកមុស្លីមបានប្រជុំគ្នាមុនបញ្ចុះព្រះរាជសពព្រះសាស្ដាដើម្បីជ្រើសរើសអ្នកស្នងព្រះអង្គ ។

**សាស្ដាចុងក្រោយបំផុត** - ព្រះសាស្ដាមូហាំម៉ាដ់ﷺត្រូវចាត់ទុកជាព្រះសាស្ដាក្រោយបង្អស់ដែលអល់ឡោះហ៍ﷻដាក់មកឲ្យមនុស្សជាតិ ។

**ស៊ូណាស់** - ទំនៀមទម្លាប់របស់ព្រះសាស្ដា គឺសម្ដី អំពើនិងទង្វើរបស់ព្រះសាស្ដា ។ ពហុវចនៈ *ស៊ូណាន់ ។*

**ហ្វៃអ៊ុ** (فَيْء) - ទ្រព្យ វត្ថុយកបានពីសត្រូវ ។

**ហាឌីស្ស** - ទំនៀមទម្លាប់និងសម្ដីរបស់ព្រះសាស្ដា ។

**ហាច់យ៉ាស់ អាល់-វ៉ាដាក់** (حَجَّة الوَداع) - ពិធីហាច់លាគ្នា ពិធីហាច់ចុងក្រោយបង្អស់របស់ព្រះសាស្ដា នៅក្នុងឱកាសនេះឯងដែលព្រះអង្គ



ដោយងប់ងល់ទេនោះ ស្នើសូមរំលឹកយើងនូវការពិតខ្លះដែលប្រចក្សតែត្រូវចោលមិនអើពើដ៏យូរហើយត្រូវបង្ខូចដោយចេតនា ។

ការពិតធំបំផុតដែលលោកអ្នកនិកពន្ធធ្វើឲ្យមុស្លីមចាប់អារម្មណ៍នោះ គឺរឿងដើមកំណើតស្ហ៊ីអាស់ ។ ដើម្បីទាក់ទាញអារម្មណ៍មុស្លីមមករកចំណុចនេះ លោករំលឹកយើងជាបឋមថាកាលព្រះសាស្ដានៅមានព្រះជន្ម មុស្លីមជំនាន់ដំបូង - គឺបណ្ដាសាវក - បែងចែកជាពីរចរន្តពាក់ព័ន្ធនឹងការកាន់ឥរិយាបថចំពោះការសម្រេចបទបញ្ជា និងអនុសាសន៍របស់ព្រះសាសនៈទូត - ពោលគឺ ចំពោះស៊ូណាស់ ។ ចរន្ត "អ្នកអនុលោមតាម" ចុះចូលខ្លួនទាំងស្រុងចំពោះទង្វើនិងសម្ដីរបស់ព្រះសាស្ដា ហើយចាត់ទុកថាត្រឹមត្រូវមិនចេះខុស ។ ចរន្តមួយទៀត ដែលសន្មតថាខ្លួនមានសិទ្ធិតវ៉ាស៊ូណាស់ព្រះសាស្ដា ហើយហ៊ានប្រឆាំងស៊ូណាស់ទាំងនេះទៀតផង ។ លោកអ្នកនិពន្ធហៅចរន្តដំបូងថា "ចរន្តបដិបត្តិតាមព្រះអត្ថបទ" (ឬធម្មប្បដិបត្តិតាមព្រះអត្ថបទ) ហៅចរន្តទីពីរថា "ចរន្តមតិខ្លួនឯងក្នុងព្រះអត្ថបទ *(អ៊ីជ្ទីហាដ់)"*។

ភាពខុសគ្នារវាងទាំងពីរនិន្នាការនេះបានលេចឡើងច្បាស់ទែង ក្នុងពេលព្រះសាស្ដាចូលទិវង្គត ។ ចរន្តដំបូង គឺចរន្ត "បដិបត្តិតាមព្រះអត្ថបទ" យល់ឃើញថាការស្នងព្រះសាស្ដាមានជាស្រេចហើយ ពីព្រោះព្រះអង្គដោយចែងឲ្យច្បាស់និងដោយមិនបាច់ចែងឲ្យច្បាស់ បានជ្រើសរើសអ៊ីម៉ាំអាលីជាអ្នកស្នងព្រះអង្គ នៅក្នុងហាឌីស្សជាច្រើន ជាពិសេស "ហាឌីស្សអាល់-ស្ហាក៏ឡែន៍" និង "ហាឌីស្ស ក៏ដៀរ៍ យុម" ដោយហេតុនេះមុស្លីមទាំងឡាយត្រូវតែគោរពតាមមរតកសាសន៍ ឬតាមសេចក្ដីប្រកាសនិងអនុសាសន៍របស់ព្រះសាស្ដា ។ ចំណែកឯបណ្ដាអ្នកនិយមចរន្តទីពីរឯ

នោះវិញបានប្រជុំគ្នានៅឯ *សាគីហ្វាស្ស៍* ដើម្បីជ្រើសរើសគ្នាឯងម្នាក់ជាអ្នកស្នងព្រះសាស្តា (គឺជាស្តេចខ៉ិលិហ្វ) ដោយផ្អែកទៅលើគោលការណ៍ *ស៊ូរ៉* ។

ដូច្នេះ ផ្ទុយពីការស្មានរបស់មនុស្សសាមញ្ញ ឬមុស្លីមមិនចេះដឹង ចរន្តដំបូងនោះទេ គឺចរន្ត "បដិបត្តិតាមព្រះអគ្គបទ" ឬចរន្ត "គោរពតាមស៊ូណាស្ស៍ព្រះសាស្តាយ៉ាងហ្មត់ចត់" ជាដើមកំណើត ជាបណ្តូលនិងជាមូលដ្ឋានរបស់ស៊ីអាស្ស៍[3] ។

អាស្រ័យហេតុនេះ លោកអ្នកនិពន្ធស្នើសូមឲ្យយើងធ្វើការសំគាល់មុនគេគឺ ស៊ីអាស្ស៍ចាប់កំណើតឡើងពីចរន្តអ៊ីស្លាមនិយមគោរពស៊ូណាស្ស៍ព្រះសាស្តាយ៉ាងហ្មត់ចត់ ហើយផ្ទុយពីចរន្តអ៊ីស្លាមមួយទៀតដែលទេរទៅរក *អ៊ីច្ធីហ្វាដ្ស៍* ក្នុងអគ្គបទព្រះសាស្តា ហើយមិនញញើតតវ៉ាសេចក្តីសម្រេចមួយចំនួននិងសេចក្តីបង្គាប់របស់ស៊ូណាស្ស៍ទេ ។

---

[3] ព្រោះតែគេដឹងថាស៊ីអាស្ស៍ប្រើ *អ៊ីច្ធីហ្វាដ្ស៍* ហើយដើម្បីនឹងកុំឲ្យច្រឡំជាមួយចរន្ត "អ៊ីច្ធីហ្វាដ្ស៍ក្នុងព្រះអគ្គបទ" លោកអ្នកនិពន្ធបញ្ជាក់ថាពួកស៊ីអាស្ស៍បែងចែក *អ៊ីច្ធីហ្វាដ្ស៍* ពីរប្រភេទដាច់ឡែកគ្នាគឺ៖ *អ៊ីច្ធីហ្វាដ្ស៍* ក្នុងស៊ូណាស្ស៍ (ពោលគឺ ចេញយោបល់ខ្លួនឯងអំពីបទបញ្ញត្តិណាមួយខុសពីបទបញ្ញត្តិរបស់ស៊ូណាស្ស៍) ម្យ៉ាង - ប្រភេទ *អ៊ីច្ធីហ្វាដ្ស៍* នេះឯងដែលពួកស៊ីអាស្ស៍បដិសេធ - ម្យ៉ាងទៀតគឺ *អ៊ីច្ធីហ្វាដ្ស៍* មកពីស៊ូណាស្ស៍ (ពោលគឺ ដកស្រង់យកនូវយោបល់ស្របច្បាប់មួយ ចេញមកពីគួរអាននិងស៊ូណាស្ស៍ ពាក់ព័ន្ធនឹងស្ថានការណ៍ថ្មីៗនិងចៃដន្យដែលពុំឃើញមានចែងនៅក្នុងព្រះអគ្គបទដោយច្បាស់លាស់) - *អ៊ីច្ធីហ្វាដ្ស៍* ប្រភេទនេះឯងដែលពួកស៊ីអាស្ស៍ទទួលស្គាល់ហើយនៅតែប្រើ ។



**ម៉ារ៉យ៉ាអ៊ីយ៉ាស្ស៍** (المَرجَعيّة) - អាជ្ញាធរកំពូល ។ ទីសំអាងកំពូលក្នុងអ៊ីស្លាម ។

**មូហាយ៉ីរីន** (مهاجرين) - មើលភៀសខ្លួន ។

**មុតតាអាស្ស៍ អាល់-ហាច់** (ឬ **ហាច់ អាល់-តាម៉ាត់ទុអ៊ុ**) - គឺទង្វើមួយចំនួនក្នុងពិធីហាច្ច ។ ទង្វើទាំងនេះត្រូវស្តេចខ៉ិលិហ្វលុបចោល ។

**យ៉ាហ៊ុលីយ៉ាស្ស៍** (جاهِليّة) - យ៉ាហ៊ុលីយ៉ាស្ស៍គឺសង្គមមុនអ៊ីស្លាមសាសនា គឺសម័យអវិជ្ជា ។ ន័យទូលាយគឺ សេចក្តីល្ងង់ខ្លៅ សេចក្តីងងឹតល្ងង់ និងអ្វីៗដែលនៅក្រៅតៅហ៊ីដ្ធ ។

**រួចខ្លួន** - ពួក "ទូឡាក៍" ពួកពហុទេពនិយមស្រុកម៉ាក់កាស្ស៍ដែលមិនព្រមកាន់សាសនាអ៊ីស្លាម ហើយត្រូវចាប់ខ្លួនជាឈ្លើយសឹកពេលច្បាំងយកម៉ាក់កាស្ស៍ ក្រោយមកត្រូវរួចទោស ត្រូវដោះលែងដោយព្រះសាស្តា ។

**វិសោធនការ** - គឺវិសោធនការអ៊ីស្លាម ។ គឺការដាក់ឲ្យអនុវត្តិសាសនាអ៊ីស្លាមតាមព្រះបញ្ញាអល់ឡោះហ៍ដែលត្រូវបានប្រកាសហើយ (គឺព្រះក្រាសិត) ពេលអត់ពីព្រះសាស្តា ក្រោមការដឹកនាំរបស់ព្រះអគ្គប្រមុខស្នងព្រះសាសនៈទូត ។

**ស៊ីអាស្ស៍ និង ស៊ីអ៊ីត** - ពួកមុស្លីមធម្មានុរូបនិយម (គឺដែលស្របទៅតាមធម៌ភាគតិច ។ គេហៅថាស៊ីអាស្ស៍ព្រោះមុស្លីមទាំងនេះជាអ្នកនិយមខ្សែបន្ទាត់របស់អ៊ីម៉ាំអាលី ។ ពួកគេយល់ឃើញថាការជំពាក់ចិត្តទៅលើស៊ូណាស្ស៍ព្រះសាស្តាទាមទារឲ្យបដិបត្តិតាមបដិញ្ញា (គឺការកំណត់) ទាំងអស់របស់ស៊ូណាស្ស៍ ព្រមទាំងការតែងតាំងអ៊ីម៉ាំអាលីជាអ្នកស្នងដោយព្រះសាស្តានោះដែរ ។ យោលតាមពួកគេ អាជ្ញាធរកំពូលរបស់អ៊ុមម៉ាត្ស៍អ៊ីស្លាមបានមកអ៊ីម៉ាំអាលី ក្រោយពីព្រះសាស្តាចូលទិវង្គត និងយោលតាមព្រះសាស្តា ។

# អក្ខរានុក្រម

**ខ៉ុលីហ្វាស់ដែលបានទទួលការដឹកនាំល្អ ឬ ខ៉ុលិហ្វដែលបានទទួលការដឹកនាំល្អ** - ស្តេចខ៉ុលិហ្វដំបូងទាំងបួនដែលបាន ស្នងតពីព្រះសាស្តា ។ រៀងតាមកាល គឺមាន អាប៊ូ បាការ, អ៊ុម៉ារ អ៊ីបនូ អាល់-ខ៉ុត្តតប់, អ៊ុស្មម៉ាន អ៊ីបនូ អ៊ាហ្វហ្វាន (عثمان بن عفان), អ៊ាលី អ៊ីបនូ អាប៊ី ត៉ូលិប ។

**គូរ៉យស្ហ៍** - កុលសម្ព័ន្ធរបស់ព្រះសាស្តា ។

**ណាស្វ៍** (نَصّ) - ព្រះអត្ថបទ គឺអ្វីៗដែលត្រូវចែងនៅក្នុងគួរអាននិងស៊ូណាស់ ។

**តាប៊ីអ៊ីន** (التابعين) - អ្នកតាម គឺបណ្តាសាវករបស់បណ្តាសាវករបស់ព្រះសាស្តា ។

**តាបាកូត់** - និវេទន៍ប្រាប់ជីវប្រវត្តិរបស់បណ្តាអ្នកចម្លងឬផ្ទេរហ្ទាឌីស្ហ ។

**តាក់បៀរ** - គឺសូត្រថា៖ "អល់ឡហ៊្វ អាក់ុបារ៍" ។

**ទ្វាទសមគ្គទេសក៍** (ស្ហ៊ីអ៊ាស់តាមអ៊ីម៉ាំដប់ពីរអង្គ) - ស្ហ៊ីអ៊ាស់ភ័ក្តីចំពោះអ៊ីម៉ាំអាស្វល់លុល-បៃត៍ទាំងដប់ពីរអង្គ ។

**ព្រះប្រកាសិត** - ប្រកាសិតឲ្យមករកអ៊ីស្លាមដែលព្រះសាស្តាបានប្រកាស ។

**ព្រះរាជសារ** - សារអ៊ីស្លាមដែលគេបើកឲ្យព្រះសាស្តាមូហ៉ាំម៉ាដ់ﷺដឹង ។

**ពីធីហ្វាច្ចុចុងក្រោយបង្អស់** - មើល ហ្វាច្ចុំយ៉ាស់ អាល់-វ៉ាដ្ទាក់ ។

**ភៀសខ្លួន** - ពាក្យអារ៉ាប់ អាល់-មូហ្វាយ៉ីរីន (المهاجرين) គឺពួកមុស្លីមស្រុកម៉ាក់កាស់ដែលបានភៀសខ្លួនជាមួយព្រះសាស្តា ទៅកាន់ស្រុកម៉ាឌីណាស់ ដើម្បីគេចការសង្កត់សង្កិនរបស់បងប្អូនស្រុកមួយរបស់ខ្លួនដែលជាបុគ្គលពហុទេពនិយម ។



បន្ទាប់ពីព្រះសាស្តាសោយព្រះទិវង្គត ខណៈដែលចរន្ត *"អ៊ីច្ចទីហ្វាដ់* ក្នុងអត្ថបទព្រះសាស្តា" - គឺចរន្ត *សាគីហ្វាស់* - ឡើងសោយរាជ្យហើយដោយហេតុនេះឯងបានជាទៅជាភាគច្រើននៅក្នុងអ៊ុមម៉ាត់ ចរន្តមួយទៀត គឺចរន្ត "បដិបត្តិតាមព្រះអត្ថបទ" យល់ឃើញថាការគោរពតាមស៊ូណាស់ទាមទារឲ្យខ្លួនត្រូវទទួលស្គាល់អ៊ីម៉ាំ អ៊ាលី អ៊ីបនូ អាប៊ី ត៉ូលិប ជាអ្នកស្នងព្រះសាស្តាស្របតាមច្បាប់ ហើយ ព្រោះតែប្រឆាំងអំណាច ចរន្តនេះក្លាយទៅជាចរន្តភាគតិចនៅក្នុងរដ្ឋអ៊ីស្លាម ។ ដូច្នេះអ៊ីម៉ាំអ៊ាលីនិងបណ្តាកូនចៅអាស្វល់លុល-បៃត៍របស់ព្រះអង្គប្រែក្លាយបន្តិចម្តងៗ ទៅជានិមិត្តរូបនៃការជំពាក់ជិតជាប់នឹងស៊ូណាស់ព្រះសាស្តា និងជំពាក់ជិតជាប់នឹងខ្សែបន្ទាត់អ៊ីស្លាមស្របច្បាប់ ។ បណ្តាអ្នកគាំទ្រខ្សែបន្ទាត់នេះ ឬចរន្តអ៊ីស្លាមមួយនេះនឹងត្រូវហៅថាស្ហ៊ីអ៊ាស់ (គឺអ្នកគាំទ្រ ឬ បក្សពួក) របស់អ៊ាលី ។

ដូចគេបានសម្គាល់ឃើញហើយ ពាក្យ "ស៊ូនីត (ឬ ស៊ូណាស់)" និងពាក្យ "ស្ហ៊ីអ៊ាស់ (ឬ ស្ហ៊ីអ៊ីត)" ដែលគេតែងតែលើកយកមកប្រើដើម្បីដាក់អ្នកទទួលកេរដំណែលចរន្តទាំងពីរនេះឲ្យប្រឈមមុខគ្នានោះ មិនត្រឹមត្រូវនឹងការពិតនៃប្រវត្តិសាស្ត្រទេ ហើយពាក្យទាំងពីនេះត្រូវបង្កើតឡើងនិងត្រូវប្រើប្រាស់មិនចំ (ឬមិនត្រូវ) ជាពិសេសពេលវាមានន័យប្រៀបធៀបនឹងគ្នា ឬមានន័យប្រឆាំងគ្នា ។ មែន គេចូលចិត្តចាត់ទុកថាស្ហ៊ីអ៊ាស់មានន័យថាចរន្តរបស់ពួកដែលគាំទ្រអ៊ីម៉ាំអ៊ាលីصلوات الله عليه والسلام រីឯស៊ូនីតមានន័យថានិន្នាការរបស់ពួកដែលគាំទ្រស៊ូណាស់ ។ តែ បើគេឲ្យចាត់ទុកថាពាក្យ "ស៊ូនីត" ដែលក្លាយមកពីពាក្យ *"ស៊ូណាស់"* មានន័យថាជំពាក់ចិត្តស្រឡាញ់ *ស៊ូណាស់* នោះ សក្តិសមហៅពួកស្ហ៊ីអ៊ាស់ថាស៊ូនីតជាងគេ ហើយសក្តិសមទាមទារយកឈ្មោះស៊ូនីត ។ ពីព្រោះ ដូចយើងទើបនឹងបានសម្គាល់ឃើញហើយ "អត្ថន័យ" របស់ស្ហ៊ីអ៊ាស់ ជាបឋមគឺ "បដិបត្តិតាមព្រះ

អត្ថបទ" និងការបដិសេធថាមិនលម្អៀងចេញពីនេះទេ ដូច្នេះវាជាការប្រឆាំងនឹងចរន្ត *សាត្តីហ្វាស្ង់ ។* បន្ទាប់មក ពួកស្ទ្រីអ៊ុស្ង់ (ឬស្ទ្រីអ៊ីត) ជា "បក្សពួករបស់អ៊ុលី" ព្រោះតែពួកគេជំពាក់ចិត្តស្រឡាញ់ស៊ូណាស្ង់ហើយអ៊ុលីជានិមត្តរូប ជាតំណាងនិងជាការបកស្រាយនៃការជំពាក់ចិត្តស្រឡាញ់នេះឯង ។ គឺថាការជំពាក់ចិត្តស្រឡាញ់អ៊ីម៉ាំអ៊ុលីនោះជាលក្ខណៈបន្ទាប់បន្សំ មិនសំខាន់បំផុត របស់មុស្លីមស្ទ្រីអ៊ុស្ង់ ។ វានៅក្រោមការជំពាក់ចិត្តស្រឡាញ់ស៊ូណាស្ង់ព្រះសាស្តា ។ ទីបំផុត ត្រូវរំលឹកឡើងវិញថា "បដិបត្តិតាមព្រះអត្ថបទ" សម្រាប់ពួកស្ទ្រីអ៊ុស្ង់ មិនមានព្រំដែនត្រឹមតែតែងតាំងអ៊ីម៉ាំអ៊ុលីជាអ្នកស្នងព្រះសាស្តាតែប៉ុណ្ណោះទេ តែវាវាតទៅលើខនានាដែលមានចែងនៅក្នុងស៊ូណាស្ង់ ប្រៀបបាននឹងការប្រើ *"អ៊ិច្ចទីហ្វាដ្ង់* ក្នុងព្រះអត្ថបទ" និងការលម្អៀងចេញពីស៊ូណាស្ង់នោះដែរ ដែលសម្រាប់ចរន្ត *សាត្តីហ្វាស្ង់* មិនមានព្រំដែនត្រឹមតែបញ្ហាស្នងព្រះសាសនៈទូតដោយស្របច្បាប់ប៉ុណ្ណោះនោះទេ តែប៉ះពាល់ដល់ទៅផ្នែកច្រើនទៀត ។ លោកអ្នកនិពន្ធបានលើកឡើងច្រើនឧទាហរណ៍ ។

ដូច្នេះការហៅថា "ស៊ូនីត" និង "ស្ទ្រីអ៊ុស្ង់ (ឬ ស្ទ្រីអ៊ីត)" ដែលគេប្រើសម្រាប់ហៅអ្នកគាំទ្រចរន្តដើមទាំងពីរដែលបានអធិប្បាយខាងលើហើយជួយធ្វើឲ្យការយល់ច្រឡំនិងមតិឥតពិចារណា កាន់តែមានយូរតរៀងមក ជួយធ្វើឲ្យការជំពាក់ចិត្តស្រឡាញ់ស៊ូណាស្ង់មានអត្ថន័យខុស ជួយបើកដៃឲ្យបដិសច្ចៈ (គឺការប្រឆាំងការពិត) វាតសុសសាយពាសពេញ ។ ដូច្នេះត្រូវតែធ្វើឲ្យពាក្យទាំងពីរនេះមានអត្ថន័យពិត ដែលត្រឹមត្រូវនឹងការពិតរបស់ព្រឹត្តិការណ៍គឺៈ "ស៊ូនីត" អាចមានអត្ថន័យពិតថា គន្លប្បដិបទាភ័ក្តីពោលគឺ ប៉ែកភាគច្រើនដែលមានលក្ខណៈភ័ក្តីចំពោះស្តេចខ៌លិហ្វកាន់អំណាច ផ្ទុយពីស្ទ្រីអ៊ុស្ង់ ចរន្តត្រូវច្បាប់ ដែលចាត់ទុកអ៊ីម៉ាំអ៊ុលី (និងខ្មែរ



មួយ ក្នុងការធ្វើសង្គមកិច្ចដោយយោលទៅតាមកាលៈទេសៈគោលដៅ ហើយជាការបកស្រាយឲ្យឃើញ នូវសម្បជញ្ញៈជ្រាលជ្រៅរបស់ព្រះអង្គ អំពីប្រភេទនិងចលនាកែប្រែដែលត្រូវអនុវត្តិ និងអំពីមធ្យោបាយដែលសក្តិសមក្នុងការប្រតិបត្តិ (សង្គមកិច្ចនេះ) ។

ដែលប៉ុនប៉ងការពារសេចក្តីដឹងខ្លួននិងឆន្ទៈអ៊ីស្លាម ដោយការលះបង់ទាំងអស់សង្ឃឹម ។ អ៊ីម៉ាំបានគាំទ្រអ្នកណាដែលស្មោះត្រង់ជាងគេក្នុងចំណោមពួកនេះ ។

អ៊ីម៉ាំ អ៊ាលី អ៊ីបនូ អាល់-រីដ្ហ៍[69] صلوات الله عليه والسلام មានវចនៈអំពីមរណៈភាពរបស់ ស្សៃដ្ឋ៍ អ៊ីបនូ អ៊ាលី ប្រាប់ស្តេចខ៉ិលិហ្វ អាល់-ម៉ាក់មូន ថា៖ "លោកនៅក្នុងចំណោមអ៊ូឡាម៉ាអ៍ (عُلَماء)[70] ព្រះរាជកុលដ្ឋានព្រះសាស្តាមួយអង្គ ។ លោកបានតស៊ូទល់នឹងពួកសត្រូវអល់ឡោះហ្ញ៍ عز وجل ហើយបានប្រយុទ្ធនឹងពួកវាលុះត្រូវស្លាប់ដើម្បីមូលហេតុអល់ឡោះហ្ញ៍ عز وجل ។ ព្រះបិតាទូលបង្គំ មូសា អ៊ីបនូ យ៉ាក្កហ្វារ៍ صلوات الله عليه والسلام បានប្រាប់ទូលបង្គំ صلوات الله عليه والسلام ថាព្រះបិតា صلوات الله عليه والسلام ព្រះអង្គ صلوات الله عليه والسلام យ៉ាក្កហ្វារ៍ صلوات الله عليه والسلام មានវចនៈថា៖ "អល់ឡោះហ្ញ៍ عز وجل មានព្រះមេត្តាប្រោសប្រណីចំពោះឪពុកមាទូលបង្គំ صلوات الله عليه والسلام ស្សៃដ្ឋ៍ ដែលបានប្រកាសសូមឲ្យគាំទ្រ "អាលី មូហ្ញាំម៉ាដ្ឋ៍" ។ បើលោកមានជ័យជំនះ (ចម្បាំង) លោកប្រាកដជាបានបំពេញតាមកិច្ចសន្យាចំពោះអល់ឡោះហ្ញ៍ عز وجل (ថានឹងធ្វើឲ្យ "អាលី មូហ្ញាំម៉ាដ្ឋ៍[71]" មានជ័យជំនះ) ។..."

ដូច្នេះ ហេតុដែលអ៊ីម៉ាំបានលះបង់ចោលនូវចលនាប្រដាប់អាវុធផ្ទាល់តទល់នឹងពួកវៀចវេរ មិនមានន័យថាព្រះអង្គបោះបង់ចោលលក្ខណៈសង្គមនៃអាជ្ញាធរ មិនសំកុកសំកុលនៅតែក្នុងផ្ទះធ្វើកិច្ចប្រតិបត្តិសាសនាឱនងើបៗនោះទេ តែនេះជាហេតុដែលបកស្រាយឲ្យឃើញនូវវិធានការផ្សេង

[69] អ៊ីម៉ាំទី ៨ របស់ពួកស្ទីអ៊ីតដែលតាមអ៊ីម៉ាំទាំង ១២ អង្គ ។

[70] បណ្ឌិតជាន់ខ្ពស់ខាងច្បាប់សាសនា ។

[71] អាលី មូហ្ញាំម៉ាដ្ឋ៍ គឺបណ្តាកូនចៅគ្រួសាររបស់ព្រះសាស្តាមូហ្ញាំម៉ាដ្ឋ៍ صلى الله عليه وآله وسلم ។



បន្ទាត់ដែលមានព្រះអង្គជាតំណាងនោះ) ជាអ្នកស្នងមួយគត់របស់ព្រះសាស្តា ដែលត្រូវច្បាប់និងពេញលក្ខណៈច្បាប់ ។

បន្ទាប់ពីពិព័ណ៌នាចប់ហើយ ត្រូវសម្គាល់ថាសាយិដ្ឋ មូហ្ញាំម៉ាដ្ឋ៍ បាគៀរ អាល់-ស្វដ្ឋ៍រ៍ មិនមានបំណងលើកយកស្ទីអ៊ាស៊ូមកប្រទូស្តនឹងស៊ូនីតនៅក្នុងសៀវភៅនេះទេ - ម្យ៉ាងទៀតពាក្យស៊ូនីតមិនមាននៅក្នុងសៀវភៅនេះទេ - តែលោកមានបំណងតែម្យ៉ាងទេ គឺកែតម្រូវព័ត៌មានមិនពិតនិងបំបាត់ការយល់ច្រឡំដើម្បីនឹងធ្វើឲ្យមុស្លីមទូទៅរួបរួមគ្នា ជុំវិញច្បាប់អ៊ីស្លាមស្ហារីអ៊ាស៊ូដែលមានគួរអាននិងស៊ូណាស៊ូជាតំណាង គួរអាននិងស៊ូណាស៊ូដែលមុស្លីមទូទៅជំពាក់ចិត្តស្រឡាញ់ជាទីបំផុត ។

ដោយលើកយកហាឌីស្ហព្រះសាស្តាមួយចំនួន និងចម្លើយសាក្សីរបស់ស្តេចខ៉ិលិហ្វខ្លះមកជាសម្អាងបញ្ជាក់ លោកអ្នកនិពន្ធផ្តល់ឲ្យមុស្លីមនូវគ្រឿងសម្គាល់ដើម្បីនឹងអាចរកការពិតបានដោយខ្លួនឯង នៅក្នុងតម្រាប្រវត្តិសាស្រ្តអ៊ីស្លាមទាំងអស់ ដោយមិនយកចិត្តទុកដាក់នឹងមតិឥតពិចារណា គំនិតចចាមអារ៉ាមនិងលម្អៀងដែលអ្នកចងក្រងតម្រាទាំងនោះអាចបញ្ចេះអារម្មណ៍មុស្លីមរូបនោះ ។

សព្វថ្ងៃនេះ ខណៈដែលមានសម្លេងប្រកបដោយព្យាបាទលេចឮខាងនេះបន្តិច ខាងនោះបន្តិច ក្នុងបំណងបង្កឲ្យមានការសង្ស័យអំពីប្រភពច្បាប់អ៊ីស្លាមស្ហារីអ៊ាស៊ូនោះ មុស្លីមជាច្រើនសួរខ្លួនឯងអំពីអតីត បច្ចុប្បន្ននិងអនាគតរបស់អ៊ីស្លាម ។ តែបែរទៅមើលម្ខាងទៀត គឺខាងដែលគេយកច្បាប់អ៊ីស្លាមស្ហារីអ៊ាស៊ូទៅអនុវត្តិ ជាការសមហេតុសមផលនិងប្រកបដោយសមធម៌ជាងមែនទេ ? តើវាជាកាតព្វកិច្ចងាយបំផុតរបស់មុស្លីម

គ្រប់រូបមែនទេ ? លោកអ្នកនិពន្ធមិនមានបំណងញុះញង់មុស្លីមឲ្យព្រមទទួលយកបែបបទច្បាប់ស៊ីអ៊ាស់ជាជាងបែបទច្បាប់ឯទៀតឡើយ តែលោកចង់ឲ្យមុស្លីមស្គាល់និងគោរពបទបញ្ញត្តិព្រះរាជសារទាំងមូល ឬយ៉ាងហោចណាស់ ចង់ឲ្យមុស្លីមមានសេចក្ដីក្លាហានប្រព្រឹត្តិត្រឹមត្រូវចំពោះបណ្ដាអ្នកដែលខិតខំគោរពតាមបទបញ្ញត្តិទាំងនោះ ទោះជាពួកគេទទួលរងការសង្កត់សង្កិននិងការប្រមាថរាប់សតវត្សមកហើយក៏ដោយ ។

បើយើងមិនព្រមគូសបញ្ជាក់កំហុសរបស់បុព្វការីយើង ដោយមិនលម្អៀងទេនោះ តើយើងអាចកែកំហុសខ្លួនយើងនិងការប្រព្រឹត្តិខុសរបស់យើងសព្វថ្ងៃនេះបានដូចម្ដេចទៅ

អ៊ុបបាស់ អាស៊ុំម៉ាជ៉ុំ អាល់-ប៊ុសតានី
ប៉ារីស, កក្កដា ១៩៩៨



ពីត្រូវបណ្ដេញចេញ - ដោយប្រើគ្រប់មធ្យោបាយដែលជឿថាអាចប្រើបាន ពីព្រោះថ្នាក់ដឹកនាំស៊ីអ៊ាស់យល់ឃើញថា មានសំណាក់ប្រជារាស្ត្រដែលមានមនសិការ (គឺយកចិត្តទុកដាក់) ឬកំពុងតែមានមនសិការ ក្នុងចំណោមពួកមូហាជីរីន ពួកអាន់ស្វារនិងបណ្ដាអ្នកតាម (التابعين អាល់-តាប៊ីអ៊ីន) ។ តែកន្លះសតវត្សក្រោយមក ពេលសំណាក់មនសិការនេះបានបាត់អស់ ឬស្ទើរអស់ ហើយគេឃើញមានកើតមានឡើង - នៅក្រោមរជ្ជកាលវៀចវេរ - នូវជំនាន់មនុស្សសោះអង្គើយ ការដណ្ដើមយកអំណាចដោយចលនាស៊ីអ៊ាស់ ដោយគ្មានមូលដ្ឋានប្រជារាស្ត្រត្រៀមខ្លួនចាំគាំទ្រយ៉ាងយកចិត្តទុកដាក់និងដោយលះបង់ចាំបាច់នោះ ពុំអាចបានទៅដល់ការសម្រេចគោលដៅអ៊ីស្លាមធំធេងទេ ។

ប្រឈមនឹងស្ថានភាពបែបនេះ ថ្នាក់ដឹកនាំស៊ីអ៊ាស់ចាំបាច់ធ្វើសកម្មភាពពីរប្រភេទគឺ៖

១- បំពេញភារកិច្ចក្នុងគោលបំណងបង្កបង្កើតមូលដ្ឋានប្រជារាស្ត្រ ដែលមានសេចក្ដីដឹងខ្លួនដើម្បីប្រុងប្រៀបខ្លួនដណ្ដើមអំណាច ។

២- ស្ដារសេចក្ដីដឹងខ្លួននិងឆន្ទៈរបស់អ៊ុមម៉ាត់ឡើងវិញ រក្សាសេចក្ដីដឹងខ្លួននិងឆន្ទៈនេះនៅក្នុងកម្រិតមុឹងម៉ាត់និងកម្រិតរស់រវើក ដើម្បីនឹងអាចបង្ការប្រជាជាតិអ៊ីស្លាម កុំឲ្យបោះបង់ខ្លួននិងសេចក្ដីថ្លៃថ្នូរទាំងស្រុងចោលនៅក្នុងរដ្ឋាភិបាលវៀចវេរ ។

សកម្មភាពប្រភេទទីមួយត្រូវបានប្រតិបត្តិដោយអ៊ីម៉ាំផ្ទាល់ សកម្មភាពប្រភេទទីពីរត្រូវបានប្រតិបត្តិដោយពួកអ៊ាឡាវី (عَلَوِيّ ឬ علوية)[68] បះបោរ

[68] ពួកកូនចៅរបស់អ៊ីម៉ាំអ៊ាលី អ៊ីបនូ អាប៊ី ត៏លិប ។

ទៅដែលស្មានថាអ៊ីម៉ាំអាចដកខ្លួនចេញពីជីវិតសង្គមបាន ដោយមិនដកខ្លួនចេញពីស៊ីអ៊ុស់ដែរនោះ ។

ដែលគេគិតថាអ៊ីម៉ាំបានលះបង់ចោលនូវលក្ខណៈសង្គម នៃអាជ្ញាធររបស់ព្រះអង្គនោះ ពីព្រោះព្រះអង្គមិនធ្វើចលនាប្រដាប់អាវុធប្រឆាំងនឹងអំណាចគ្រប់គ្រង ម្យ៉ាងទៀតពីព្រោះគេគិតថាស្វីការ "លក្ខណៈសង្គម" មានន័យចង្អៀត មានតែចលនាកាន់អាវុធប៉ុណ្ណោះ ។

យើងមានឯកសារច្រើន ដែលបញ្ជាក់ថាអ៊ីម៉ាំត្រៀមខ្លួនប្រយុទ្ធដោយអាវុធជានិច្ច បើព្រះអង្គជឿជាក់ថាមានមនុស្សចូលរួមក្នុងការប្រយុទ្ធនោះ ហើយជឿជាក់ថាអាចបានសម្រេចគោលដៅអ៊ីស្លាម ដែលបានគ្រោងទុកមុន ដោយសារការប្រយុទ្ធនេះ ។

ពេលគូសលំអានចលនាស៊ីអ៊ុស់ឡើងវិញ យើងបានកត់សម្គាល់ឃើញថាអគ្គប្រមុខស៊ីអ៊ុស់ តំណាងដោយអ៊ីម៉ាំអាស្ស៊់លុល-បៃត៍ យល់ឃើញថាការឡើងកាន់អំណាចមិនគ្រប់គ្រាន់ និងមិនអាចគ្រប់គ្រាន់ទេក្នុងការបំពេញចលនាកែប្រែផ្នែកសាសនាអ៊ីស្លាមឲ្យបានសម្រេច បើអំណាចនេះមិនស្ថិតនៅលើមូលដ្ឋានប្រជារាស្ត្រដែលស្គាល់គោលដៅ (របស់អំណាច) ដែលជឿទ្រឹស្ដីរបស់រដ្ឋាភិបាល ព្រមការពារអំណាចនេះ មានសមត្ថភាពអធិប្បាយបំភ្លឺគោលជំហររបស់អំណាចនេះឲ្យប្រជាពលរដ្ឋយល់ និងមានសមត្ថភាពស៊ូទ្រាំការវីវក់ច្របូកច្របល់គ្រប់បែបយ៉ាង ។

ដូច្នេះហើយបានជា ក្នុងអំឡុងកន្លះសតវត្សដំបូងបន្ទាប់ពីព្រះសាស្ដាបានចូលទិវង្គត ថ្នាក់ដឹកនាំស៊ីអ៊ុស់ខិតខំយកអំណាចមកវិញជានិច្ច - ក្រោយ

# កថាមុខ

អ្នកស្រាវជ្រាវសម័យថ្មីមួយចំនួនខិតខំសិក្សាស៊ីអ៊ុស់ ដោយចាត់ទុកថាវាជាបាតុភូតមួយដែលកើតឡើងដោយចៃដន្យនៅក្នុងសង្គមអ៊ីស្លាម ហើយគិតថាវាជាផ្នែកមួយកកើត ឡើងក្នុងរយៈពេលយ៉ាងយូរនៅក្នុងអ៊ុមម៉ាត់អ៊ីស្លាម (أُمَّة គឺអង្គភាព) ក្រោយពីមានព្រឹត្តិការណ៍និងហេតុការណ៍ពិសេសកើតឡើង ដែលបណ្ដាលឲ្យកកើតមាននូវក្រុមអ្នកប្រាជ្ញផ្នែកសាសនាពិសេសមួយក្រុម នៅក្នុងប៉ែកមួយនៃអង្គភាពដ៏ធំនេះ ប៉ែកមួយនេះរីកចម្រើនឡើងបន្តិចម្ដងៗ ។
បន្ទាប់ពីបានធ្វើការស្មានបែបនេះ អ្នកស្រាវជ្រាវទាំងនេះមិនមូលមតិគ្នាអំពីព្រឹត្តិការណ៍ និងហេតុការណ៍ដែលបណ្ដាលឲ្យបាតុភូតនេះលេចឡើង ហើយបណ្ដាលឲ្យប៉ែក (គឺបក្ស) មួយនៃអង្គភាពនេះកកើតឡើង ។ អ្នកស្រាវជ្រាវខ្លះថា អ៊ាប់ឌុលឡោះហ៍ អ៊ីបនូ សាបាអ៊ ‌(عبد الله بن سبأ) និងសកម្មភាពរបស់លោក ដែលគេហៅថាសកម្មភាពនយោបាយនោះជាដើមហេតុដែលបណ្ដាលឲ្យអ៊ីស្លាមស៊ីអ៊ុស់កកើតឡើង ។ អ្នកស្រាវជ្រាវឯទៀតចាត់ទុកថាបាតុភូតស៊ីអ៊ុស់កើតឡើងក្នុងសម័យខ៍លីហ្វាស់ អ៊ីម៉ាំអ៊ាលី صلوات الله عليه والسلام ហើយកើតឡើងមកពីស្ថានភាពនយោបាយនិងស្ថានភាពសង្គមដែលបណ្ដាលមកពីសម័យនោះឯងនៅលើឆាកព្រឹត្តិការណ៍ ។ ខ្លះទៀតអះអាងថា ស៊ីអ៊ុស់កើតចេញមកពីព្រឹត្តិការណ៍ដែលបានកើតឡើងក្រោយមកហើយទេ ។
ខ្ញុំយល់ឃើញថា ដែលអ្នកស្រាវជ្រាវគិតដោយមិនត្រឹមត្រូវថាស៊ីអ៊ុស់ជាបាតុភូតចៃដន្យនៅក្នុងសង្គមអ៊ីស្លាមនោះ ព្រោះតែអ្នកនិយមស៊ីអ៊ុស់មានចំនួនតិចនៅក្នុងអ៊ុមម៉ាត់អ៊ីស្លាមទាំងមូល កាលសាសនាអ៊ីស្លាមទើបនឹង

កើតឡើងគ្រាដំបូង ។

ហេតុការណ៍នេះបណ្តាលឲ្យមនុស្សជឿថា អ្វីដែលត្រឹមត្រូវស្របច្បាប់ក្នុងសង្គមអ៊ីស្លាមគឺអ៊ីស្លាមមិនមែនស្ទ៊ីអ៊ុស្ទ័ តែអ៊ីស្លាមស្ទ៊ីអ៊ុស្ទ័ជាអញ្ញត្រកម្ម (គឺព្រឹត្តិការដោយឡែក) ជាបាតុភូតចៃដន្យនៅក្នុងសង្គមអ៊ីស្លាមដែលត្រូវស្វែងរកមូលហេតុនៅក្នុងការកើតមានឡើងនូវការប្រឆាំងបង្កាប់ ។

តែមិនសមហេតុផលទេដែលយកភាគច្រើន និងភាគតិចដែលមិនជាក់លាក់នោះជាកត្តាសំខាន់ក្នុងការវែកញែករកការច្បាស់ រវាងអ្វីដែលជាធម្មតានិងអ្វីដែលជាអញ្ញត្រកម្ម (គឺព្រឹត្តិការណ៍ដោយឡែក) រវាងឫសគល់និងអ្វីដែលបែកចេញពីឫសគល់ ។ ពីព្រោះវាជាកំហុសមួយដែលចាត់ទុកអ៊ីស្លាមមិនមែនស្ទ៊ីអ៊ុស្ទ័ជាលទ្ធិដែលសមស្របទៅតាមច្បាប់ ហើយចាត់ទុកអ៊ីស្លាមស្ទ៊ីអ៊ុស្ទ័ជាបាតុភូតចៃដន្យនិងជាប៉ែកប្រឆាំងនោះ ដោយសំអាងលើភាគច្រើនយកតាមតួលេខ ។

ជាញឹកញយ សារសព្វ (សាសនា) ធ្វើឲ្យអ្នកជឿសាសនាប្រឆាំងគ្នារឿងសាសនាតែម្តង ការប្រឆាំងគ្នានេះកើតឡើងមកពីមិនស្របមតិគ្នាអំពីលក្ខណៈរបស់សារសព្វនេះ ហើយប៉ែកទាំងពីរមានចំនួនមិនស្មើគ្នាថែមទាំងអះអាងថារៀងៗខ្លួនបានទទួលសារសព្វពិតឥតក្លែងក្លាយ ហើយថាខ្លួនមានសិទ្ធិជាតំណាងជាងប៉ែកឯទៀត ដោយផ្អែកលើសារសព្វនេះតែម្តង គឺសារសព្វនេះឯងជាមូលហេតុធ្វើឲ្យពួកគេប្រឆាំងគ្នា ។

យើងមិនហ៊ានលើកយកកត្តាចំនួន (គឺចំនួនសមាជិកដែលគាំទ្រគោលលទ្ធិនីមួយៗ) ជាមូលដ្ឋានក្នុងការបង្ហាញទស្សនៈនៃការប្រឆាំងជំនឿក្នុងក្របខណ្ឌសារសព្វអ៊ីស្លាមស្ទ៊ីអ៊ុស្ទ័និងអ៊ីស្លាមមិនមែនស្ទ៊ីអ៊ុស្ទ័ទេ ។

ដូចនេះដែរ មិនត្រូវដាក់បញ្ចូលការកកើតទ្រឹស្តីស្ទ៊ីអ៊ុស្ទ័នៅក្នុងសាសនាអ៊ីស្លាមទៅក្នុងពេលដែលពាក្យថា "ស្ទ៊ីអ៊ុស្ទ័" ឬ "ស្ទ៊ីអ៊ុីត" លេចឮឡើងដោយចង្អុលបង្ហាញទៅលើក្រុមមុស្លីមមួយយ៉ាងច្បាស់នោះទេ ពីព្រោះ



(ឬ អគ្គប្រមុខ ឬ ការដឹកនាំ) របស់អ៊ុលី រីឯការប្រឆាំងខ៊ុលីហ្វាស្ទ័របស់អាប៊ូ បាការនិងចរន្តដែលលើកអំណាចឲ្យទៅអ្នកផ្សេងក្រៅពីអ៊ីម៉ាំអ៊ុលីនោះជាជំនឿរបស់ពួកគេលើលក្ខណៈនយោបាយ នៃអាជ្ញាធររបស់អ៊ុលី ។

ចក្ខុវិស័យចែកជាភាគនៃស្ទ៊ីអ៊ុស្ទ័ផ្នែកសាសនា បែកចេញពីស្ទ៊ីអ៊ុស្ទ័ផ្នែកសង្គមបានលេចឡើងមែន ហើយបានកើតឡើងនៅក្នុងចិត្តរបស់អ្នកនិយមស្ទ៊ីអ៊ុស្ទ័ (ឬស្ទ៊ីអ៊ុីត) ក្នុងពេលដែលអ្នកនោះបានទទួលរងការពិតនិងក្នុងពេលដែលកំសួលភ្លើងស្ទ៊ីអ៊ុស្ទ័ - គឺការជំពាក់ចិត្ត(ចំពោះស្ទ៊ីអ៊ុស្ទ័)ជាពិសេស ទៅលើការដឹកនាំអ៊ីស្លាមស្របច្បាប់ដែលមានមុខនាទីបន្តការលើកស្ទួយអ៊ុមម៉ាត់ក្រោយពីព្រះសាស្តាបានចូលទិវង្គត និងមានមុខនាទីធ្វើប្រតិបត្តិការកែប្រែធំដែលព្រះអង្គចាប់ផ្តើមពីដើមមកហើយនោះ - បានរលត់នៅក្នុងខ្លួនអ្នកនោះ ក្លាយទៅជាលទ្ធិសាមញ្ញដែលគេទុកនៅក្នុងបេះដូងសម្រាប់ស្វែងរកសេចក្តីសង្ឃឹមនិងការលួងចិត្តសម្រាលទុក្ខ ។

ត្រង់នេះ យើងមកប៉ះនឹងអំណះអំណាងមួយដែលថាអ៊ីម៉ាំអាស្ស៊ុលុល-បៃត៍ដែលបានស្នងអ៊ីម៉ាំអាល់-ហ៊ូសែន៍នោះ បានដកខ្លួនចេញពីជីវិតសង្គម លែងអើពើលោកនេះ ។ សូមរំលឹករឿងនេះឡើងវិញជាបឋមថាស្ទ៊ីអ៊ុស្ទ័ ដូចដែលយើងបានដឹងហើយនោះ ជារូបមន្តបញ្ជាក់នូវការជំពាក់ចិត្តទៅលើការបន្តការដឹកនាំសាសនាអ៊ីស្លាម (ដែលព្រះអត្ថបទសាសនាបានតែងតាំង ដូច្នេះវាជាការតែងតាំងឥតខ្ចោះ) ហើយការបន្តនេះមិនមានន័យផ្សេងពីន័យបន្តចលនាកែប្រែ ដែលព្រះសាស្តាបានចាប់ផ្តើមធ្វើពីដើមមកហើយនោះទេ ដើម្បីធ្វើឲ្យការលើកស្ទួយអ៊ុមម៉ាត់ពេញលេញនៅលើមូលដ្ឋានអ៊ីស្លាម ។ ដោយបានថ្លែងរឿងនេះរួចហើយ មិនអាចទៅរួច

ក្នុងឋានៈជាអ្នកស្នងសក្តិសមនឹងបន្តមុខងារ របស់អ្នកកាន់តំណែងមុនៗបីរូប (គឺអាប៊ូ បាកា, អ៊ុម៉ារ, អ៊ុស្មម៉ាន) ជាអគ្គប្រមុខកាន់អំណាច អ៊ីម៉ាំអ៊ុលីបានទទួលនូវការស្មោះស្ម័គ្រពីសំណាក់មុស្លីមយ៉ាងសម្បើម ការស្មោះស្ម័គ្រដែលបាននាំព្រះអង្គទៅដល់ខ៊ុលីហ្វាស្វ បន្ទាប់ពីស្តេចខ៊ុលិហ្វទីបី អ៊ុស្មម៉ាន ត្រូវគេសម្លាប់ ។ តែការស្មោះស្ម័គ្រនេះមិនមានលក្ខណៈស៊្មីអ៊ុស្វផ្នែកសាសនា និងផ្នែកសង្គម-នយោបាយទេ ព្រោះស៊្មីអ៊ុស្វមានន័យថា៖ "ជំនឿលើទ្រឹស្តីយកអ៊ុលីជាអ្នកស្នងព្រះសាស្តាផ្ទាល់ស្របច្បាប់ ខុសពីស្តេចខ៊ុលិហ្វកាន់កាប់អំណាចមុនៗបីរូបនោះ ។" ដូច្នេះវាច្រើនជាងស៊្មីអ៊ុស្វបូរណ៌ (បូរៈណៈ គឺទាំងស្រុង) ពិត គឺស៊្មីអ៊ុស្វផ្នែកសាសនានិងផ្នែកសង្គម-នយោបាយ ។ ដោយហេតុនេះ ទោះបីស៊្មីអ៊ុស្វបូរណ៌ (ស៊្មីអ៊ុស្វបូរៈណៈ) បានលូតឡាស់ឡើងនៅក្នុងក្របខណ្ឌនៃការស្មោះស្ម័គ្រដ៏ធំធេងនេះក៏ដោយ គេមិនអាចចាត់ទុកការស្មោះស្ម័គ្រនេះជាឧទាហរណ៍មួយនៃស៊្មីអ៊ុស្វមិនពេញភាគនោះទេ ។

ម្យ៉ាងទៀត អ៊ីម៉ាំអ៊ុលីទទួលបាននូវការស្មោះស្ម័គ្រផ្នែកសាសនានិងផ្នែកមនោគមវិជ្ជាពីបណ្តាសាវកថ្លៃថ្នូរច្រើនរូបដូចជា សាល់ម៉ាន, អាប៊ូ ស្ងារ៍, អ៊ុំម៉ារ៍ និងច្រើននាក់ទៀត... សម័យ អាប៊ូ បាការនិងអ៊ុម៉ារ ។ តែគ្រានេះទៀត គេមិនអាចហៅការស្មោះស្ម័គ្រនេះថា "ស៊្មីអ៊ុស្វផ្នែកសាសនាដាច់ឡែកពីស៊្មីអ៊ុស្វផ្នែកនយោបាយ" បានទេ ព្រោះការពិត វាគ្រាន់តែបកស្រាយឲ្យឃើញនូវជំនឿរបស់បណ្តាសាវកខាងលើនេះទេ គឺជំនឿដែលអះអាងថាការដឹកនាំព្រះប្រកាសិតផ្នែកសាសនា និងផ្នែកនយោបាយត្រូវបានមកអ៊ីម៉ាំអ៊ុលីភ្លាមក្រោយពីព្រះសាស្តាចូលទិវង្គត ។ ការស្មោះស្ម័គ្រផ្នែកសាសនារបស់បណ្តាសាវកទាំងនេះ ដែលបានអធិប្បាយខាងលើនេះជាការបកស្រាយឲ្យឃើញថា ពួកគេជឿលក្ខណៈមនោគមវិជ្ជានៃអាជ្ញាធរ



ការកកើតរបស់ពាក្យ និងការកកើតរបស់របៀបនិយាយនោះជារឿងមួយ រីឯការកកើតរបស់ សាច់រឿងនិងទ្រឹស្តីដែលពាក្យនោះចង្អុលទៅរកនោះជារឿងផ្សេង ។

ម្យ៉ាងទៀត ដែលយើងមិនដែលបានឃើញមានពាក្យ "ស៊្មីអ៊ុស្វ" នៅក្នុងភាសានិយាយសាមញ្ញកាលព្រះសាស្តាមានព្រះជន្មនៅឡើយ ឬនៅក្នុងសម័យក្រោយព្រះអង្គចូលទិវង្គតនោះមិនមានន័យថា មិនដែលមានទ្រឹស្តីឬការនិយមស៊្មីអ៊ុស្វនោះទេ ។

យើងនឹងបកស្រាយរឿងស៊្មីអ៊ុស្វនិងអ្នកនិយមស៊្មីអ៊ុស្វ ក្នុងគោលគំនិតនេះ ដោយខិតខំឆ្លើយតបសំណួរពីរគឺ៖

១-តើស៊្មីអ៊ុស្វកើតឡើងដូចម្តេច ?

២-តើអ្នកនិយមស៊្មីអ៊ុស្វ (ឬស៊្មីអ៊ុត) លេចឡើងដូចម្តេច ?

# វគ្គ ១ - តើស្ទ៊ីអ៊ុស្ស៊ុំកើតឡើងដូចម្តេច ?

គេអាចនិយាយបានថាស្ទ៊ីអ៊ុស្ស៊ុំកើតឡើង ជាធម្មតាមកពីសាសនាអ៊ីស្លាម និងអនុទស្សទ្រឹស្តី ដែលព្រះប្រកាសិតអ៊ីស្លាមគប្បីអនុចរទៅរកដើម្បីអភិវក្សការរីកចម្រើនយ៉ាងល្អក្រោយពីព្រះសាស្តាបានចូលទិវង្គត ។
គេអាចស្រង់យកទ្រឹស្តីនេះឡើងបានយ៉ាងសមហេតុសមផល ចេញមកពីដំណើរការទៅមុខនៃព្រះប្រកាសិតអ៊ីស្លាម ដែលព្រះសាស្តាបានដឹកនាំដោយផ្ទាល់តែម្តងនោះ អាស្រ័យលើមូលហេតុប្រភេទនៃការកកើតរបស់ព្រះប្រកាសិតនេះ និងអាស្រ័យលើមូលហេតុកាលៈទេសៈដែលព្រះប្រកាសិតនេះឆ្លងកាត់ ។ មែន ព្រះសាស្តាបានទទួលភារកិច្ចដឹកនាំបេសកកម្មបដិវត្ត ហើយបានប្រតិបត្តិការផ្លាស់ប្តូរសង្គមទាំងស្រុង ផ្លាស់ប្តូរបែបបទ ផ្លាស់ប្តូរច្បាប់ និងមនោគតិ ។ ដើម្បីបានសម្រេចកិច្ចប្រតិបត្តិការនេះត្រូវប្រើពេលយូរបំផុត កិច្ចប្រតិបត្តិការនេះចាំបាច់ធ្វើឲ្យមានភាពផ្សេងគ្នាផ្នែកសីលធម៌រវាងយ៉ាហ្ស៊ីលីយ៉ាស៊ុំ (جاهِلِيّة គឺសង្គមមុនសាសនាអ៊ីស្លាម) និងសាសនាអ៊ីស្លាមកាន់តែមានថែមឡើងក្នុងចំណោមភាពខុសគ្នាដែលមានច្រើនស្រាប់ហើយនោះ ។
ព្រះប្រកាសិតអ៊ីស្លាមដែលព្រះសាស្តាបានផ្តើមប្រតិបត្តិការនោះ មានកាតព្វកិច្ចដ៏លំបាកក្នុងការអប់រំមនុស្សយ៉ាស៊ុំលីយ៉ា (គឺមនុស្សបុរាណមុនសាសនាអ៊ីស្លាម) បង្ហាត់មនុស្សនោះតាមសាសនាអ៊ីស្លាម ធ្វើឲ្យមនុស្សនោះមានពន្លឺរស្មីថ្មី ហើយដកយកចេញឲ្យអស់នូវឫសគល់និងស្លាកស្នាមយ៉ាស៊ុំលីយ៉ាបុរាណ ។
ព្រះសាស្តាបានបោះជំហានលោតផ្លោះ ក្នុងរយៈពេលយ៉ាងខ្លី បានយ៉ាងធំមហិមាក្នុងការប្រតិបត្តិការបដិវត្តនេះ ។ សកម្មភាពដែលព្រះសាស្តា



ដោយយល់ឃើញថាចរន្តទីមួយចាស់ជាងចរន្តទីពីរ ហើយក្រោយពីការកាប់សម្លាប់នៅការបាឡាអ៊ុំ (كربلاء) អ៊ីម៉ាំអាល់-ហ៊ូសែន៍ត្រូវសម្លាប់នៅទីនោះ បណ្តាអ៊ីម៉ាំអាស្ស៊ុលុល-បៃត៍ដែលព្រះរាជវង្សអ៊ីម៉ាំអាល់-ហ៊ូសែន៍លែងចាប់អារម្មណ៍លោកនេះ ចោលនយោបាយហើយបានលះបង់ខ្លួនក្នុងការប្រកាសសាសនានិងក្នុងធម្មប្បដិបត្តិសាសនា ។

ក៏ប៉ុន្តែភាពខុសគ្នានេះមិនត្រូវនឹងការពិតទេ ពីព្រោះចាប់តាំងពីដើមកំណើតមកម្ល៉េះ ស្ទ៊ីអ៊ុស្ស៊ុំមិនទេរទៅខាងសាសនាតែម្យ៉ាងឡើយ ។ លើសពីនេះទៀត ស្ទ៊ីអ៊ុស្ស៊ុំបានកើតឡើងដូចដែលយើងបានបរិយាយយ៉ាងច្បាស់លាស់ហើយនោះ ត្រង់កន្លែងយើងធ្វើសេចក្តីរាយការណ៍អំពីកាលៈទេសៈនៃការកកើតរបស់ស្ទ៊ីអ៊ុស្ស៊ុំ - ជាទ្រឹស្តីគាំទ្រការតែងតាំងអ៊ីម៉ាំអ៊ុាលីដើម្បីបន្តការដឹកនាំសហាគមន៍អ៊ីស្លាមផ្នែកសាសនា និងផ្នែកសង្គមពេលអត់ពីព្រះសាស្តា ។

ដូច្នេះមិនអាចញែកលក្ខណៈសាសនា ចេញពីលក្ខណៈសង្គមបានទេ អាស្រ័យលើព្រឹត្តិការណ៍ ដែលបានលើកមកអធិប្បាយខាងលើហើយនោះក្នុងទ្រឹស្តីស្ទ៊ីអ៊ុស្ស៊ុំ ហើយក៏មិនអាចធ្វើការញែកបែបនេះក្នុងអ៊ីស្លាមបានទេដែរ ។ អាចធ្វើការញែកបែបនេះបានក្នុងទ្រឹស្តីស្ទ៊ីអ៊ុស្ស៊ុំទាល់តែបានយកខ្លឹមសារចេញពីខាងក្នុងស្ទ៊ីអ៊ុស្ស៊ុំអស់សិន ពោលគឺ យកគុណសម្បត្តិនៃទ្រឹស្តីដែលផ្តោតទៅរកការអភិរក្សអនាគតរបស់ព្រះប្រកាសិត ពេលអត់ពីព្រះសាស្តា ។ ព្រោះដើម្បីអភិរក្សអនាគតនេះ វិសោធនការអ៊ីស្លាមត្រូវការអាជ្ញាធរសាសនា គឺមនោគមវិជ្ជា និងត្រូវការការដឹកនាំផ្នែកសង្គមនយោបាយ ។

ហើយពួកមុស្លីមចាត់ទុកអាស្ទ៍លុល-បៃត៍ និងអ៊ីម៉ាំអ៊ុលីជាមនុស្សសាមញ្ញ និងជា "បុគ្គលនៅក្រោមការគ្រប់គ្រង" ជាទម្លាប់ ទីបំផុតគេលែងអើពើនឹងមុខនាទី "អាជ្ញាធរជាន់ខ្ពស់ផ្នែកសាសនា" របស់អាស្ទ៍លុល-បៃត៍ ។ តែមុខនាទីនេះមិនអាចនៅទទេបានទេ គេបានប្រគល់មុខនាទីនេះ មិនមែនឲ្យទៅស្ដេចខ៉ិលិហ្វកាន់កាប់អំណាចទេ តែឲ្យទៅបណ្ដាសាវកទូទៅ ។ អាជ្ញាធរសាសនារបស់អាស្ទ៍លុល-បៃត៍លែងសមគួរ អាជ្ញាធរសាសនារបស់បណ្ដាសាវកទូទៅ ដែលបានជួសអាជ្ញាធរសាសនារបស់អាស្ទ៍លុល-បៃត៍នោះ ដូចជាសមគួរជាងព្រោះបណ្ដាសាវកទាំងនេះបាននៅក្បែរព្រះសាស្ដាយ៉ាងយូរ បានរស់នៅជាមួយព្រះអង្គ ស្គាល់បទពិសោធន៍ព្រះអង្គ ដឹងហ្ាឌីស្ទ្រនិងស៊ូណាស្ទ៍ព្រះអង្គ ។

ដូច្នេះឯងដែលអាស្ទ៍លុល-បៃត៍ ស្ទើរតែបានបាត់បង់ឯកសិទ្ធិដែលមកពីអល់ឡោះហ្វ៍ ស្ទើរតែបាត់បង់បឋមភាពដាច់គេផ្នែកសាសនា ហើយត្រូវរឹតត្បិតទៅជាប៉ែកមួយនៃអាជ្ញាធរសាសនា ក្នុងឋានៈជាសាវកសាមញ្ញដូចសាវកឯទៀត ។ ដោយហេតុពួកសាវកផ្ទាល់រងការឈ្លោះប្រកែកគ្នាប្រឆាំងគ្នាខ្លាំង ជួនកាលបណ្ដាលឲ្យប្រយុទ្ធតទល់គ្នា បង្ហូរឈាមគ្នា វាយប្រហារសេចក្ដីថ្លៃថ្នូររបស់គូជម្លោះ ចោទគ្នាទៅវិញទៅមកថាវៀចវេពីមាគ៌ាល្អនិងក្បត់ បានជាកើតមាននូវការជំទាស់ជំនឿនិងមនោគមវិជ្ជានៅក្នុងអ៊ុមម៉ាត្ទ៍ ដូចស្រមោលឆ្លុះនៃការជំទាស់ផ្សេងៗនៅក្នុងអាជ្ញាធរសាសនាតែមួយនោះដែលបានកើតឡើងដោយសារ *អ៊ីច្ទីហ្វាដ្ទ៍ ។*

មុននឹងបញ្ចប់របាយការណ៍ ខ្ញុំសូមទាក់ទាញអារម្មណ៍មកកាន់ចំណុចមួយ សេចក្ដីអធិប្បាយចំណុចនេះមានលក្ខណៈទទៅរកការបំបែកស្ទ៊ីអ៊ុស្ទ៍ជាពីរចរន្តដាច់ឡែកគឺ៖ ស្ទ៊ីអ៊ុស្ទ៍សាសនានិងស្ទ៊ីអ៊ុស្ទ៍នយោបាយ



បានចាប់ផ្ដើមធ្វើនេះ ត្រូវតែដំណើរការតទៅមុខទៀតជាចាំបាច់ ក្រោយពីព្រះអង្គចូលទិវង្គត ។ មុនព្រះអង្គសោយព្រះទិវង្គតបន្តិច ព្រះសាស្ដាបានដឹងខ្លួនថាព្រះអង្គនឹងមិនមានព្រះជន្មបានយូរតទៅទៀតទេ ។ ដូច្នេះព្រះអង្គបានប្រកាសប្រាប់យ៉ាងច្បាស់ជាសាធារណៈ ក្នុងពេលបំពេញពិធីហ្ាច្ចចុងក្រោយបង្អស់ (حَجَّة الوَداع) ។ ដូច្នេះព្រះអង្គបានដឹងពេលព្រះចូលទិវង្គត ។ បានសេចក្ដីថា ទោះជាយើងមិនយកចិត្តទុកដាក់នឹងការបើកឲ្យដឹងព្រះគម្ពីរនិងព្រះទិព្វញ្ញាណ ព្រមទាំងតួនាទីរបស់កត្តាទាំងពីរនេះក្នុងការចង្អុលបង្ហាញផ្លូវរបស់ព្រះសាស្ដា រឿងអនាគតរបស់ព្រះប្រកាសិតអត់ពីព្រះអង្គទៅនោះក៏ដោយ ក៏ព្រះសាស្ដាមានពេលគ្រប់គ្រាន់សម្រាប់គិតគូរអំពីជោគវាសនា (គឺអនាគត) របស់ព្រះប្រកាសិតនេះក្នុងពេលអត់ពីព្រះអង្គ ។
គេអាចកត់សំគាល់បានយ៉ាងសមហេតុផលថា ព្រះសាសនៈទូតប្រឈមមុខនឹងមធ្យោបាយបីដែលព្រះអង្គត្រូវជ្រើសរើសយកមួយ ដើម្បីអនាគតព្រះប្រកាសិត ។

## មធ្យោបាយទី ១

មធ្យោបាយទីមួយដែលលេចឡើងសម្រាប់ព្រះសាស្ដា គឺកាន់ឥរិយាបថអកម្មរឿងអនាគតរបស់ព្រះប្រកាសិត គ្រាន់តែដឹកនាំនិងចង្អុលបង្ហាញផ្លូវរឿងនេះក្នុងពេលព្រះអង្គមានព្រះជន្ម ដោយទុកឲ្យកាលៈទេសៈនិងចៃដន្យគិតគូរអំពីអនាគតព្រះប្រកាសិតនេះ ។
តែគេមិនអាចសន្និដ្ឋានបានឡើយ ថាព្រះសាស្ដាកាន់ឥរិយាបថដូច្នេះពីព្រោះគេដកស្រង់បាននូវសម្មតិកម្មពីរ ដែលមិនសមស្របនឹងគោល

គំនិតរបស់ព្រះសាសនៈទូតគឺ៖

១- គិតថា មិនផ្ដើមធ្វើអ្វីសោះដើម្បីធានាអនាគតព្រះប្រកាសិតនោះនឹងមិនជះលទ្ធផលអាក្រក់ទៅលើអានាគតនោះទេ ហើយអ៊ុមម៉ាត្ដ៍ដែលទទួលព្រះប្រកាសិតនេះជាកេរដំណែលតរៀងមក នឹងមានសមត្ថភាពអភិរក្សព្រះប្រកាសិតនេះបាន ព្រមទាំងអាចធ្វើឲ្យព្រះប្រកាសិតនេះមិនលម្អៀងចេញពីលំនាំដើមបានឡើយ ។

យល់ឃើញបែបនេះ អំពីអនាគតព្រះប្រកាសិតមិនសមស្របនឹងកាលៈទេសៈពិតសម័យនោះទេ ។ កាលៈទេសៈសម័យនោះតឿនឲ្យយល់ឃើញផ្ទុយពីនោះវិញទេ ។ ពីព្រោះ "ព្រះប្រកាសិត" ដែលមានសេចក្ដីថាចលនាកែប្រែខុសប្លែកពីធម្មតា (គឺទាំងស្រុងតែម្ដង)[4] ដែលទើបនឹងកកើតឡើងនោះ ដើម្បីលើកស្ទួយអ៊ុមម៉ាត្ដ៍ (គឺសហគមន៍អ៊ីស្លាម) និងដើម្បីកម្ចាត់ឫសគល់បុរាណយ៉ាហ្ហ៊ីលីយ៉ាស្ុំ (جاهِلِيّة) នោះ នឹងរងគ្រោះថ្នាក់ធ្ងន់គ្រប់ប្រភេទបើអ្នកដឹកនាំព្រះប្រកាសិតនោះ (គឺព្រះសាស្តា) បាត់ព្រះកាយទៅដោយពុំបានរៀបចំជាមុនក្នុងការស្នងព្រះអង្គទេនោះ ។ ដំបូងបង្អស់គឺមានគ្រោះថ្នាក់ដែលកើតឡើងពីស្ថានភាពមួយ ដែលត្រូវគិតថាគេពុំបានគ្រោងអ្វីឡើយសម្រាប់ចន្លោះពេលទំនេរនោះទេ (គឺពេលព្រះសាស្តាចូលទិវង្គតដោយពុំបានគ្រោងអ្វីឡើយ) ហើយត្រូវគិតថានឹងចាំបាច់ត្រូវលៃលកយ៉ាងទាន់ហាន់នៅក្រោមការតក់ស្លុត ដែលកើតឡើងពីព្រះសាស្តាចូលទិវង្គតនោះ ។ ពីព្រោះ បើព្រះសាស្តាបានចាកចោលដោយពុំបានរៀបផែនការសម្រាប់អនាគតព្រះប្រកាសិតទេនោះ ជាចំបងពេលអត់អ្នកដឹកនាំនោះ អ៊ុមម៉ាត្ដ៍ត្រូវទទួលខុសត្រូវការប្រឈមមុខនឹងបញ្ហាលំបាកបំផុត ដែលព្រះប្រកាសិតអាចជួបប្រទះ ពីព្រោះអ៊ុមម៉ាត្ដ៍មិន

[4] យោលតាមកំណត់ហេតុរបស់លោកអ្នកបកប្រែ ។



ស្ដេចខ៍លិហ្វកាន់កាប់អំណាចផងដែរ ពីព្រោះកាតព្វកិច្ចនៃអាជ្ញាធរខាងសាសនាខុសពីកាតព្វកិច្ចនៃការប្រើអំណាច ។ ពិតមែន ទទួលស្គាល់ថាបុគ្គលណាមួយមានសមត្ថភាពកាន់កាប់អំណាច និងដាក់ឲ្យអនុវត្តិច្បាប់នោះមិនមានន័យថា គេព្រមទទួលបុគ្គលនោះជាអ៊ីម៉ាំដឹកនាំសាសនានិងជាអាជ្ញាធរខាងមនោគមវិជ្ជាថ្នាក់ខ្ពស់បំផុតនេះឡើយ (ផ្នែកការចេះដឹងទ្រឹស្ដីសាសនាអ៊ីស្លាម) បន្ទាប់គួរអាននិងស៊្វណាស្ុំព្រះសាស្តា ។ ព្រោះអ៊ីម៉ាម៉ាស្ុំ[64]ខាងសាសនា និងខាងមនោគមវិជ្ជានេះទាមទារឲ្យមានកម្រិតវប្បធម៌ខ្ពស់ មានការចេះដឹងទូទៅនិងយល់ជាក់ទ្រឹស្ដី ។ តែការពិតពុំមានសាវកណាមួយអាចអះអាងបានថាខ្លួនតែម្នាក់ ស័ក្តិសមនឹងឋានៈនេះទេលើកលែងតែអាស្ុំលុល-បៃត៍ ។

ដូច្នេះ ជញ្ជីងអាជ្ញាធរផ្នែកសាសនាយោលទៅមកមួយរយៈ ។ ពួកស្ដេចខ៍លិហ្វនៅតែទាក់ទងជាមួយអុាលីដែលជា "អ៊ីម៉ាំសាសនា"[65] អស់រយៈពេលយូរ ឬស្មើរតែរហូត ។ ស្ដេចខ៍លិហ្វទីពីរ អ៊ុំម៉ារ បាននិយាយសាច្រើនដងថា៖ "គ្មានអុាលី អ៊ុំម៉ារច្បាស់ជាស្លាប់ ។ សូមអល់ឡោះហ្វ៍កុំឲ្យខ្ញុំជួបប្រទះបញ្ហាណាមួយដែលពុំមានអាប៊ូ អាល់-ហ្សាសាន់[66] - អ៊ីម៉ាំអុាលី - (ដើម្បីដោះស្រាយបញ្ហានេះ)[67] ។"

ក្រោយពីព្រះសាស្តាចូលទិវង្គត លុះព្រឹត្តិការណ៍នេះកន្លងទៅជាបណ្ដើរៗ

[64] ត្រង់នេះមានន័យដើមថា៖ មុខ, អ្វីដែលគេដាក់នៅខាងមុខ ខាងក្បាល ។

[65] ពោលគឺ អាជ្ញាធរធរមានជាន់ខ្ពស់បំផុត រឿងច្បាប់អ៊ីស្លាម (កំណត់របស់អ្នកបកប្រែ) ។

[66] អាប៊ូ អាល់-ហ្សាសាន់ គឺឪពុករបស់អាល់-ហ្សាសាន់ គឺអ៊ីម៉ាំអុាលី صلوات الله عليه والسلام ។

[67] កំណត់របស់អ្នកបកប្រែ ។

គម្ពីរទេ ដូចព្រះសាសនៈទូតមានព្រះវចនៈនៅក្នុងហាឌីស្ទខាងលើនេះ ។

រីឯចរន្តទីពីររបស់ពួកមុស្លីម គឺចរន្តដែលទេរទៅរក *អ៊ីច្ទីហ្វាដ្ទ* ជាជាងទេរទៅរក "ធម្មប្បដិបត្តិតាមព្រះអត្ថបទ" ចាប់តាំងពីព្រះសាស្តាបានចូលទិវង្គតទៅ ចរន្តនេះបានសម្រេចផ្ទេរ "អាជ្ញាធរផ្នែកដឹកនាំ" ដែលមានភារកិច្ចអនុវត្តិអំណាចនោះ ឲ្យទៅមនុស្សដែលត្រូវជ្រើសរើសក្នុងចំណោមពួកមូហាឃ្ជីរីន យោលទៅតាមមូលដ្ឋានផ្លាស់ប្តូរ ងាយបត់បែន និងវិបរិណាម (គឺងាយប្រែប្រួល) ។ អាប៊ូ បាការត្រូវបានលើកឲ្យកាន់អំណាចដូចនេះឯង ក្រោយពីព្រះសាសនៈទូតចូលទិវង្គតភ្លាម បន្ទាប់ពីបានធ្វើការពិភាក្សាមានកំហិតនៅក្នុងសភាសាគ្ទីហ្វាស្ទ (السقيفة) ។ ចុងក្រោយអ៊ុស្ទម៉ានបានស្នងអ៊ុម៉ារអាស្រ័យលើមរតកសាសន៍របស់អ៊ុម៉ារ ឲ្យតែងតាំងអ៊ុស្ទម៉ានដោយមិនចំជាអ្នកកាន់ខ៊ីលីហ្វាស្ទ ។ ដូច្នេះការងាយបត់បែនបែបនេះនៅក្នុងច្បាប់ឡើងកាន់ការដឹកនាំអ៊ុមម៉ាត្ទជាផ្លូវការ ប្រមាណសាមសិបបីឆ្នាំក្រោយពីព្រះសាស្តាបានចូលទិវង្គត បណ្តាលឲ្យមានការជ្រាបចូលរបស់ពួក "កូនៗរបស់ពួករួចខ្លួន (ទូឡាក្ទ)" (ឬត្រូវដោះលែង) - ដែលបានប្រយុទ្ធតទល់នឹងអ៊ីស្លាមកាលពីដើម - ទៅក្នុងមណ្ឌលអាជ្ញាធរនានា (គឺជ្រាបចូលទៅក្នុងអំណាច) ។

ដូច្នេះ"អាជ្ញាធរថ្នាក់ដឹកនាំ" (គឺអំណាច, ខ៊ីលីហ្វាស្ទ) អាស្ទលុល-បៃត៍ ត្រូវដកហូតដោយសារ *អ៊ីច្ទីហ្វាដ្ទ ។* ពិបាកទុក "អាជ្ញាធរផ្នែកប្រាជ្ញា" (គឺខាងសាសនា) ឲ្យម្ចាស់ពេញច្បាប់របស់វា (គឺអាស្ទលុល-បៃត៍) ពីព្រោះម្ចាស់ពេញច្បាប់ទាំងនេះនឹងអាចមានលក្ខណ្ឌគោលដៅ ដែលធ្វើឲ្យពួកគេបានទៅដល់អំណាច ដូច្នេះនឹងអាចប្រជុំអាជ្ញាធរទាំងពីរនេះបានជារបស់ខ្លួន ។ តែម្យ៉ាងទៀត ពិបាកប្រគល់អាជ្ញាធរខាងសាសនាឲ្យទៅ



បានប្រុងប្រៀបខ្លួនពើបពះស្ថានការណ៍បែបនេះជាមុនហើយទេ ។ ម្យ៉ាងទៀត ស្ថានការណ៍បែបនេះនឹងទាមទារឲ្យអ៊ុមម៉ាត្ទសម្រេចការយ៉ាងទាន់ហាន់ ឥតបានប្រុងប្រៀបជាមុន ទោះជាបញ្ហាជួបប្រទះនោះធ្ងន់ធ្ងរក្តី ពីព្រោះមិនអាចពន្យារពេលឲ្យចន្លោះពេលទំនេរដែលកើតឡើងនោះ វែងឆ្ងាយបានទេ ។ ដូច្នេះ តើការសម្រេចយ៉ាងទាន់ហាន់បែបនេះមានលទ្ធផលយ៉ាងណា គឺការសម្រេចរបស់អ៊ុមម៉ាត្ទនៅក្រោមការតក់ស្លុតពេលព្រះមគ្គុទេសក៍របស់ខ្លួនបានបាត់បង់ជីវិត ? អ៊ុមម៉ាត្ទបានរងការតក់ស្លុតពេលព្រះសាស្តាចូលទិវង្គត ធ្វើឲ្យអារម្មណ៍រង្គោះរង្គើ រំខានចិត្ត ហើយការតក់ស្លុតនេះបានធ្វើឲ្យសាវក ដែលគេស្គាល់ច្បាស់មួយរូបប្រកាសនៅក្រោមការតក់ស្លុតថា៖ "ទេ ! ព្រះសាស្តាមិនចូលទិវង្គតទេ ព្រះអង្គនឹងមិនចូលទិវង្គតទេ ។"
ម្យ៉ាងទៀត គឺមានគ្រោះថ្នាក់ដែលកើតឡើងពីមូលហេតុដែលអ៊ុមម៉ាត្ទមិនទាន់បានឈានដល់ដំណាក់ការចាស់ចិត្ត ចាស់គំនិតក្នុងជំនឿនៅឡើយ ដើម្បីព្រះសាស្តានឹងបានសម្រេចជាមុនគោលដៅឥរិយាបថ ដែលនឹងត្រូវជ្រើសយកក្រោយពីព្រះអង្គចូលទិវង្គត នឹងបានសម្រេចការសមស្របគ្នារវាងឥរិយាបថនេះនិងក្របខណ្ឌបេសកកម្មនៃព្រះប្រកាសិត នឹងបានសម្រេចសមត្ថភាពយកជ័យជំនះលើបដិវាទកម្ម (គឺការជំទាស់) មិនចេញមុខបាន គឺបដិវាទកម្មដែលជិតជាប់ នៅក្នុងចិត្តពួកមុស្លីមដែលបែងចែកជាក្រុមមូហាឃ្ជីរីន (مهاجرين)[5] អាន់ស្វារ (أنصار)[6] ជាអារ៉ាប់គូរ៉យ៉ស្ទ[7]និងមិន

[5] គឺពួកមុស្លីមដែលបានចាកចេញពីម៉ាក់កាស្ទ ជាមួយព្រះសាស្តាទៅកាន់ម៉ាឌីណាស្ទដើម្បីគេចពីការបៀតបៀនរបស់ពួកអ្នកស្រុកម៉ាក់កាស្ទ ដែលប្រឆាំងសាសនា (គឺពួកកាហ្វៀរ) ។

[6] គឺបក្សពួក ។ គឺពួកអ្នកស្រុកម៉ាឌីណាស្ទដែលជាបក្សពួករបស់ព្រះសាស្តា ។

[7] គូរ៉យ៉ស្ទជាកុលសម្ព័ន្ធរបស់ព្រះសាស្តា ។

មែនគូរ៉យ៉ស្ទ៍ ជាអ្នកស្រុកម៉ាក់កាស្ទ់និងអ្នកស្រុកម៉ាឌីណាស្ទ់ ។ ការពិតបដិវាទកម្មនេះរមែងតែដិតជាប់នៅក្នុងក្រឪបេះដូងជនទាំងនេះ ។
នៅមានគ្រោះថ្នាក់ដែលកើតមកពីពួកចូលសាសនាអ៊ីស្លាមប្រទ្បំ ដែលតែងតែលួចធ្វើផែនការណ៍សម្ងាត់ប្រឆាំងសាសនាអ៊ីស្លាម នៅពេលព្រះសាស្តាមានព្រះជន្មទៅឡើយ ។ ពួកនេះឯងដែលព្រះគម្ពីរគួរអានហៅថា "ពួកលាក់ពុត" ។ បើគេបូកបញ្ចូលជាមួយមនុស្សចំពួកនេះនូវមនុស្សមួយចំនួនធំដែលចូលសាសនាអ៊ីស្លាមក្រោយពីសញ្ជ័យ (គឺក្រោយពីគេច្បាំងឈ្នះ)[8] មិនមែនដោយស្ម័គ្រចិត្តទេតែដោយចុះចាញ់គេនោះ គេអាចស្មានបាននូវគ្រោះថ្នាក់ដែលចំពួកជនទាំងនេះបង្កឲ្យកើតមាន កាលណាពួកគេមានសេរីភាពយ៉ាងទាន់ហាន់ឡើងវិញ ធ្វើអ្វីបានតាមចិត្តក្នុងចន្លោះពេលទំនេរពីអំណាច គ្មានអ្នកដឹកនាំ ។
ស្ថានការណ៍ធ្ងន់ធ្ងរខ្លាំងបំផុត ដែលនឹងអាចកើតមានឡើងបានក្រោយពីព្រះសាស្តាចូលទិវង្គតនោះ មិនអាចចៀសផុតពីការគិតឃើញរបស់មេដឹកនាំណាមួយដែលធ្លាប់បានប្រតិបត្តិបេសកកម្មនោះបានឡើយ ជាពិសេសចៀសផុតពីការគិតឃើញរបស់ព្រះសាស្តាចុងក្រោយបំផុត (គឺព្រះសាស្តាមូហាំម៉ាដ់ﷺ) ។
បើគេព្រមទទួលស្គាល់ថា៖

-អាប៊ូ បាការមិនព្រមចាកចោលឆាកជីវិតទេ (គឺស្លាប់) មុននឹងបានលូកដៃយ៉ាងសកម្មក្នុងការស្នងអំណាច ដើម្បីធានាអនាគត

[8] សាសនាអ៊ីស្លាមច្បាំងឈ្នះយកស្រុកពួកនេះបាន ។ នាដើមសម័យអ៊ីស្លាមមានមុស្លីមពីរចំពួកគឺ៖ ពួកដែលចូលសាសនាអ៊ីស្លាមដោយស្ម័គ្រចិត្តនិងពួកដែលព្រមចូលសាសនាអ៊ីស្លាមព្រោះទឹកដីរបស់ខ្លួនត្រូវគេច្បាំងឈ្នះ ដណ្តើមយកបាន ។



ដូច្នេះព្រះអត្ថបទថ្លៃថ្លាទាំងពីរនេះ ដូចអត្ថបទស្រដៀងនេះឯទៀតដែរចែងអំពី *ម៉ារ៉យ៉ាអ៊ីយ៉ាស្ទ់* (المَرجَعيّة អាជ្ញាធរ) ទាំងពីររបស់អាស្ទ់លុល-បៃត៍ ។ ចរន្តអ៊ីស្លាម "និយមព្រះអត្ថបទព្រះសាស្តា" បានប្រកាន់យកហ្វាឌីស្ទទាំងពីរនេះ អាស្រ័យហេតុនេះ បានជឿ *ម៉ារ៉យ៉ាអ៊ីយ៉ាស្ទ់* ទាំងពីរខាងលើនេះ ។ ចរន្តនេះជាចរន្តរបស់ពួកមុស្លីមដែលកាន់តាមអាស្ទ់លុល-បៃត៍ ។

យើងកត់សម្គាល់ថា "អាជ្ញាធរ (ម៉ារ៉យ៉ាអ៊ីយ៉ាស្ទ់) ផ្នែកកិច្ចដឹកនាំនិងផ្នែកសង្គមកិច្ច" របស់អ៊ីម៉ាំនីមួយៗមានលក្ខណៈមិនអចិន្ត្រៃយ៍ ព្រោះអាជ្ញាធរនេះមានកាលបរិច្ឆេទយោលទៅតាមអាយុកាលរបស់អ៊ីម៉ាំ ហើយអាជ្ញាធរនេះជាការបកស្រាយឲ្យឃើញ នូវការអនុវត្តិន៍អំណាចរបស់អ៊ីម៉ាំក្នុងកាលបរិច្ឆេទនេះ ។ ចំណែកឯ "អាជ្ញាធរប្រាជ្ញា" វិញ វាជាការពិតឥតប្រែប្រួលនិងដាច់ខាតដែលពុំមានកាលបរិច្ឆេទ អាស្រ័យហេតុនេះ វាមានអត្ថន័យប្រតិបត្តិនិងរស់រវើកស្ទួកាលរៀងរហូត ហើយនេះជារឿងធម្មតា ពីព្រោះដរាបណាបាវ (គឺសាសនិកជន) ត្រូវការយល់ដឹងចំណុចជាក់លាក់ណាមួយនៃសាសនាអ៊ីស្លាមនិងការចេះដឹងយោបល់នៃសាសនាអ៊ីស្លាម ត្រូវការចេះដឹង "អនុញ្ញាត" និង "បម្រាម" នៃសាសនាអ៊ីស្លាម ត្រូវការចេះដឹងទស្សនៈនិងគុណសម្បត្តិនៃសាសនាអ៊ីស្លាម ដរាបនោះបាវត្រូវការអាជ្ញាធរ (គឺម៉ារ៉យ៉ាអ៊ីយ៉ាស្ទ់) ដែលអល់ឡោះហ្វ៍បានកំណត់មក ដែលតំណាងដោយ៖

១)- ព្រះគម្ពីររបស់អល់ឡោះហ្វ៍
២)- ស៊ូណាស្ទ់របស់ព្រះសាស្តា និងព្រះរាជកុលដ្ឋាលឥតខ្ចោះអាស្ទ់លុល-បៃត៍(របស់ព្រះសាស្តា) ព្រះរាជកុលដ្ឋាននេះមិនលម្អៀងបែកចេញពីព្រះ

ទទួលខុសត្រូវមួយដែរ ។ តើអស់លោកមានអ្វីថាទេ ?" មនុស្សដែលប្រជុំនៅទីនោះបានថា៖ "អស់ទូលបង្គំធ្វើសាក្សីថាព្រះអង្គបានផ្ទេរ(ព្រះរាជសារ)[62] បានតស៊ូបំពេញព្រះបេសកកម្មសាស្ដាហើយបានណែនាំ ។ សូមអល់ឡោះហ្ទ៍តបស្នងព្រះអង្គយ៉ាងសក្តិសម ។" ព្រះអង្គបានសួរពួកគេថា៖ "តើអស់លោកសូមសច្ចាទេថា ពុំមានព្រះទេក្រៅពីអល់ឡោះហ្ទ៍ មូហ៊ាំម៉ាដ្ទ៍ជាបាវព្រះអង្គនិងជាព្រះសាស្ដាព្រះអង្គ ថាឋានសួគ៌ព្រះអង្គជាការពិត ថាការស្លាប់ជាការពិត ថាការរស់ឡើងវិញក្រោយពីស្លាប់ជាការពិត ថាម៉ោងប្រាកដជាមកដល់ជាមិនខាន កាលនោះអល់ឡោះហ្ទ៍នឹងឲ្យបណ្ដាអ្នកនៅក្នុងផ្នូររស់ឡើងវិញ ?" ពួកគេបានតបថា៖ "អស់ទូលបង្គំសូមសច្ចា ។" ព្រះអង្គមានព្រះវចនៈថា៖ "អល់ឡោះហ្ទ៍អើយ សូមព្រះអង្គជាសាក្សីរឿងនេះ ។" ព្រះអង្គបានបន្ថែមថា៖ "ប្រជារាស្ត្រអើយ អល់ឡោះហ្ទ៍ជាម្ចាស់របស់ខ្ញុំ ខ្ញុំជាម្ចាស់របស់បណ្ដាអ្នកមានសទ្ធា ខ្ញុំទទួលខុសត្រូវពួកគេលើសពួកគេទទួលខុសត្រូវខ្លួនឯងទៅទៀត ។ អ្នកណាក៏ដោយដែលមានខ្ញុំជាម្ចាស់ ម្នាក់នេះ (ពោលគឺ អ៊ាលី) ជាម្ចាស់របស់អ្នកនោះ ។ អល់ឡោះហ្ទ៍អើយ សូមព្រះអង្គគាំទ្រអ្នកណាដែលគាំទ្រគេ សូមព្រះអង្គជាសត្រូវរបស់បុគ្គលណាដែលជាសត្រូវរបស់គេ ។"[63]

[62] កំណត់របស់អ្នកបកប្រែ ។

[63] ហ្គាឌីស្ទ អាល់-ក៏ដៀរត្រូវបានលើកយកមកអធិប្បាយទាំងក្នុងសៀវភៅពួកស៊ូនិត ទាំងក្នុងសៀវភៅពួកស្ទីអ៊ីត ។ អ្នកស្រាវជ្រាវឯកទេសរឿងនេះមួយចំនួនបានធ្វើបញ្ជីអ្នកធ្វើសេចក្ដីរាយការណ៍ហ្គាឌីស្ទនេះដូចតទៅ៖

-សាវកជាង ១០០ នាក់ ។

-អ្នកតាមបណ្ដាសាវករបស់ព្រះសាស្ដាជាង ៨០ នាក់ ។

-អ្នកចងចាំរត់មាត់(ហ្គាឌីស្ទនេះ)និងអ្នកឯកទេសហ្គាឌីស្ទនេះ ក្នុងសតវត្សទី ២ នៃសករាជហ្ទ៍ជ្រ៉ះត៏ ប្រមាណ ៦០ នាក់ ។



ខ៏លិហ្វាស្ទ៍ដោយយកលេសថាដើម្បីបង្ការ (គឺប្រុងប្រយ័ត) ។

-ពួកមុស្លីមបានរត់ទៅរកអ៊ុម៉ារ កាលគាត់មានរបួស ដោយទទូចសូមគាត់ថា៖ "សូមលោកឲ្យសន្យាយើង[9] (មានន័យថាជ្រើសរើសអ្នកស្នង)" ព្រោះតែខ្លាចមានចន្លោះទំនេរ គ្មានអ្នកដឹកនាំក្រោយពីគាត់ស្លាប់នោះ ហើយកាលនោះអ៊ុមម៉ាត្ទ៍ចាប់ផ្ដើមមានលក្ខណៈចាស់នយោបាយ ចាស់សង្គម (បានសេចក្ដីថា នយោបាយនិងសង្គមមានលក្ខណៈរឹងប៉ឹងបន្តិចហើយ) ដប់ឆ្នាំក្រោយពីព្រះសាស្ដាបានចូលទិវង្គត ហើយអ៊ុម៉ារដែលបារម្ភដូចពួកមុស្លីមនោះដែរនោះក៏បានជ្រើសរើសបុគ្គលប្រាំមួយនាក់ ដែលអាចជាអ្នកស្នងបាន ។

-អ៊ុម៉ារដឹងច្បាស់អំពីស្ថានការណ៍ធ្ងន់ធ្ងរថ្ងៃសាគីហ្វាស្ទ៍ (السقيفة)[10] ហើយដឹងច្បាស់អំពីបញ្ហាស្មុគស្មាញដែលអាចនឹងកើតឡើង បើគេជ្រើសរើសយ៉ាងប្រថុចញ៉ុច អាប៊ូ បាការ ឡើងកាន់ខ៏លីហ្វាស្ទ៍ ពីព្រោះអ៊ុម៉ារបានថ្លែងអំពីរឿងនេះថា៖ "នេះគឺកំហុសមួយ អល់ឡោះហ្ទ៍عز وجلបានធ្វើឲ្យយើងចៀសផុតពីលទ្ធផលអាក្រក់ ដែលកើតពីកំហុសនេះ"[11] ហើយពីព្រោះ អាប៊ូ បាការ ផ្ទាល់បានឆ្លើយដោះសារកាលដែលខ្លួនបានទទួល យ៉ាងរហ័ស អំណាចនិងការ

[9] តារិក្ហ អាល់-ត៏បារី (تاريخ الطبري), 5/26

[10] ថ្ងៃដែលពួកមុស្លីមបានប្រជុំគ្នានៅក្នុងជំរំសំពត់ (សាគីហ្វាស្ទ៍) របស់ពួកបានី-សាអ៊ីដាស្ទ៍ (بني ساعدة) ដើម្បីតែងតាំងអ្នកស្នងព្រះសាស្ដា ។

[11] តារិក្ហ អាល់-ត៏បារី (تاريخ الطبري), 3/20

ស្នងព្រះសាស្ដា ដែលជាភារកិច្ចមួយធំបំផុតនោះ ដោយអះអាងថានេះព្រោះតែស្ថានការណ៍ដុនដាបពេក (គឺស្ថានការណ៍ដែលកើតឡើង ក្រោយពីព្រះសាស្ដាបានចូលទិវង្គត) ចាំបាច់តម្រូវឲ្យលោករកមធ្យោបាយ ដោះស្រាយរឿងនេះយ៉ាងឆាប់រហ័សបំផុត ដោយថ្លែង (ពេលគេស្ដីបន្ទោសលោកថាព្រមទទួលអំណាចយ៉ាងលឿននោះ) ថា៖ "ព្រះសាសនៈទូតរបស់អល់ឡោះហ្ទ៍ عز وجل បានចូលទិវង្គត ក្នុងពេលដែលសាសនិកជនមិនទាន់បានភ្លេចបុរាណភាពអស់នៅឡើយ (យ៉ាហ្ហ៊ីលីយ៉ាស្ទ៍ ។ គឺមិនទាន់អស់កម្អែលសាសនាដើមនៅឡើយ) ។ ដូច្នេះឯងបានជាមិត្តខ្ញុំបានជ្រើសរើសខ្ញុំជាអ្នកទទួលភារកិច្ចនេះ ។"[12]

បើរឿងទាំងប៉ុន្មានខនេះជារឿងពិតមែននោះ បុគ្គលអ្នកធ្វើមុនគេហើយដែលជាព្រះសាស្ដារបស់ព្រះប្រកាសិតនោះ ប្រាកដជាដឹងជាងគេបំផុតអំពីសាសនាអ៊ីស្លាមក្រោយពីព្រះអង្គចូលទិវង្គត ហើយព្រះអង្គយល់ច្បាស់ជាងគេបំផុតនូវប្រភេទស្ថានការណ៍ និងការទាមទារឲ្យប្រតិបត្តិចលនាកែប្រែខុសប្លែកពីធម្មតា ដែលព្រះអង្គអនុវត្តិលើអ៊ុមម៉ាត្ទ៍ដែលទើបតែនឹងបានចាកចោលបុរាណភាពថ្មីៗ (គឺសាសនាចាស់ យ៉ាហ្ហ៊ីលីយ៉ាស្ទ៍) យោលតាមសម្ដីរបស់អាប៊ូ បាការ ។

២- សម្មតិកម្មមិនសមហេតុផលទីពីរ (គឺការសន្និដ្ឋាន) ដែលបញ្ជាក់ថាព្រះសាស្ដាមិនអើពើអំពីជោគវាសនា និងអនាគតរបស់ព្រះប្រកាសិតក្រោយ

[12] ស្វារហ្ទ៍ ណាស្ទ៍យ្ទ៍ អាល់-បាឡាកោះត្ទ៍ (شرح نهج البلاغة សេចក្ដីអធិប្បាយ ណាស្ទ៍យ្ទ៍ អាល់-បាឡាកោះត្ទ៍), អ៊ីបនូ ហាឌីដូ (إبن أبي الحديد), 6/42



នេះ[56] ។ ដូច្នេះខ្ញុំ صلى الله عليه وآله وسلم ទុកឲ្យអស់លោកនូវ *ស្សាក៏លែន៍* (គឺបន្ទុកធ្ងន់ពីរ)[57] គឺ៖ ព្រះគម្ពីរអល់ឡោះហ្ទ៍ عز وجل ដែលជាខ្សែវែងរវាងមេឃនិងដី និងក្រុមគ្រួសារខ្ញុំ صلى الله عليه وآله وسلم (គឺព្រះរាជកុលដ្ឋាន عليهم السلام) ។ ព្រះដ៏មហាស្លូត عز وجل[58] ព្រះដ៏ទ្រង់សវនាការ عز وجل[59] បានប្រាប់ខ្ញុំ صلى الله عليه وآله وسلم ថាពួកគេទាំងនេះ عليهم السلام នឹងមិនបែកគ្នាទេលុះបានត្រឡប់មកជួបខ្ញុំ صلى الله عليه وآله وسلم វិញនៅឯបឹង[60] ។ ដូច្នេះចូរអស់លោកប្រុងប្រយ័តខ្លួនក្នុងការប្រព្រឹត្តចំពោះពួកគេ عليهم السلام[61] ។"

រីឯព្រះអត្ថបទព្រះសាស្ដាដែលជាឧទាហរណ៍គំរូពាក់ព័ន្ធនឹង "អាជ្ញាធរ" របស់អាស្ទ៍លុល-បៃត៍ រឿងកិច្ចដឹកនាំនិងសង្គមកិច្ចនោះ គឺហាឌីស្ទ៍ អាល់-ក៏ដៀរ (حديث الغدير) ដែលអាល់-ត៍បារី (الطبري) បានធ្វើសេចក្ដីរាយការណ៍យោងតាមបណ្ដាញព័ត៌មានដែលគេទទួលស្គាល់ថាពិតជាឯកច្ឆន្ទ ដែលឡើងទៅដល់ស្សៃដ៍ អ៊ីបនូ អារកាំ (زيد بن أرقم) យោងតាមហាឌីស្ទ៍នេះ ព្រះសាស្ដាមានព្រះវចនៈចំពោះបណ្ដាមុស្លីមថា៖
"ប្រជារាស្ត្រអើយ ខ្ញុំជិតដល់ពេលគេហៅត្រឡប់វិញ ហើយខ្ញុំត្រូវតែឆ្លើយតបការហៅនេះ ។ ខ្ញុំមានការទទួលខុសត្រូវមួយ អស់លោក៏មានការ

[56] ត្រូវហៅត្រឡប់វិញដោយអល់ឡោះហ្ទ៍ عز وجل ពោលគឺ ចូលទិវង្គត ។
[57] កំណត់របស់អ្នកប្រែ ។
[58] ព្រះគុណសម្បត្តិរបស់អល់ឡោះហ្ទ៍ عز وجل ។
[59] ព្រះគុណសម្បត្តិរបស់អល់ឡោះហ្ទ៍ عز وجل ។
[60] ពោលគឺ ថ្ងៃជំនុំជម្រះ ។
[61] បណ្ដាសាវកប្រមាណម្ភៃនាក់បានធ្វើសេចក្ដីរាយការណ៍ហាឌីស្ទ៍នេះ ។ អាល់-ហាគីមបានថ្លែងនៅក្នុងក្រាំងលោក "អាល់-មុសតាដ្រ៉ក់ អ៊ុឡា អាល់-ស្វ៍ហ៊ីហៃន៍ (المستدرك على الصحيحين)" ព្រមទាំងអាល់-តៀរមីស៊ី (الترمذي), អាល់-នីសាអ៊ី (النسائي), អាស្ទ៍ម៉ាដ៍ អ៊ីបនូ ហាន់បាល់ (أحمد بن حنبل) និងច្រើននាក់ទៀត ។

ពីរគំរូ) គឺ៖ អាជ្ញាធរផ្នែកប្រាជ្ញា (គឺអាជ្ញាធរផ្នែកគំនិត) និងអាជ្ញាធរដឹកនាំ (គឺអាជ្ញាផ្នែកកិច្ចដឹកនាំនិងផ្នែកសង្គមកិច្ច) ។ ព្រះសាស្ដាជាតំណាងអាជ្ញាធរទាំងពីរនេះ ។ ចៀសមិនផុតទេ ព្រះអង្គត្រូវតែយកចិត្តទុកដាក់នឹងកាលៈទេសៈបង្កើតវិសោធនការ ដោយហេតុនេះព្រះអង្គត្រូវរៀបចំខ្លួនអ្នកស្នងបរិសុទ្ធដែលអាចគ្រប់គ្រងអាជ្ញាធរទាំងពីរនេះបាន ដើម្បីនឹងឲ្យអ្នកស្នងរូបនេះ ដែលជាអាជ្ញាធរផ្នែកប្រាជ្ញានោះអាចបំពេញចន្លោះទទេដែលអាចកើតមានឡើងនៅក្នុងអារម្មណ៍ពួកមុស្លីមបាន អាចបង្ហាញទស្សនៈអ៊ីស្លាមសមរម្យ និងយោបល់អ៊ីស្លាមពាក់ព័ន្ធនឹងស្ថានភាពថ្មីបាន អាចពន្យល់បំភ្លឺបាន នូវប៉ែកស្រពិចស្រពិលនៃព្រះគម្ពីរដែលជាអាជ្ញាធរប្រាជ្ញាទីមួយនៃសាសនាអ៊ីស្លាមនោះ និងដើម្បីនឹងអ្នកស្នងរូបនេះ ក្នុងឋានៈជាអាជ្ញាធរដឹកនាំនិងផ្នែកសង្គម បន្តការគ្រប់គ្រងវិសោធនការអ៊ីស្លាមលើខ្សែបន្ទាត់សង្គម ។

លុះពិនិត្យមើលដំណើរហេតុ និងឧប្បត្តិហេតុដែលកើតឡើងក្នុងវិសោធនការអ៊ីស្លាម គេអាចឃើញថាមានតែអាស្ហ៍លុល-បៃត៍ទេដែលមានគុណសម្បត្តិគ្រប់គ្រាន់ជាតំណាងអាជ្ញាធរទាំងពីរនេះ ។ មានព្រះអត្ថបទព្រះសាស្ដាអះអាងបន្ថែមពីលើការពិតនេះឥតខ្ចះ ។

ព្រះអត្ថបទព្រះសាស្ដាសំខាន់បំផុត ដែលអះអាងបន្ថែមសាឡើងវិញថាអាជ្ញាធរផ្នែកប្រាជ្ញានៃព្រះប្រកាសិត ជាកម្មសិទ្ធិរបស់អាស្ហ៍លុល-បៃត៍ពេលអត់ពីព្រះសាសនៈទូតនោះគឺហាឌីស្ហ៍អាល់-ស្ហាក៏ឡៃន៍(حديث الثقلين) ។ នៅក្នុងព្រះសុន្នរកថាល្បីមួយ ព្រះសាស្ដាصلى الله عليه وآله وسلمមានព្រះវចនៈមែនថា៖ "ខ្ញុំصلى الله عليه وآله وسلمជិតដល់ពេលគេហៅត្រឡប់វិញ ហើយខ្ញុំត្រូវតែឆ្លើយតបការហៅ



ពីព្រះអង្គចូលទិវង្គតទេនោះ គឺគិតថាទោះបីព្រះអង្គដឹងថាការមិនអើពើនេះបណ្ដាលឲ្យមានគ្រោះថ្នាក់ក៏ដោយ ក៏ព្រះអង្គមិនបានធ្វើអ្វីមួយដើម្បីការពារព្រះប្រកាសិតពីគ្រោះថ្នាក់ទេ នេះព្រោះតែព្រះអង្គឃើញតែផលប្រយោជន៍ខ្លួនឯងក្នុងព្រះប្រកាសិតនេះ ព្រះអង្គគ្រាន់តែការពារព្រះប្រកាសិតនេះពេលព្រះអង្គនៅមានព្រះជន្មតែប៉ុណ្ណោះ ដើម្បីទាញយកកម្រៃនិងផលប្រយោជន៍ផ្ទាល់ខ្លួន មិនគិតដល់ការគង់នៅរបស់ព្រះប្រកាសិតក្រោយពីព្រះអង្គចូលទិវង្គតនោះទេ ។
នេះគឺសម្មតិកម្មដែលលើសពីឆ្កួតលីលាទៅទៀត ទោះបីគេដកហូតពីព្រះសាស្ដានូវគុណសម្បត្តិសាសនៈទូតរបស់អល់ឡោះហ្វ៍عز وجل ហើយគេភ្លេចគិតថាព្រះអង្គមានទំនាក់ទំនងជានិច្ចជាមួយអល់ឡោះហ្វ៍عز وجل ក្នុងរឿងព្រះរាជសារនោះក៏ដោយ ទោះបីយើងចាត់ទុកព្រះអង្គត្រឹមតែជាមេដឹកនាំផ្សាយសាសនា ដូចមេដឹកនាំផ្សាយដំណឹងឯទៀតក៏ដោយ មិនអាចយកសម្មតិកម្មបែបនេះមកអនុវត្តិលើព្រះអង្គបានទេ ដែលជាព្រះអគ្គប្រមុខដឹកនាំព្រះសាសនា ឥតប្រៀបផ្ទឹមបានដែលបានបង្ហាញឲ្យឃើញថាព្រះអង្គបានបូជាព្រះកាយចំពោះព្រះប្រកាសិត ដែលស្មោះស្ម័គ្រអស់ពីចិត្តថ្លើម ដែលលះបង់ខ្លួនដើម្បីព្រះប្រកាសិតនេះ លុះគ្រាអវសាននៃព្រះជន្មព្រះអង្គ ។

ព្រះជីវប្រវត្តិរបស់ព្រះអង្គជាភ័ស្តុតាងបញ្ជាក់រឿងនេះ ។ ទោះបីពេលព្រះអង្គជិតចូលទិវង្គត ហើយអាការជម្ងឺព្រះអង្គកាន់តែដុនដាបខ្លាំងឡើងក៏ដោយ ក៏ព្រះអង្គនៅតែខ្វល់ខ្វាយអំពីចម្បាំងដែលព្រះអង្គបានចាត់ចែងផែនការណ៍ ហើយបានរៀបចំទ័ពរបស់អ៊ូសាម៉ាស្ហ៍ (أسامة) សម្រាប់ចម្បាំងនេះ ។ ព្រះអង្គចេញបញ្ជាការពីលើគ្រែជម្ងឺឥតដាច់ លាយឡំនឹងអាការសន្លប់បាត់ស្មារតីជាញយផង ថា៖ "ចូររៀបចំទ័ពរបស់អ៊ូសាម៉ាស្ហ៍! ចូរឲ្យ

ទ័ពប្រុងខ្លួនចេញច្បាំង..."[13]

ទោះជាគេបានឃើញហើយនោះថា ព្រះអង្គខ្វល់ខ្វាយអំពីវិស័យយោធានៃព្រះប្រកាសិត ថ្វីបើព្រះអង្គកំពុងតែព្រះប្រឈួនជិតចូលទិវង្គត ជាពិសេសព្រះអង្គដឹងខ្លួន ថាព្រះអង្គនឹងចូលទិវង្គតមុនបានទទួលលទ្ធផលចម្បាំងនេះក៏ដោយ តើស័ក្កិសមដែរឬទេដែលគិតថាព្រះអង្គមិនយកចិត្តទុកដាក់នឹងអនាគតរបស់សាសនាអ៊ីស្លាម ហើយមិនបានរៀបចំផែនការណ៍ណាមួយទេ ដើម្បីការពារកុំឲ្យគ្រោះថ្នាក់មកបៀតបៀនព្រះប្រកាសិតនោះបាន ក្រោយពីព្រះអង្គបានចូលទិវង្គត ?

ទីបញ្ចប់ ព្រឹត្តិការណ៍មួយដែលបានកើតឡើងកាលព្រះសាសនៈទូតទ្រង់ប្រឈួនពេលចុងក្រោយនោះ ជាភ័ស្តុតាងគ្រប់គ្រាន់ណាស់សម្រាប់បញ្ជាក់ថាព្រះអង្គមិនបានជ្រើសរើសយកមធ្យោបាយដំបូងនេះទេ ហើយព្រះអង្គមិនបានជ្រើសយកឥរិយាបថអកម្ម រឿងអនាគតព្រះប្រកាសិតឡើយ ព្រះអង្គមិនមែនមិនដឹងគ្រោះថ្នាក់ដែលបណ្ដាលមកពីឥរិយាបថបែបនេះទេ ឬមិនយកចិត្តទុកដាក់អំពីព្រះរាជសារនោះឡើយ ។ ព្រឹត្តិការណ៍នេះ ស្ហ៊ីហ្ហាស្ហ់ (الصحاح)[14] (គឺតម្រាជំនាញខាងចំឡងហ្ហាឌីស្ហពិត) ទាំងអស់របស់ពួកមុស្លីមស៊្ហូណាស្ទ់និងស៊្ហីអុ្ទាស្ទ់បានឲ្យដឹង ថា៖ "ស្ដីអំពីសម្ដីរបស់ព្រះសាស្ដាកាលព្រះអង្គជិតចូលទិវង្គត នៅចំពោះមុខសាក្សីច្រើននាក់ ដូចជា អ៊ុម៉ារ អ៊ីបនូ អាល់-ខ្ហត់ត្ហប់ ជាដើម ថា៖ "ចូរយក

---

[13] តារិក្ហ អាល់-កាមីល (الكامل في التاريخ), អ៊ីបនូ អាស្សៀរ (ابن الاثير) និងច្រើននាក់ទៀត ។

[14] សម្ដីរបស់ព្រះសាស្ដា ។



កម្រិតណា) ។ ចាប់ពីត្រង់នេះមក យើងអាចអះអាងបានថា ក្នុងករណីវិសោធនការអ៊ីស្លាម ចរន្ត "ធម្មប្បដិបត្តិតាមព្រះអត្ថបទ" តំណាងកម្រិតខ្ពស់នៃការជឿនិងការចុះចូលស៊ប់ចិត្តចំពោះព្រះរាជសារ ដោយមិនបដិសេធ *អ៊ីច្ហទីហ្ហាដ្ទ់* បើ *អ៊ីច្ហទីហ្ហាដ្ទ់* នេះត្រូវធ្វើឡើងនៅក្នុងក្របខណ្ឌព្រះអត្ថបទ និងមិនប្រើមតិខ្លួនឯងនោះទេដើម្បីស្រង់ឡើងនូវវិចារណ៍ផ្អែកច្បាប់ពីព្រះអត្ថបទនេះ ។ សំខាន់ ត្រូវដឹងថាធម្មប្បដិបត្តិតាមព្រះអត្ថបទមិនមានន័យថារឹងត្អឹងនិងតឹងតែងនោះទេ ពីព្រោះវាប្រឆាំងនឹងតម្រូវការឲ្យវិវដ្តនិងប្រឆាំងនឹងកត្តាធ្វើឲ្យលូតលាស់ឡើងក្នុងជីវិតមនុស្ស ។ ព្រោះយើងបានឃើញហើយថា "ធម្មប្បដិបត្តិតាមព្រះអត្ថបទ" មានន័យថាស្មោះត្រង់ចំពោះសាសនានិងព្រមទទួលសាសនាទាំងស្រុង មិនមែនតែមួយចំណែកនោះទេ តែនៅក្នុងសាសនានេះមានគ្រប់កត្តានៃការបត់បែនងាករេបាន និងមានសមត្ថភាពសម្រួលទៅតាមការផ្លាស់ប្ដូរនៃកាលៈទេសៈ ព្រមទាំងទៅតាមការលូតលាស់គ្រប់ប្រភេទនិងតាមការវិវត្តន៍ដែលកើតមាននៅក្នុងការផ្លាស់ប្ដូរទាំងនេះ ។ ដោយហេតុនេះ គឺស្មោះត្រង់ចំពោះប្រការទាំងនេះនិងចំពោះអ្វីៗ ដែលជាគំនិតបង្កបង្កើតការច្នៃប្រឌិតនិងការផ្លាស់ប្ដូរថ្មី ។

ទាំងនេះគឺខ្សែបន្ទាត់សរុបនៃការបកស្រាយអំពីស៊្ហីអុ្ទាស្ទ់ ដែលជាបាតុភូតមានមកពីកំណើត ដែលកើតឡើងក្នុងក្របខណ្ឌនៃព្រះប្រកាសិតអ៊ីស្លាម និងនៃការអធិប្បាយបំភ្លឺការលេចឡើងរបស់ពួកស៊្ហីអុ្ទាស្ទ់ (ឬស៊្ហីអ៊ុត) បណ្ដាលមកពីបាតុភូតមានមកពីកំណើតនេះឯង ។

អ៊ីម៉ាម៉ាស្ទ់របស់អាស្ហ់លុល-បៃត៍ (និងរបស់អ៊ីមុាំអុ្ទាលី) ដែលតំណាងដោយបាតុភូតមានមកពីកំណើតនេះ បកស្រាយឲ្យឃើញពីរអាជ្ញាធរ (គឺ

"ចាំបាច់ត្រូវប្រើដោយមានលក្ខខណ្ឌ"[54]នោះគឺ *អ៊ីច្ថទីហ្វាដ្ធ* ក្នុងការទាញយកនូវវិចារណ៍ចេញមកពីព្រះអត្ថបទសាសនា ពុំមែន *អ៊ីច្ថទីហ្វាដ្ធ* ក្នុងការបដិសេធព្រះអត្ថបទ ពេលដែលមុច្ថតាហ្វ៊ីដ្ធ (គឺអ្នកដែលអារកាត់ដោយខ្លួនឯង) គិតថាចាំបាច់ ឬស្មានថាវាមានប្រយោជន៍នោះទេ ។ *អ៊ីច្ថទីហ្វាដ្ធ* បែបនេះមិនអនុញ្ញាតឲ្យប្រើទេ ។ ចរន្តស្ទីអុស្វបដិសេធការប្រើ *អ៊ីច្ថទីហ្វាដ្ធ* ក្នុងន័យនេះ ។ ដែលយើងនិយាយអំពីចរន្តគំនិតពីរដែលបានលេចឡើងក្នុងដើមសម័យអ៊ីស្លាម ចរន្តគំនិតមួយទាក់ទាញទៅរក "ធម្មប្បដិបត្តិតាមព្រះអត្ថបទ" រីឯចរន្តគំនិតមួយទៀតនិយម *អ៊ីច្ថទីហ្វាដ្ធ*។ ត្រង់នេះ យើងចង់មានន័យថា *អ៊ីច្ថទីហ្វាដ្ធ* ក្នុងការព្រមទទួល ឬក្នុងការបដិសេធព្រះអត្ថបទ (ពោលគឺ មុច្ថតាហ្វ៊ីដ្ធអារកាត់ដោយខ្លួនឯងថាសមរម្យ ឬមិនសមរម្យក្នុងការដាក់ឲ្យប្រើព្រះអត្ថបទព្រះអត្ថបទ ក្នុងកាលៈទេសៈនីមួយ)[55] ។

ការប្រើចរន្តគំនិតទាំងពីរនេះជាការធម្មតា នៅក្នុងសារបដិវត្តន៍ទូទៅដែលមានគោលដៅផ្លាស់ប្តូរការពិតទុរាចារ (គឺការពិតដែលត្រូវកាឡៃ) ចាប់ពីឫសគល់ឡើងទៅ ។ ពីព្រោះសារប្រភេទនេះជះឥទ្ធិពលដែលមានកម្រិតប្រែប្រួលយោលទៅតាមទំហំសំណល់ចាស់ ដែលសល់មកពីអតីតកាល និងយោលទៅតាមកម្រិតជំនឿ និងការចុះចូលរបស់បុគ្គលចំពោះសារថ្មីនេះ (ពោលគឺ តើមនុស្សថ្មីជឿនិងព្រមចុះចូលខ្លួនចំពោះសារថ្មីនេះដល់

[54] الواجب الكفائي ឬ ការចាំបាច់ដោយមានលក្ខខណ្ឌ គឺការចាំបាច់ដែលបង្ខំពេលណាមានតម្រូវការចៀសមិនបាន តែពេលណាលែងមានតម្រូវការចៀសមិនបាននេះហើយ ពេលនោះលែងមានការចាំបាច់ដោយមានលក្ខខណ្ឌនេះ ។

[55] កំណត់របស់អ្នកប្រែ ។



ស្នា (គឺបន្ទះ) និងទឹកខ្មៅមកឲ្យខ្ញុំ ដើម្បីខ្ញុំនឹងសរសេរលិខិតមួយ (គឺមរតកសាសន៍) ។ អាស្រ័យលិខិតនេះអស់លោកនឹងមិនវង្វេងទេ ។"[15]

ទង្វើបែបនេះរបស់ព្រះអគ្គមគ្គទេសក៍ ដែលអស់មុស្លីមដឹងច្បាស់ថាជាសច្ចការីនោះ សឲ្យឃើញយ៉ាងប្រចក្សថាព្រះសាស្តាគិតដល់គ្រោះថ្នាក់គំរាមអនាគត ហើយព្រះអង្គដឹងច្បាស់យ៉ាងជ្រាលជ្រៅអំពីការចាំបាច់ត្រូវថែរក្សាអ៊ុមម៉ាត្ថ់ពីវិមគ្គកម្ម ត្រូវការពារព្រះប្រកាសិតពីការភ្លាំងភ្លាត់និងការដួលរលំដែលអាចកើតឡើងបាននាថ្ងៃមុខ ។ ដូច្នេះគេមិនអាចគិតបានជាដាច់ខាតទេ ថាព្រះសាស្តាជ្រើសយកនូវឥរិយាបថអកម្មរឿងអនាគតព្រះប្រកាសិតនោះ ។

# មធ្យោបាយទី ២

មធ្យោបាយទីពីរ ដែលព្រះសាស្តាអាចជ្រើសយកដើម្បីអនាគតព្រះប្រកាសិត គឺរើសយកឥរិយាបថសកម្ម[16] និងរៀបចំផែនការណ៍ស្នងព្រះអង្គ ដែលស្ថិតនៅលើការផ្ទេរអភិបាលភាពនៃព្រះប្រកាសិតនិងការដឹកនាំព្រះវិសោធនការឲ្យទៅអ៊ុមម៉ាត្ថ់តែម្តង ។ តំណាងអ៊ុមម៉ាត្ថ់នេះនឹងប្រព្រឹត្តិទៅតាមប្រព័ន្ធស៊្ហូរ៉ (គឺការពិភាក្សាគ្នា شورى) ។ បុគ្គលដែលនឹងទៅជា

[15] មុសណាដ្ធ៍ អាស្ម៉ាដ្ធ៍ (مسند أحمد), 1/300 ។ ស្ហ៊ហ៊ិះហ្វ៍ មុស្លីម (صحيح مسلم) ក្បាលទី ២ ចុងបំផុតនៃវគ្គស្តីអំពីមរតកសាសន៍ ។ ស្ហ៊ហ៊ិះហ្វ៍ អាល់-ប៊ូខ៏រី (صحيح البخاري) ក្បាលទី ១ វគ្គ "គីតាប់ អាល់-ស្ហូលហ៍"

[16] ពោល គឺមិនឃុំឃាំងនៅក្នុងអសកម្មភាពក្នុងការធានាអនាគតនៃវិសោធនការអ៊ីស្លាមក្រោយពីព្រះអង្គចូលទិវង្គត ។

តំណាងអ៊ុមម៉ាត្ហ៍គឺបុគ្គលដែលមានជំនឿជំនាន់មុន សរុបមានពួកមូហាជ៊ីរីន (مهاجرين) និងពួកអាន់សរ (أنصار) ។ បុគ្គលជំនាន់នេះដែលជាតំណាងអ៊ុមម៉ាត្ហ៍នោះជាមូលដ្ឋានអំណាច ជាស្នូលនៃទិសដៅព្រះប្រកាសិតនៅក្នុងដំណើរការអភិវឌ្ឍន៍ព្រះប្រកាសិតនេះ (គឺជាអ្នកដឹកនាំក្នុងការអនុវត្តិតាមព្រះប្រកាសិត) ។

ត្រង់នេះដែរ ការពិនិត្យពិច័យស្ថានការណ៍ទូទៅ (គឺស្ថានការណ៍សំខាន់ក្នុងសម័យព្រះសាស្ដា) យ៉ាងហ្មត់ចត់ ព្រមទាំងព្រឹត្តិការណ៍ដែលមិនអាចប្រកែកបានដែលគេបានដឹងអំពីព្រះសាសនៈទូត អំពីព្រះប្រកាសិតនិងអំពីអ៊ីស្លាមជំនាន់មុន បញ្ជាក់ឲ្យឃើញថាសម្មតិកម្មនេះក៏មិនត្រឹមត្រូវទៀតដែរ ហើយនាំឲ្យយើងសម្គាល់ឃើញថាព្រះសាស្ដាមិនបានតែងតាំងអ៊ុមម៉ាត្ហ៍ទេដែលមានបុគ្គលជំនាន់មុន (គឺពួកមូហាជ៊ីរីននិងពួកអាន់សរ) ជាតំណាងនោះ ដើម្បីតែងតាំងអ្នកគ្រប់គ្រងព្រះប្រកាសិតតាមគោលការណ៍ស្ហ៊ូរ៉ ។

ខាងក្រោមនេះគឺសេចក្ដីអធិប្បាយបំភ្លឺ (ការពិនិត្យពិច័យនេះ) ។

I- បើព្រះសាស្ដាបានជ្រើសយកឥរិយាបថ ប្រកបដោយសេចក្ដីសង្ឃឹមរឿងអនាគតព្រះប្រកាសិតមែននោះ ដោយបង្គាប់ឲ្យអនុវត្តិតាមប្រព័ន្ធស្ហ៊ូរ៉ភ្លាមៗ ក្រោយពីព្រះអង្គចូលទិវង្គតដោយមានអំណាចតែងតាំងអ្នកគ្រប់គ្រងព្រះប្រកាសិត ឥរិយាបថបែបនេះទាមទារឲ្យព្រះសាស្ដាព្យាយាមបង្ហឹកអ៊ុមម៉ាត្ហ៍ និងបណ្ដាអ្នកស៊ាំនឹងព្រះប្រកាសិតមុនគេនោះឲ្យថ្នឹកនឹងប្រព័ន្ធស្ហ៊ូរ៉ ឲ្យស៊ាំនឹងវិន័យនិងព័ត៌មានលម្អិតរបស់ប្រព័ន្ធនេះ ហើយនេះគឺទង្វើយ៉ាងហោចបំផុតឬជាទង្វើរាងវៃបំផុតដែលត្រូវធ្វើ ទាមទារឲ្យព្រះ



ពាក់ព័ន្ធនឹងការប្រឆាំងនឹងការសម្រេចរបស់ការប្រជុំនៅឯ សាគីហ្វាស្ញ អាល់-ត៏បារស៊ី (الطبرسى) បានថ្លែងតមកពី អាបាន អ៊ីបនូ តាក់លិប (أبان بن تَغلِب) ដែលបានថ្លែងថា៖ "កាលខ្ញុំបានសួរយ៉ាក់ហ្វារ អ៊ីបនូ មូហាំម៉ាដ្ញ អាល់-ស្វ៏ឌិក្វ ថាតើមានសាវកណាម្នាក់របស់ព្រះសាស្ដាបានងើបឡើងដើម្បីប្រឆាំងទង្វើរបស់អាប៊ូ បាការទេ ព្រះអង្គបានឆ្លើយប្រាប់ខ្ញុំថា៖ "

មាន មានដប់ពីរនាក់ គឺ៖ ខ៏លិដ្ញ អ៊ីបនូ អាល់-សាអាដ្ញ អាប៊ី វ៉ាក់ក្វាស្វ (خالد بن السعد أبي وقاص), សាល់ម៉ាន អាល់-ហ្វារ៉ស៊ី (سلمان الفارسي), អាប៊ូ ស្ហារ៍ អាល់-គីហ្វារី (أبو ذر الغفاري), អាល់-មីក្ដាដ្ញ អ៊ីបនូ អាល់-អាស់វ៉ាដ្ញ (المقداد بن الأسود), អាំម៉ារ៍ អ៊ីបនូ យ៉ាសៀរ៍ (عمار بن ياسر), ប៊ូរ៉យ់ដ្ហាស្ញ អាល់-អាស់ឡាមី (بريدة الأسلمي) ក្នុងចំណោមពួកមូហាជ៊ីរីន អាប៊ូ ហៃស្ហាំ អ៊ីបនូ អាល់-តៃហាន់ (ابو الهيثم بن التَيِّهان), អ៊ុស្ហម៉ាន អ៊ីបនូ ហ៊ូណៃហ្វ៍ (عثمان بن حُنيف), យូសៃម៉ាស្ញ អ៊ីបនូ ស្ហាប៊ីត ស្ហ៊ុល-ស្ហាហាដ្ហាតៃន៍ (خزيمة بن ثابت ذو الشهادتين), អាប៊ី អ៊ីបនូ កាអាប់ (أبي بن كعب), អាប៊ូ អៃយូប អាល់-អាន់ស្វ៏រី (أبو أيوب الأنصاري) ក្នុងចំណោមពួកអាន់សរ ។

គេអាចជំទាស់អំណះអំណាងនេះដោយពាក្យជំទាស់មួយនេះគឺ៖ "បើចរន្តស្ហ៊ីអាស្ញជាតំណាងការភក្ដីភាពចំពោះព្រះអត្ថបទសាសនា រីឯចរន្តមួយទៀតជាតំណាងការប្រើ *អ៊ីជ្ទីហាដ្ញ* បានសេចក្ដីថាពួកស្ហ៊ីអាស្ញបដិសេធនិងច្រានចោល *អ៊ីជ្ទីហាដ្ញ ។* ក៏ប៉ុន្តែពួកស្ហ៊ីអាស្ញនៅតែប្រើ *អ៊ីជ្ទីហាដ្ញ ។"*

ចម្លើយតបពាក្យជំទាស់នេះគឺ *អ៊ីជ្ទីហាដ្ញ* ដែលពួកស្ហ៊ីអាស្ញប្រើហើយចាត់ទុក យ៉ាងហោចណាស់ ថាអនុញ្ញាតឲ្យប្រើបាន បើមិនដូច្នោះទេ

ចរន្តគំនិតទាំងពីរនេះដែលបានប្រទូស្តគ្នា កាលព្រះសាសនៈទូតនៅមានព្រះជន្ម នឹងជះឥទ្ធិពលទៅលើគោលជំហាររបស់ប្រជានិករមុស្លីមចំពោះទ្រឹស្តីជ្រើសរើសអ៊ីម៉ាំអាុលីជាអ្នកគ្រប់គ្រងព្រះប្រកាសិតតពីព្រះសាស្ដា ។

ដូច្នេះ បណ្តាតំណាងចរន្តគំនិត "ធម្មប្បដិបត្តិតាមព្រះអត្ថបទព្រះសាស្ដា" គិតថាបទបញ្ញត្តិ "ធម្មប្បដិបត្តិតាមព្រះអត្ថបទព្រះសាស្ដា" នេះតម្រូវឲ្យពួកគេចាំបាច់ទទួលទ្រឹស្តីខាងនេះដូចដើម មិនឲ្យផ្អាកទ្រឹស្តីនេះ មិនឲ្យកែប្រែទ្រឹស្តីនេះ ។ ចំណែកឯបណ្តាអ្នកនិយមចរន្តគំនិតមួយទៀត យល់ឃើញថាពួកគេអាចមានសេរីភាពបានចំពោះទ្រឹស្តីនេះ បើសិនជា *អុីច្ទីហ្វាដ់* (គឺការវែកញែកដោយប្រើមតិឯង) របស់ពួកគេដឹកនាំពួកគេទៅដល់មតិមួយដែលត្រូវនឹងកាលៈទេសៈ ដោយយោងទៅតាមគំនិតពួកគេ ។

ដូច្នេះ បណ្តាអ្នកស្ហ៊ីអុាស់និយម (ឬពួកស្ហ៊ីអុាស់ ឬ ស្ហ៊ីអុីត) បានកើតឡើងភ្លាមក្រោយពីព្រះសាស្ដាចូលទិវង្គត ។ ចំពោះរឿងនេះ គេអាចនិយាយបានថា ពួកស្ហ៊ីអុាស់មានអត្ថន័យថា "បណ្តាមុស្លីមដែលព្រមទទួលស្គាល់តាមការពិតទ្រឹស្តីតែងតាំងអ៊ីម៉ាំអាុលី" ជាអ្នកគ្រប់គ្រងនិងជាអគ្គប្រមុខព្រះប្រកាសិត ហើយត្រូវដាក់ឲ្យប្រើទ្រឹស្តីនេះភ្លាមក្រោយពីអត់ពីព្រះសាសនៈទូតជាចាំបាច់តាមព្រះបញ្ជាព្រះអង្គ ។

ចរន្តស្ហ៊ីអុាស់នេះ តាំងពីដើមម្ល៉េះ ប្រឆាំងនឹងការទោរទន់ទៅរកសាគ្ហ៊ីហ្វាស់ (السقيفة) ដែលលម្អៀងទៅរកការធ្វើឲ្យតាំងទ្រឹស្តីយកអាុលីជាអគ្គប្រមុខ និងលម្អៀងទៅរកការផ្ទេរអំណាចឲ្យទៅអ្នកផ្សេង ។



សាស្ដាធ្វើឲ្យប្រព័ន្ធស្ហ៊ូរ៉ានេះមានលក្ខណៈជាជំនឿគួរគោរពបូជា ដើម្បីធ្វើឲ្យសង្គមអ៊ីស្លាមត្រៀមខ្លួនទាំងវិស័យប្រាជ្ញា ទាំងវិស័យចិត្ត សម្រាប់ទទួលប្រព័ន្ធស្ហ៊ូរ៉ានេះ ដោយដឹងច្បាស់ថាសង្គមអ៊ីស្លាមនេះជាប្រជុំកុលសម្ព័ន្ធនានាដែលបានរស់នៅក្នុងសម័យមុនអ៊ីស្លាមសាសនា ដោយមិនធ្លាប់បានស្គាល់ស្ថានការណ៍នយោបាយ ដែលមានប្រព័ន្ធស្ហ៊ូរ៉ាជាមូលដ្ឋានឡើយ តែធ្លាប់តែស្គាល់ប្រព័ន្ធបក្សពួកនិងកុលសម្ព័ន្ធដែលមានតែកម្លាំង ទ្រព្យធននិងកត្តាស្នងគ្នាសួរពូជប៉ុណ្ណោះជាធំ ។

ក៏ប៉ុន្តែ គេកត់សម្គាល់ឃើញយ៉ាងងាយស្រួលថា ព្រះសាស្ដាមិនបានចាត់ការឲ្យមនុស្សប្រុងប្រៀបខ្លួនអនុវត្តិតាមរបបស្ហ៊ូរ៉ា និងតាមសេចក្តីរៀបរាប់លំអិតអំពីនីតិបញ្ញត្តិរបស់របបស្ហ៊ូរ៉ានេះទេ ។ ពីព្រោះ ប្រសិនបើបានប្រព្រឹត្តដូច្នេះមែននោះ ទង្វើនេះប្រាកដជាត្រូវបានចារទុកនៅក្នុងហាឌីស្ហ៍ព្រះសាសនៈទូត ត្រូវដឹតជាប់នៅក្នុងការចងចាំរបស់អ៊ុមម៉ាត់ ឬយ៉ាងហោចណាស់ត្រូវដឹតជាប់នៅក្នុងការចងចាំរបស់ជនជំនាន់មុន ដែលសន្មតថាជាអ្នកទទួលខុសត្រូវខាងការអនុវត្តន៍ប្រព័ន្ធស្ហ៊ូរ៉ានោះ ។ តែពេលយើងស្រាវជ្រាវស្វែងរកនៅក្នុងហាឌីស្ហ៍ព្រះសាស្ដា យើងមិនឃើញតួអង្គនីតិបញ្ញត្តិនៃប្រព័ន្ធស្ហ៊ូរ៉ាយ៉ាងជាក់ច្បាស់ទេ ។ លុះយើងពិនិត្យមើលចំណាំរបស់អ៊ុមម៉ាត់អ៊ីស្លាម ឬចំណាំរបស់ជនជំនាន់មុននៃអ៊ុមម៉ាត់ យើងមិនឃើញមានស្លាកស្នាម មិនឃើញមានស្រមោលជាក់លាក់នៃសកម្មភាពណាមួយដែលបញ្ជាក់អំពីការត្រៀមខ្លួនអនុវត្តិតាមប្រព័ន្ធនេះទេ ។

ការពិតជនជំនាន់មុនមានពីរនិន្នាការ (គឺការទោរទន់ទៅរក) គឺ៖

១-និន្នាការដឹកនាំដោយអាស្ទ៍លុល-បៃត៍[17]

២-និន្នាការដែលមានសាគីហ្វាស្ទ៍ (السقيفة)[18] និងខ៏លីហ្វាស្ទ៍ជាតំណាង គឺខ៏លីហ្វាស្ទ៍ដែលបានយកអំណាចធរមាន ក្រោយពីព្រះសាស្តាបានចូលទិវង្គតនោះ ។

ចំពោះនិន្នាការទីមួយ គឺបណ្ដាអ្នកដែលជឿជាក់ទៅលើ "ការតែងតាំងពីបុព្វកាល[19]" លើអ៊ីម៉ាម៉ាស្ទ៍ ហើយឲ្យទម្ងន់ទៅលើព្រះរាជវង្ស (គឺព្រះរាជវង្សរបស់ព្រះសាស្តាﷺ) ។ គេមិនសម្គាល់ឃើញបុគ្គលដែលមាននិន្នាការនេះជឿជាក់ទៅលើមតិស្ទីរ៉នោះទេ ។

ចំណែកឯនិន្នាការទីពីរវិញ គ្រប់ហេតុការណ៍នៅក្នុងការប្រតិបត្តិមែនទែន និងនៅក្នុងទង្វើរបស់អ្នកប្រតិបត្តិមែនតែននោះបញ្ជាក់ឲ្យឃើញថា អ្នកប្រតិបត្តិមែនទែនទាំងនេះមិនជឿទៅលើគោលការណ៍ស្ទីរ៉នោះទេ ហើយជនទាំងនេះមិនបានប្រើប្រាស់អំណាច ដោយផ្អែកទៅលើគោលការណ៍នេះទេ ។ មុស្លីមគ្រប់ផ្នែកទាំងអស់ក្នុងសម័យព្រះសាស្តាចូលទិវង្គនោះក៏

17 អាស្ទ៍លុល-បៃត៍គឺព្រះរាជកុលដ្ឋានعليهم السلام គឺក្រុមគ្រួសាររបស់ព្រះសាស្តាﷺ ដែល យោលតាមស្ទីអ៊ាស្ទ៍ មានបងប្អូនជីតាមួយរបស់ព្រះសាស្តាﷺ ហើយជាកូនប្រសាររបស់ព្រះអង្គﷺ គឺអ៊ីមុាំ អ៊ាលីصلوات الله عليه والسلام អ៊ីបនូ អាប៊ី ត៉ូលិបرضي الله عنه មានព្រះរាជបុត្រីរបស់ព្រះសាស្តាﷺ គឺហ្វាទីម៉ាស្ទ៍ ស្សាស្ទ៍រ៉سلام الله عليها ព្រះរាជអគ្គមហេសីរបស់អ៊ាលីﷺ និងមានព្រះរាជបុត្ររាជនត្តាعليهم السلامរបស់ព្រះអង្គعليهم السلام (គឺអ៊ីមុាំទាំង ១១ អង្គទៀត) ។

18 គឺពួកមុស្លីមដែលបានប្រជុំគ្នានៅឯសាគីហ្វាស្ទ៍ ។ មើលកំណត់ខាងលើលេខ 7 ។

19 ពោលគឺ ត្រូវតែងតាំងតាមរយៈព្រះរាជសាររបស់អល់ឡោះហ្ទ៍عز وجل ។



ការទាស់គំនិតគ្នានិងជម្លោះបានផ្ទុះឡើងនៅទីនោះ រវាងបណ្ដាអ្នកមានវត្តមាននៅទីនោះ ។ អ្នកខ្លះថា៖ "ឲ្យព្រះសាស្តាសរសេរសំបុត្រមួយច្បាប់ឲ្យអស់លោកចុះ សំបុត្រនេះនឹងការពារអស់លោកមិនឲ្យវង្វេងក្រោយពីព្រះអង្គចូលទិវង្គត ។" អ្នកឯទៀតយល់ស្របតាមសម្ដីរបស់អ៊ូម៉ារ ។ លុះការខ្វែងគំនិតគ្នានិងជម្លោះនោះកាន់តែរាលដាលធំឡើង ព្រះសាស្តាក្រោធ ក៏បានប្រាប់ពួកគេថា៖ "អស់លោកទៅវិញទៅ ។"

សម្រាប់ព្រះសាស្តា ឧប្បត្តិហេតុនេះបង្ហាញឲ្យឃើញជម្រៅប្រឡាយដែលញែកចរន្តគំនិតទាំងពីរ ឲ្យឃើញជម្រៅនៃបដិវាទកម្ម (គឺការផ្ទុយសម្ដីគ្នា) និងការប្រជែងគ្នារវាងចរន្តគំនិតទាំងពីរនេះ ។

គេបរិយាយបន្ថែមពីលើរឿងនេះ - ដើម្បីបង្ហាញនូវជម្រៅនិងការចាក់ឫសនៃចរន្តនេះ - នូវការមិនត្រូវគ្នា ឬការខុសមតិគ្នាដែលធ្វើឲ្យបណ្ដាសាវកបែកខ្ញែកគ្នារឿងតែងតាំងអ៊ូសាម៉ាស្ទ៍ អ៊ីបនូ ស្សៃដ៍ ជាមេបញ្ជាការទ័ព ទោះបីនេះជាការតែងតាំងដែលព្រះសាសនៈទូតបញ្ជាមក យ៉ាងច្បាស់លាស់ក៏ដោយ បានសេចក្ដីថាត្រូវនឹងព្រះអត្ថបទសាសនា (គឺស្របតាមព្រះបន្ទូលអល់ឡោះហ្ទ៍) ។ ការខ្វែងគំនិតគ្នានេះធ្ងន់ណាស់ បង្ខំព្រះសាសនៈទូតឲ្យចេញមកក្រៅ ថ្វីដ្បិតព្រះអង្គទ្រង់ប្រឈួនខ្លាំង មកប្រកាសប្រាប់សាធារណៈជនរឿងនេះថា៖ "ម្នាលប្រជានិករ ! ខ្ញុំបានឮថាអស់លោកខ្លះជំទាស់ការសម្រេចតែងតាំង អ៊ូសាសាម៉ាស្ទ៍ជាមេបញ្ជាការដូចអស់លោកបានធ្វើកាលពីមុននោះដែរ កាលឪពុករបស់គេត្រូវតែងតាំងជាមេបញ្ជាការ ។ តែអល់ឡោះហ្ទ៍عز وجلទ្រង់ញាណច្បាស់ថាឪពុកសក្តិសមនឹងមុខងារមេបញ្ជាការនេះដូចកូនរបស់គេដែរ បន្ទាប់ពីឪពុក ។"

យើងសូមបញ្ជាក់រឿងនេះអំពីគោលជំហរលោក អ៊ុម៉ារ អ៊ីបនូ អាល់-ខុត្តុប់ជាអ្នកប្រឆាំងសន្ធិសញ្ញាសន្តិសុខនៅហ៊្វូដៃបីយ៉ាស់ (الحديبية) អាកប្បកិរិយាលោកពាក់ព័ន្ធនឹងរឿងអាស្ហាន (أَذَان ការប្រកាសស្ហ៍ឡាត់) ស្របតាមច្បាប់ដែលលោកបានកាត់ចោលឃ្លា "ហៃយ៉ា អាឡា ខុយ៉រីល អ៊ុម៉ាល់ حي على خير العمل"[52] ឬគោលជំហរលោកប្រឆាំងព្រះសាស្ដាកាលព្រះអង្គបានដាក់ឲ្យប្រើ "មុតតាអ៊ុស្ទ់ អាល់-ហ៊ាជ្ជ់"[53] លោកមានគោលជំហរជាអ្នកធ្វើ *អ៊ីជ្ទីហ្ហាដ្ន់* ច្រើនរឿងទៀត ។

ចរន្តគំនិតទាំងពីរនេះបានប្រឈមមុខគ្នានៅក្នុងការប្រជុំមួយ នៅឯដំណាក់ព្រះសាសនៈទូតពេលចុងក្រោយនៃជីវិតព្រះអង្គ ។ អាល់-ប៊ូខរ៍ីបានថ្លែងតមកពីអ៊ីបនូ អ៊ាប់បាស់ នៅក្នុងស្ហ៊ហ៊ិះហ៍លោក ថាៈ

"កាលព្រះសាស្ដាជិតចូលទិវង្គតនៅឯដំណាក់ព្រះអង្គ ដោយមានវត្តមានមនុស្សពីរបីនាក់ ដូចជាអ៊ុម៉ារ អ៊ីបនូ អាល់-ខុត្តុប់ជាដើម ព្រះអង្គមានព្រះវចនៈថាៈ "ឲ្យខ្ញុំសរសេរសំបុត្រប្រាប់ការប្រតិបត្តិមួយច្បាប់ (គឺមរតកសាសន៍) ដែលនឹងការពារអស់លោកមិនឲ្យវង្វេង ។" អ៊ុម៉ារបាននិយាយដាក់បណ្ដាអ្នកនៅទីនោះថាៈ "ព្រះសាស្ដាឈឺខ្លាំងណាស់ ។ អស់លោកមានគម្ពីរអានស្រេចហើយ ។ យើងអាចពឹងផ្អែកលើព្រះគម្ពីរអល់ឡោះហ៍បានហើយ ។"

[52] មានន័យថា ចូរប្រញាប់ប្រញាល់ធ្វើល្អ ។

[53] មុតតាអ៊ុស្ទ់ អាល់-ហ៊ាជ្ជ់ ឬ ហ៊ាជ្ជ់ អាល់-តាម៉ាត់ទុអ៊ំ គឺទង្វើមួយចំនួនក្នុងពិធីហ៊ាជ្ជ ។



ដូច្នេះដែរ ។

យើងសូមលើកឡើងនូវឧទាហរណ៍ខ្លះដើម្បីបំភ្លឺការអះអាងនេះ គឺៈ

កាល អាប៊ូ បាការ ឈឺធ្ងន់ លោកបានតែងតាំង អ៊ុម៉ារ អ៊ីបនូ អាល់-ខុត្តុប់ជាអ្នកស្នងលោក (ក្នុងការកាន់ខ៊ុលីហ្វាស់) ហើយបានសូមឲ្យអ៊ុស្ហ៍ម៉ានកត់ត្រាជាលាយលក្ខអក្សរនូវបណ្ដាំមរតកសាសន៍របស់លោក ដូចតទៅ គឺៈ "ក្នុងព្រះនាមអល់ឡោះហ៍ ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី ។ នេះគឺអ្វីដែល អាប៊ូ បាការ ខ៊ុលិហ្វ (គឺអ្នកស្នង) របស់ព្រះសាសនៈទូតរបស់អល់ឡោះហ៍ ជូនចំពោះបណ្ដាអ្នកមានសទ្ធានិងមុស្លីមទាំងឡាយ សូមសិរីសួស្ដីកើតមានដល់អស់លោក ។ សូមថ្វាយសេចក្ដីរុងរឿងចំពោះអល់ឡោះហ៍ ។ ខ្ញុំបានតែងតាំង អ៊ុម៉ារ អ៊ីបនូ អាល់-ខុត្តុប់ ឲ្យអស់លោក ។ ដូច្នេះចូរអស់លោកស្ដាប់និងគោរពតាម អ៊ុម៉ារ អ៊ីបនូ អាល់-ខុត្តុប់ ។"

លុះ អ៊ាប់ឌុលរ៉ោះហ្ម៉ាន អ៊ីបនូ អ៊ោហ្វ៍ (عبد الرحمن بن عوف) បានទៅជួបលោក សួរលោកថាៈ "ខ៊ុលិហ្វរបស់ព្រះសាសនៈទូតរបស់អល់ឡោះហ៍អឺយ តើលោកសុខទុក្ខយ៉ាងណា ?" លោកបានតបថាៈ "ខ្ញុំជិតស្លាប់ហើយ ។ ចំណែកឯលោកវិញ លោកបានធ្វើឲ្យអាការរោគខ្ញុំកាន់តែធ្ងន់ឡើង ។ ពេលឃើញខ្ញុំតែងតាំងគ្នាអស់លោកម្នាក់ អស់លោករាល់គ្នារីកច្រមុះ ហើយអស់លោករាល់គ្នាបានសូមឲ្យតែងតាំងខ្លួន ។"[20]

[20] តារិខ៊ អាល់-យ៉ាក៊ូប៊ី (تاريخ اليعقوبي), 2/126-127 ។

របៀបស្នងតំណែងកាន់អំណាចខ៏លីហ្វាស្វ់បែបនេះ និងការប្រកែកជំទាស់នៅក្នុងបក្សប្រឆាំង ដែលវិធីស្នងតំណែងនេះបណ្ដាលឲ្យកើតមានឡើងនោះសឲ្យឃើញថាស្ដេចខ៏លិហ្វ (គឺអាប៊ូ បាការ) មិនបានគិតគូតាមស៊ូរ៉ទេ លោកបានគិតថាខ្លួនមានសិទ្ធិជ្រើសរើសឈ្មោះអ្នកស្នងអំណាចតពីខ្លួនបាន ហើយការតែងតាំងនេះទាមទារឲ្យពួកមុស្លីមអនុវត្តតាម ។ ដូច្នេះឯងបានជាលោកដាក់បញ្ជាឲ្យមុស្លីមទាំងឡាយ ស្ដាប់អ្នកស្នងអំណាចតពីលោកនោះ ហើយឲ្យគោរពតាមអ្នកនោះ ។ ដូច្នេះ នេះមិនមែនការណែនាំធម្មតាទេ មិនមែនការស្នើឈរឈ្មោះធម្មតាទេ តែជាកំហិតចាំបាច់និងជាការតែងតាំងឡើង ។

គេអាចកត់សម្គាល់បានថាអ៊ុម៉ារ អ៊ីបនូ អាល់-ខុត្ត៏តូប់ ក៏គិតថាខ្លួនមានសិទ្ធិតែងតាំងអ្នកស្នងអំណាចខ៏លីហ្វាស្វ់ឲ្យមុស្លីមជាកំហិតដែរ ។ ដូច្នេះឯងបានជាលោកតែងតាំងបុគ្គលប្រាំមួយនាក់ ហើយឲ្យបុគ្គលទាំងប្រាំមួយរូបនេះជ្រើសរើសម្នាក់ជាខ៏លិហ្វ ដោយមិនបណ្ដោយឲ្យមុស្លីមទូទៅចូលរួមយ៉ាងពេញលេញក្នុងការ "ជ្រើសរើស" នេះឡើយ ។

និយាយសរុប ទាំងវិធានការដែលបុគ្គលដំបូង (គឺខ៏លិហ្វ អាប៊ូ បាការ) បានជ្រើសយកដើម្បីតែងតាំងអ្នកស្នងខ្លួន ទាំងវិធានការដែលបុគ្គលទីពីរ (គឺខ៏លិហ្វ អ៊ុម៉ារ អ៊ីបនូ អាល់-ខុត្ត៏តូប់) បានជ្រើសយកនោះមិនបង្ហាញឲ្យឃើញនូវស្មារតី *ស៊ូរ៉* ទេ ។ ដូចគ្នាដែរ បើយើងបែរទៅមើលសម្ដីរបស់បុគ្គលទីមួយនិងបុគ្គលទីពីរ (គឺខ៏លិហ្វទាំងពីរ) យើងមិនកត់សម្គាល់ឃើញមាននូវស្លាកស្នាមមតិ *ស៊ូរ៉* នេះទេ ។

ដូច្នេះ កាលគេបានសួរអ៊ុម៉ារអំពីការស្នងលោកនោះ លោកបានថា៖ "បើ



និយាយបានថា ប្រវត្តិសាស្ត្រមនុស្សជាតិមិនដែលស្គាល់ជំនាន់ជំនឿណាថ្លៃថ្នូរ ឬបរិសុទ្ធជាងជំនាន់ជំនឿដែលព្រះសាស្ដាបានបង្កើតនោះទេ) តែត្រូវទទួលស្គាល់ថានៅក្នុងជួរបណ្ដាសាវកទាំងនេះ សម័យព្រះសាសនៈទូតមានព្រះជន្មនៅឡើយនោះ មាននូវចរន្តគំនិតធំដែលទេរទៅរកការនិយមប្រើ *អ៊ីច្ទីហ្វាដ៏* (គឺការអារកាត់ដោយខ្លួនឯង) ដើម្បីផលប្រយោជន៍ (របស់អ៊ុមម៉ាត់ ឬសាសនិកជន)[50] និងការសន្និដ្ឋានទាញយកផលពីកាលៈទេសៈ[51] ផ្ទុយពីចរន្តគំនិតមួយទៀតដែលជឿលើមជ្ឈត្តកម្មសាសនា ជឿលើការចាំបាច់ត្រូវចុះចូលខ្លួនក្នុងសាសនានិងត្រូវគោរពព្រះអត្ថបទសាសនាយ៉ាងម៉ឺងម៉ាត់និងដាច់ខាតក្នុងគ្រប់វិស័យជីវិត ។ ប្រាកដណាស់ ដែលមុស្លីមភាគច្រើនគាំទ្រចរន្តគំនិតទីពីរនោះមកពីមូលហេតុមួយ ក្នុងចំណោមមូលហេតុច្រើនទៀត គឺមូលហេតុមនុស្សទេរទៅរកការប្រព្រឹត្តជាធម្មតាដោយយោលទៅតាមផលប្រយោជន៍ដែលខ្លួនគិត និងប៉ាន់ស្មានបានដោយខ្លួនឯង ពុំមែនយោលទៅតាមការសម្រេចដែលខ្លួនមិនយល់ន័យនោះទេ ។

ចរន្តគំនិតនេះមានអ្នកតំណាងព្រហើនច្រើនអ្នកដែលជាសាវកល្បីៗ ដូចជា អ៊ុម៉ារ អ៊ីបនូ អាល់-ខុត្ត៏តូប់ជាដើមដែលបានប្រកែកការសម្រេចរបស់ព្រះសាស្ដាហើយហ៊ានចេញមតិដោយខ្លួនឯង ដែលមិនសមស្របនឹងព្រះអត្ថបទសាសនារាល់ដងទេនោះ ជឿជាក់ថាខ្លួនមានសិទ្ធិធ្វើបែបនេះ ។

[50] កំណត់របស់អ្នកបកប្រែ ។

[51] ព្រះសាស្ដាﷺបានឈឺចាប់យ៉ាងខ្លាំង - ច្រើនលើក ច្រើនគ្រា ជាពិសេសពេលព្រះអង្គជិតចូលទិវង្គត - ដោយសារពួកនិយមចរន្តគំនិត *អ៊ីច្ទីហ្វាដ៏* ។

១- និន្នាការដែលជឿលើធម្មប្បដិបត្តិ[48]សាសនា (គឺទង្វើនានាក្នុងសាសនា) ជឿលើមជ្ឈត្តកម្មរបស់សាសនា (គឺអាជ្ញាកណ្តាលរបស់សាសនា) និងជឿលើស្វីការជាដាច់ខាត (គឺការព្រមទទួលគ្រប់ប្រការ) នៃព្រះអត្ថបទសាសនាក្នុងគ្រប់វិស័យនៃជីវិត ។

២- និន្នាការដែលគិតថា ជំនឿលើសាសនាតម្រូវឲ្យមុស្លីមកាន់ធម្មប្បដិបត្តិសាសនាដោយមានកំណត់តែលើការមានសទ្ធាខ្លះ និងលើប្រការ (សាសនាអ៊ីស្លាម) ខ្លះប៉ុណ្ណោះដែលពាក់ព័ន្ធនឹងអាថិកំបាំង ។ ក្រៅពីខណ្ឌសីមានេះ និន្នាការនេះជឿលើការអាចប្រើ *អ៊ីជ្ទីហ្វាដ្ន៍*[49]បាននៅក្នុងផ្នែកឯទៀតនៃជីវិត ដោយហេតុនេះ ជឿលើការអាចផ្លាស់ប្តូរឬកែព្រះអត្ថបទសាសនាបានដោយស្របច្បាប់តាមផលប្រយោជន៍ក្នុងកាលៈទេសៈ និងតាមព្រឹត្តិការណ៍នៃស្ថានភាព (ពាក់ព័ន្ធនឹងផ្នែកឯទៀតនៃជីវិតខាងលើនេះ) ។

ទោះបីបណ្តាសាវកទាំងនេះ - ដែលមានគុណសម្បត្តិជាអ្នកមានសទ្ធានិងជាអ្នកមានការចេះដឹងជំនាន់មុននោះ - ជាគ្រាប់ពូជប្រសើរបំផុតនិងជាបំផុតសម្រាប់បង្កបង្កើតប្រជារាស្ត្រសាសនាក៏ដោយ (ដល់ថ្នាក់គេអាច

[48] ពោលគឺ អនុវត្តិនិងគោរពយ៉ាងម៉ឺងម៉ាត់តាមបទបញ្ញត្តិនៃព្រះសាត្រាសាសនា (មិនត្រឹមតែគួរអានទេ ថែមទាំងស៊្វណាស៎ណាប៊ីដែរ) ។ គឺព្រមទទួលឥតប្រកែកដោយមិនសាកសួររកមូលហេតុ និងការសមរម្យរបស់អត្ថបទសាសនាទាំងនោះទេ ។

[49] យោបល់ខ្លួនឯង ។ ត្រង់នេះ អ៊ីជ្ទីហ្វាដ្ន៍ផ្ទុយពីការគោរពព្រះអត្ថបទសាសនា (نَصّ ណាស្ន៍ ប្រែត្រង់ថា អត្ថបទ) យ៉ាងម៉ឺងម៉ាត់ ។



បុគ្គលណាមួយ ក្នុងចំណោមបុគ្គលទាំងពីរនាក់នោះ (គឺសាលិម ម៉ៅឡា អ៊ីបនូ អាប៊ី ហ៊្វស្ស៊ៃក្ងោះហ៍ និង អាប៊ី អ៊ូបៃដ្ងាស៎ អាល់-យ៉ារ៉ោះត៊៍) មានវត្តមាន ខ្ញុំនឹងប្រគល់វា[21]ឲ្យទៅបុគ្គលនោះ ហើយខ្ញុំទុកចិត្តលើបុគ្គលនោះ ។ ប្រសិនបើសាលិមនៅរស់ ខ្ញុំនឹងធ្វើវា[22]ដោយគ្មាន *ស៊ូរ៉* ទេ ។"[23]

ចំណែកឯ អាប៊ូ បាការ វិញ (កាលលោកជិតដាច់ដង្ហើម) លោកបានប្រាប់អ៊ាប់ឌុលរ៉ោះហ្ម៉ាន អ៊ីបនូ អ៊ៅហ្វ៍ ថា៖ "ខ្ញុំចង់សួរព្រះសាសនៈទូតរបស់អល់ឡោះហ្វ៍ណាស់ថារឿងនេះ (គឺការស្នងអំណាច) បានទៅលើអ្នកណា ។ ធ្វើបែបនេះ ពុំមានអ្នកណាមួយហ៊ានជំទាស់រឿងនេះឡើយ ។"[24]

កាលពួកអាន់ស្វារ ពេលប្រជុំគ្នានៅឯសាគីហ្វាស៎ បានសម្រេចចិត្តជ្រើសរើសគ្នាឯងម្នាក់ដើម្បីដឹកនាំពួកមុស្លីម ក្រោយពីព្រះសាស្តាបានចូលទិវង្គត មានបក្សពួកពួកគេម្នាក់ថ្លែងសេចក្តីបារម្ភថា៖ "បើពួកមូហ្វាយ៉ីរីនគូរ៉ៃស្ហ៍ជំទាស់ដោយអះអាងលើសិទ្ធិរបស់ខ្លួន (ដែលអាចស្នងអំណាចខ៊ីលីហ្វាស៎បាន) ក្នុងនាមជាមូហ្វាយ៉ីរីន ជាសាវករបស់ព្រះសាស្តានិងរបស់ព្រះរាជកុលដ្ឋានរបស់ព្រះអង្គ ?" គេបានឆ្លើយប្រាប់អ្នកនោះថា៖ "យើងនឹងប្រាប់ពួកគេថា៖ «គ្នាយើងម្នាក់និងគ្នាអស់លោកម្នាក់[ជាខ៊ីលិហ្វ] ។ នេះគឺមតិផ្តាច់ព្រ័ត្ររបស់យើង ។»"

[21] វាគឺការស្នងអំណាច ។

[22] វាគឺការស្នងអំណាច ។

[23] តាបាក៊ូត់ អ៊ីបនូ សាក៊ុដ្ន៍, 3/248 ។

[24] តារិក៊ អាល់-ត៏បារី (تاريخ الطبري), 4/52 ។

មែន អាប៊ូ បាការ បានប្រាប់ពួកគេ (គឺពួកអាន់ស្វារ) ដោយថ្លែងថា៖ "យើងជាមុស្លីមភៀសខ្លួន (គឺមូហ្វាយ៊ីរីន) ជាអ្នកប្រែមកកាន់សាសនាអ៊ីស្លាមមុនគេបង្អស់ ។ មនុស្សម្នាបានធ្វើតាមយើង ។ យើងជាកុលសម្ព័ន្ធរបស់ព្រះសាសនៈទូតរបស់អល់ឡោះហ្វ៍ យើងជាក្រសែលោហិតរបស់អារ៉ាប់ថ្លៃថ្នូរជាងគេ ។"

លុះពួកអាន់ស្វារបានស្នើសូមឲ្យពួកអាន់ស្វារ និងពួកមូហ្វាយ៊ីរីនកាន់ខ៊ុលីហ្វាស៊ូឆ្លាស់គ្នា អាប៊ូ បាការ បានតបថា៖ "កាលព្រះសាសនៈទូតអល់ឡោះហ្វ៍ត្រូវដាក់ចុះមក ពួកអារ៉ាប់មិនចង់បោះបង់ចោលសាសនារបស់ដូនតាខ្លួនទេ ដូច្នេះហើយបានជាពួកគេប្រឆាំងព្រះអង្គ សាងឧបសគ្គដាក់ព្រះអង្គ ។ អល់ឡោះហ្វ៍បានជ្រើសរើសពួកភៀសខ្លួនមុនគេដែលជាជនរួមកុលសម្ព័ន្ធព្រះអង្គដើម្បីជឿព្រះអង្គ ។ ដូច្នេះពួកគេជាអ្នកបូជាអល់ឡោះហ្វ៍មុនគេបង្អស់ ។ ពួកគេជាសាវកភក្តីរបស់ព្រះសាស្តានិងជាសមាជិកនៃព្រះរាជកុលដ្ឋានព្រះអង្គ ។ ពួកគេមានសិទ្ធិស្នងអំណាចតពីព្រះអង្គជាងអ្នកដទៃ ។ មានតែបុគ្គលទុច្ចរិតទេដែលហ៊ានប្រឆាំងសិទ្ធិពួកគេ ។"

កាល អាល់-ហាប់បាប់ អ៊ីបនូ អាល់-មុនស្ទៀរបានប្រាប់ពួកអាន់ស្វារដើម្បីញុំាងពួកគេឲ្យកាន់ជំហរដដែលថា៖ "ចូរអស់លោកកាន់អ្វីដែលមាននៅក្នុងដៃអស់លោកស្រាប់ហើយឲ្យជាប់ ។ មនុស្សរស់នៅក្រោមម្លប់អស់លោក លើដីអស់លោក ។ ប្រសិនបើពួកនេះ (គឺពួកភៀសខ្លួន) បដិសេធ[25] នឹងមានស្តេចយើងនិងស្តេចពួកគេ ។"

[25] គឺបដិសេធការស្នើសូមរបស់អស់លោក ការឈរឈ្មោះរបស់អស់លោកដើម្បីឡើងកាន់ខ៊ុលីហ្វាស៊ូ ។



# វគ្គ ២ - តើអ្នកស្ទីអ្នុស្វ៉និយមកកើតឡើងដូចម្តេច?

យើងបានដឹងហើយថាស្ទីអ្នុស្វ៉កើតឡើងដូចម្តេច ។ យើងមិនទាន់ដឹងទេថាតើប៉ែកស្ទីអ្នុស្វ៉កកើតឡើងដូចម្តេច តើអ៊ុមម៉ាត់ត្រូវបែកបាក់ដូចម្តេច ។ យើងសាកល្បងឆ្លើយសំណួរទាំងនេះក្នុងទំព័រខាងមុខ ។

លុះគេរៀបរាប់សាឡើងវិញ អំពីដំណាក់កាលដំបូងនៃជីវភាពអ៊ុមម៉ាត់អ៊ីស្លាម គេសម្គាល់ឃើញថាពីរនិន្នាការធំនិងខុសគ្នាបានអមជាប់តាមកំណើតអ៊ុមម៉ាត់ ហើយបានលេចឡើងតាំងពីឆ្នាំដំបូងនៃវិសោធនការអ៊ីស្លាមម្ល៉េះ ។ និន្នាការទាំងពីរនេះនៅជាមួយគ្នាក្នុងក្របខណ្ឌអ៊ុមម៉ាត់ដែលទើបនឹងកើតឡើង ដែលព្រះសាសនៈទូតបានសាងហើយនោះ ។ ភាពខុសគ្នារវាងទាំងពីរនិន្នាការនេះ បណ្តាលឲ្យមានការបែងចែកជំនឿកើតឡើងភ្លាមៗក្រោយពីព្រះសាស្តាបានចូលទិវង្គត ការបែងចែកនេះធ្វើឲ្យអ៊ុមម៉ាត់អ៊ីស្លាមបែកជាពីរប៉ែក ប៉ែកមួយត្រូវលើកឲ្យកាន់អំណាចហើយអាស្រ័យហេតុនេះ បានទៅជាប៉ែកភាគច្រើន រីឯប៉ែកមួយទៀតត្រូវឃ្លាតចេញពីអំណាចហើយអាស្រ័យហេតុនេះ ត្រូវទៅជាបក្សប្រឆាំងភាគតិចនៅក្នុងក្របខណ្ឌអ៊ីស្លាមធុនអន់ ។ ជនភាគតិចនេះឯងដែលគេហៅអ្នកស្ទីអ្នុស្វ៉និយម (ឬ ស្ទីអ្នុស្វ៉ ឬ ស្ទីអ៊ីត) ក្រោយមក ។

និន្នាការទាំងពីរដែលអមជាប់តាមកំណើតអ៊ុមម៉ាត់អ៊ីស្លាម ពីសម័យព្រះសាស្តានៅមានព្រះជន្មនិងចាប់តាំងពីដើមវិសោធនការអ៊ីស្លាមគឺ៖

ដូច្នេះ ស្ទីអ៊ុស្ទ់បានចាប់បដិសន្ធិឡើងនៅក្នុងក្របខ័ណ្ឌព្រះប្រកាសិតអ៊ីស្លាមជាការបកស្រាយនិក្ខេបបទ (thèse) ព្រះសាស្ដា ដែលព្រះសាសនៈទូតបានប្រគល់ជូនតាមព្រះបញ្ជារបស់អល់ឡោះហ៍ ដើម្បីអភិរក្សអនាគតព្រះប្រកាសិត ។

ដោយហេតុនេះ ស្ទីអ៊ុស្ទ់មិនមែនបាតុភូតដែលកើតដោយចៃដន្យនៅក្នុងឆាកព្រឹត្តិការណ៍នោះទេ តែជាលទ្ធផលចាំបាច់ដែលកើតមកពីប្រភេទនៃការកកើតព្រះប្រការសិត និងមកពីតម្រូវការរបស់ព្រះប្រកាសិតនេះនិងកាលៈទេសៈដើមដែលតម្រូវឲ្យអ៊ីស្លាមបង្កបង្កើតស្ទីអ៊ុស្ទ់ឡើង ។ អាចនិយាយបានម្យ៉ាងទៀតថាកាលៈទេសៈនេះ និងប្រភេទនៃព្រះប្រកាសិតតម្រូវឲ្យព្រះអគ្គប្រមុខដំបូងនៃព្រះវិសោធនការ (គឺព្រះសាស្ដា) ត្រៀមខ្លួនព្រះអគ្គប្រមុខទីពីរ (គឺអ៊ីម៉ាំអ៊ុលី) ដើម្បីនឹងឲ្យព្រះអគ្គប្រមុខទីពីរនេះ ព្រមទាំងបណ្ដាអ្នកស្នងតៗមកនោះ ធានាអភិវឌ្ឍនាការនៃព្រះវិសោធនការបដិវត្ត ប្រតិបត្តិការក្នុងគោលបំណងសម្រេចគោលដៅកម្ចាត់សំណល់និងឫសគល់នៃបុរាណសម័យមុនអ៊ីស្លាម (យ៉ាហ្ស៊ីលីយ៉ាស្ទ់) និងលើកស្ទួយអ៊ុមម៉ាត្ទ់ដែលស័ក្តិសមនឹងលេចត្រដែតឡើងដល់កម្រិតត្រូវការ និងដល់កម្រិតអាចគ្រប់គ្រងព្រះប្រកាសិតបាន ។



អ៊ុម៉ារ អ៊ីបនូ អាល់-ខ៊ុត្តុប់បានតបគាត់វិញថា៖ "ដាវពីរមិនអាចនៅក្នុងស្រោមតែមួយបានជាដាច់ខាត... បុគ្គលណាដណ្ដើមអំណាចនិងការស្នងតពីមូហ៊ាំម៉ាដ្ទ់ពីយើង យើងដែលជាសាវកភ័ក្ដីរបស់ព្រះអង្គព្រមទាំងជាជនរួមកុលសម្ព័ន្ធ បុគ្គលនោះអាចជាបុគ្គលមិនត្រឹមត្រូវ ទេរទៅរកបាបកម្ម ឬពាក់ព័ន្ធនៅក្នុងកំហុសធំ ។"[26]

វិធីជ្រើសរើសអ្នកស្នងដែលខ៊ុលិហ្វទីមួយនិងខ៊ុលិហ្វទីពីរបានប្រើ ការពុំមានការប្រកែកជំទាស់វិធីនេះ មតិទូទៅដែលមានប្រៀបលើគេថ្ងៃសាគ៊ីហ្វាស្ទ់នៅក្នុងបក្សប្រឆាំងទាំងពីរដែលជាជនជំនាន់មុន (គឺពួកមូហ្វាយ៉ីរីននិងពួកអាន់ស្វារ) ពួកហ្វាយ៉ីរីនមាននិន្នាការទៅខាងទាញយកអំណាចមកតែខាងខ្លួនឯង ដោយមិនឲ្យពួកអាន់ស្វារចូលរួមចំណែកអំណាចនេះទេ ពួកមូហ្វាយ៉ីរីនទទូចអះអាងលើលក្ខខណ្ឌស្នងមរតកស្ពូជ យោលតាមលក្ខខណ្ឌនេះ កុលសម្ព័ន្ធរបស់ព្រះសាស្ដាមានសិទ្ធិស្នងអំណាចមុនពួកអារ៉ាប់ទាំងអស់ ពួកអាន់ស្វារព្រមទទួមមតិស្ដេចសោយរាជ្យពីរ (គឺមានខ៊ុលិហ្វពីរ) ស្ដេចអាន់ស្វារមួយ ស្ដេចមូហ្វាយ៉ីរីនមួយ ។ ហេតុការណ៍ដែល អាប៊ូ បាការ បានសម្ដែងឲ្យឃើញថាខ្លួនស្ដាយក្រោយដែលពុំបានសួរព្រះសាស្ដាថាអ្នកណាជាអ្នកស្នងអំណាចបន្ត ថ្ងៃដែលគេបានតែងតាំងខ្លួនជាអ្នកគ្រប់គ្រងខ៊ុលិហ្វាស្ទ់... ចំណុចទាំងនេះសឲ្យឃើញយ៉ាងជាក់ស្ដែង ពុំអាចក្រកែបាន ដោយរាប់បញ្ចូលប៉ែកដែលបានកាន់អំណាចក្រោយពីព្រះសាស្ដាបានចូលទិវង្គតដែរ ថាបុគ្គលទាំងនេះនៃ

26 មើលសេចក្ដីរាយការណ៍អំពីថ្ងៃសាគ៊ីហ្វាស្ទ់នៅក្នុងតម្រា "ស្ទារហ្ទ៍ ណាស្ទ់យ៉ អាល់-បាឡាក៊ោះត្ទ៍" ក្បាលទី 4 ទំព័រ 6-9 ។

អ៊ុមម៉ាត់ជំនាន់មុននេះមិនរិះគិតដោយសមស្រមទៅតាមមតិ *ស៊ូរ៉* ទេ ហើយមិនស្គាល់យ៉ាងច្បាស់លាស់ថា *ស៊ូរ៉* គឺអ្វីទេ ។ តើអាចប្រមើលគិតបានដូចម្ដេចទៅ កាលនោះ ថាព្រះសាស្ដាបានអនុវត្តិដើម្បីរៀបចំពួកមុស្លីមឲ្យត្រៀមខ្លួនទទួលប្រព័ន្ធ *ស៊ូរ៉* ហើយបានអប់រំមនុស្សជំនាន់ពួកមូហ្សាយ៊ីរីន និងពួកអាន់ស្វារដើម្បីជាអ្នកគ្រប់គ្រង់ព្រះប្រកាសិតតាមប្រព័ន្ធនេះ ថ្វីបើយើងមិនសម្គាល់ឃើញមានការអនុវត្តន៍ពេញស្មារតីទេ មិនឃើញមានមតិជាក់ច្បាស់អំពីប្រព័ន្ធនេះទេ នៅក្នុងជំនាន់នេះ ? ម្យ៉ាងទៀត គេមិនអាចប្រមើលគិតបានទេថាព្រះសាសនៈទូតបានចាត់តាំងឡើងនូវប្រព័ន្ធនេះ បានចាត់ចែងឲ្យមានការយល់ដឹងប្រព័ន្ធនេះនិងនីតិបញ្ញត្តិដោយពុំបានខិតខំអនុវត្តិ ដើម្បីរៀបចំពួកមុស្លីមឲ្យប្រុងខ្លួនប្រើប្រាស់ប្រព័ន្ធនេះទេនោះ ។

សេចក្ដីខាងលើនេះបញ្ជាក់ប្រាប់ថា ព្រះសាស្ដាពុំបានស្នើសូមឲ្យអ៊ុមម៉ាត់ប្រើប្រាស់ប្រព័ន្ធ *ស៊ូរ៉* ជាមធ្យោបាយស្នងអំណាចតពីព្រះអង្គទេ ។ ពីព្រោះតាមធម្មតា គម្រោងការសំខាន់បែបនេះត្រូវតែមានការពិភាក្សាគ្នាសមទៅតាមសារៈសំខាន់នៃគម្រោងការនោះ តែបែរជាពុំឃើញមានស្លាកស្នាមស្ដីអំពីរឿងនេះទៅវិញ ។

យើងសូមថ្លែងឡើងវិញចំណុចសំខាន់ៗ ដើម្បីពន្យល់ការរកហេតុផលរបស់យើងដូចតទៅគឺ៖

ក) សម្រាប់ពួកមុស្លីមសម័យនោះ ប្រព័ន្ធ *ស៊ូរ៉* ជាអ្វីដែលទំនើប ដែលមិនធ្លាប់ស្គាល់របបរដ្ឋាភិបាលដែលមានរចនាសម្ព័ន្ធ ។ ដូច្នេះចាំបាច់ត្រូវមានការឃោសនាយ៉ាងសកម្មដើម្បីឲ្យយល់ដឹងរឿងប្រព័ន្ធនេះ ដូចយើងបាន



ឆ្លុះបញ្ចាំងឲ្យឃើញការបំពាក់បំប៉នអប់រំផ្នែកសាសនាពិសេសនេះ ដែលបង្ហាញនូវស្លាកស្នាមនិងលទ្ធផល ។ ដូច្នេះ អ៊ុលីជាជម្រកនិងជាគំរូយ៉ាងច្បាស់ឥតប្រកែកបាន ស្ដេចខ៉ូលិហ្វរត់ទៅរកជម្រកនេះរាល់ពេលដែលជួបប្រទះបញ្ហាដែលពុំអាចដោះស្រាយបាន ។ នៅក្នុងប្រវត្តិសាស្ត្រអ៊ីស្លាម ក្រោមការគ្រប់គ្រងរបស់ស្ដេចខ៉ូលិហ្វទាំងបួនដែលបានទទួលការដឹកនាំល្អ[47] គេមិនដែលឃើញមានករណីណាមួយដែលអ៊ីម៉ាំអ៊ុលីសូមយោបល់ពីអ្នកផ្សេងទេ ថាតើអ៊ីស្លាមឲ្យធ្វើដូចម្ដេចខ្លះពាក់ព័ន្ធនឹងរឿងនេះមួយ រឿងនោះមួយនោះ ។ ផ្ទុយទៅវិញ គេអាចលើកយកមករៀបរាប់បានរាប់សិបករណី ដែលស្ដីអំពីស្ដេចខ៉ូលិហ្វគ្រងរាជ្យទាល់ចំណោះរត់ទៅរកអ៊ីម៉ាំអ៊ុលីសូមឲ្យជួយ ទោះបីពួកស្ដេចខ៉ូលិហ្វទាំងអស់នោះស្អប់ខ្ពើមធ្វើដូច្នេះក៏ដោយ ។

ភ័ស្ដុតាងច្រើនបង្ហាញថា ព្រះសាស្ដាបានបង្វឹកអ៊ីម៉ាំអ៊ុលីជាពិសេសដើម្បីប្រគល់ឲ្យអ៊ីម៉ាំអ៊ុលីនូវភារកិច្ចគ្រប់គ្រងព្រះប្រកាសិត ពេលអត់ពីព្រះអង្គរីឯភ័ស្ដុតាងបង្ហាញថា ព្រះសាសនៈទូតបានប្រកាសឲ្យដឹងជាសាធារណៈនូវផែនការព្រះអង្គ(ដើម្បីស្នងព្រះអង្គ) បានតែងតាំងជាសាធារណៈនិងតាមផ្លូវការអ៊ីម៉ាំអ៊ុលីដើម្បីគ្រប់គ្រងព្រះប្រកាសិតផ្នែកប្រាជ្ញា និងផ្នែកនយោបាយនោះក៏ច្រើនដែរ ។ កសិណសាក្សីរឿងនេះគឺហាឌីស្ស អាល់-ដ្វារ៍ (حديث الدار), ហាឌីស្ស អាល់-ស្វាក៏ឡៃន៍ (حديث الثقلين), ហាឌីស្ស អាល់-ម៉ាន់ស៊ីឡាស់ (حديث المنزلة), ហាឌីស្ស អាល់-ក៏ដៀរ (حديث الغدير)... និងច្រើនសិបហាឌីស្សព្រះសាស្ដាឯទៀត ។

[47] គឺ អាប៊ូ បាការ, អ៊ូម៉ារ, អ៊ុស្សម៉ាន, អ៊ុលី ។

សម្ងាត់ឲ្យអ៊ាលីដឹង ។"

នៅក្នុងសុន្នរកថាល្បីមួយ (យុត្តបាស្ទ័) អ៊ីម៉ាំបានរៀបរាប់ឲ្យយើងដឹងអំពីទំនាក់ទំនង ដែលមានតែមួយ គ្មានពីរ ជាមួយព្រះសាសនៈទូត-អគ្គប្រមុខ និងឲ្យដឹងអំពីការយកចិត្តទុកដាក់ពិសេសដែលព្រះអង្គអប់រំ និងបង្ហាត់បង្រៀនអ៊ីម៉ាំ (ដើម្បីគ្រប់គ្រងព្រះប្រកាសិត) ថា៖ "អស់លោកដឹងថាខ្ញុំជាប់សាច់សាលោហិតជិតស្និទ្ធជាមួយព្រះសាសនៈទូត ហើយស្គាល់ឋានៈពិសេសរបស់ខ្ញុំសម្រាប់ព្រះអង្គ ។ ព្រះអង្គបានចិញ្ចឹមខ្ញុំកាលខ្ញុំនៅតូច ។ ព្រះអង្គឱបខ្ញុំ ព្រះអង្គនៅអបអមខ្ញុំក្នុងគ្រែព្រះអង្គ ព្រះអង្គឲ្យខ្ញុំប៉ះខ្លួនព្រះអង្គ ឲ្យខ្ញុំហិតក្លិនព្រះអង្គ ។ ព្រះអង្គទំពាបាយបញ្ចុកខ្ញុំ ។ ព្រះអង្គមិនដែលឮខ្ញុំនិយាយកុហកឡើយ មិនដែលឃើញខ្ញុំប្រព្រឹត្តខុសឡើយ ។ ខ្ញុំតាមព្រះអង្គដូចកូនអូដ្ឋដើរតាមមេវា ។ រៀងរាល់ថ្ងៃព្រះអង្គបង្ហាត់ខ្ញុំឲ្យចេះដឹងសីលធម៌ព្រះអង្គបន្តិចម្ដងៗ ព្រះអង្គដាក់បង្គាប់ឲ្យខ្ញុំយកតម្រាប់តាមព្រះអង្គ ។ រៀងរាល់ឆ្នាំ ព្រះអង្គនាំខ្ញុំទៅហ៊ីរ៉អ៍ (حراء) ខ្ញុំមើលឃើញព្រះអង្គនៅទីនោះ ចំណែកឯមនុស្សឯទៀតមើលមិនឃើញព្រះអង្គទេ ។ សម័យនោះ អ៊ីស្លាមប្រមូលផ្ដុំសាសនៈទូត ខ៏ឌីយ៉ាស្ទ័ និងខ្ញុំ បុគ្គលទីបីនៅក្រោមដំបូលតែមួយ ។ នៅក្រោមដំបូលនេះ ខ្ញុំបានឃើញពន្លឺវ៉ាហ៊ីនិងពន្លឺព្រះសាស្ដា ហើយខ្ញុំបានស្គាល់ខ្យល់នៃសាស្ដាភាពនៅក្រោមដំបូលនេះ ។"

ព័ត៌មានថ្លែងហេតុការណ៍ទាំងនេះ និងច្រើនទៀតសឲ្យយើងឃើញការបំពាក់បំប៉នអប់រំផ្នែកសាសនា ដែលព្រះសាស្ដាបានផ្ដល់ឲ្យអ៊ីម៉ាំអ៊ាលីដើម្បីឲ្យបានដល់កម្រិតសមត្ថភាពគ្រប់គ្រងព្រះប្រកាសិត ។ ដូចនេះដែរអត់ពីព្រះសាសនៈទូតទៅ ជីវិតរបស់អ៊ីម៉ាំអ៊ាលីផ្ដល់ឲ្យនូវភ័ស្តុតាងច្រើន



អធិប្បាយខាងលើហើយ ។

ខ) *ស៊ូរ៉* ដែលជាទស្សនៈនោះ ពិបាកយល់បន្តិច ។ ដើម្បីដាក់ឲ្យអនុវត្តិមិនគ្រប់គ្រាន់ទេបើត្រឹមតែប្រកាសដោយគ្មានការអធិប្បាយណែនាំ ឲ្យយល់សេចក្ដីលំអិត យល់របៀបរបបនិងលក្ខណៈវិនិច្ឆ័យដែលធ្វើឲ្យមានតុល្យភាពធ្ងន់ម្ខាង ឬស្រាលម្ខាងក្នុងករណីមិនស្របមតិគ្នាក្នុង *ស៊ូរ៉* ហើយដោយគ្មានការបញ្ជាក់ច្បាស់លាស់ថា តើលក្ខណៈវិនិច្ឆ័យនេះចាំបាច់ត្រូវតែស្ថិតនៅលើចំនួននិងបរិមាណ ឬស្ថិតនៅលើគុណសម្បត្តិនិងបទពិសោធន៍ ។ សេចក្ដីអធិប្បាយច្រើនទៀតដែលកំណត់ចំណុចផ្សេងនៃទស្សនៈ *ស៊ូរ៉* នេះ ដែលអាចធ្វើឲ្យ *ស៊ូរ៉* នេះស្រួលប្រើហើយអាចអនុវត្តិតាមបានភ្លាមៗក្រោយពីព្រះសាស្ដាចូលទិវង្គត ចាំបាច់ត្រូវបានគេថ្លែងបញ្ជាក់ឲ្យដឹងយ៉ាងច្បាស់លាស់ ប្រសិនបើព្រះមគ្គទេសក៍ព្រះប្រកាសិតបានផ្សាយឲ្យដឹង បានជ្រើសរើសយកទស្សនៈនេះដើម្បីដោះស្រាយបញ្ហាស្នងអំណាចតពីព្រះអង្គនោះមែន ។

គ) ការពិត *ស៊ូរ៉* ជាការបកស្រាយឲ្យឃើញនូវការប្រើអំណាចមួយបែបផ្សេងដោយអ៊ុមម៉ាត្ទ័ និងជាការបកស្រាយឲ្យឃើញនូវការកំណត់ជោគវាសនារបស់រដ្ឋាភិបាលដោយការពិភាក្សា ។ ដូច្នេះ នេះជាភារកិច្ចដែលប្រជារាស្ត្រភាគច្រើនចាំបាច់ត្រូវអនុវត្តិ ពោលគឺ ជនទាំងអស់ដែលទាក់ទងនឹង *ស៊ូរ៉* បានសេចក្ដីថាបើ *ស៊ូរ៉* ជាបញ្ញត្តិចែងឲ្យធ្វើតាមជាធរមានសម្រាប់ដាក់ឲ្យអនុវត្តិតាមក្រោយពីព្រះសាស្ដាចូលទិវង្គតនោះមែន ប្រជារាស្ត្រភាគច្រើនទាំងនោះប្រាកដជាបានដឹងឮ ពីព្រោះពួកគេមានកាតព្វកិច្ចចូលរួមយ៉ាងសកម្មក្នុង *ស៊ូរ៉* នេះជាចាំបាច់ ហើយរាល់គ្នាចាំបាច់ត្រូវទទួលខុសត្រូវក្នុងរឿងនេះ ។

ខទាំងនេះបញ្ជាក់ប្រាប់ថាប្រសិនបើព្រះសាស្តាបានជ្រើសយកប្រព័ន្ធ *ស្ហ៊ូរ៉* ជាមធ្យោបាយសម្រាប់ដឹកនាំអ៊ុមម៉ាត់ ក្រោយពីព្រះអង្គចូលទិវង្គតនោះមែន ព្រះអង្គចាំបាច់ត្រូវផ្សាយជាទូទៅនិងយ៉ាងជ្រាលជ្រៅពេញទំហឹងនូវទស្សនៈ *ស្ហ៊ូរ៉* នេះ ចាំបាច់ត្រូវរៀបចំប្រជារាស្ត្រទាំងអស់ឲ្យប្រុងប្រៀបខ្លួនផ្លូវអារម្មណ៍ ចាំបាច់ត្រូវពង្រឹងចំណុចខ្សោយ ចាំបាច់ត្រូវពន្យល់គ្រប់រឿងពាក់ព័ន្ធនឹង *ស្ហ៊ូរ៉* ដើម្បីងាយស្រួលប្រើ ។ តែមិនអាចកើតមានឡើងបានទេដែលព្រះសាស្តាផ្សាយទស្សនៈ *ស្ហ៊ូរ៉* ដ៏ធំបែបនេះ - យ៉ាងជ្រាលជ្រៅពេញទំហឹង យ៉ាងល្អនិងយ៉ាងច្រើន - ហើយមិនមានសល់នូវស្លាកស្នាមទស្សនៈ *ស្ហ៊ូរ៉* នេះឡើយនៅលើរូបពួកមុស្លីមដែលបានរស់នៅជាមួយព្រះសាស្តារហូតដល់ព្រះអង្គចូលទិវង្គត ។

គេអាចធ្វើសម្មតិកម្មមួយទៀតបានអំពីរឿងនេះ ពោលគឺ ព្រះសាស្តាអាចផ្សាយទស្សនៈ *ស្ហ៊ូរ៉* យ៉ាងធំនិងយ៉ាងពាសពេញតម្រូវតាមស្ថានភាព ហើយវាបានជ្រួតជ្រាបទៅក្នុងខួរក្បាលពួកមុស្លីមយ៉ាងល្អមែន តែហេតុការណ៍នយោបាយកើតឡើងយ៉ាងទាន់ហាន់បានបំបិទរឿងពិត ដាក់កំហិតហាមមនុស្សបើកឲ្យគេដឹងរឿង ដែលខ្លួនបានដឹងឮពីព្រះសាស្តាពាក់ព័ន្ធនឹង *ស្ហ៊ូរ៉* លក្ខខណ្ឌនិងសេចក្តីលំអិតរបស់ *ស្ហ៊ូរ៉* នោះ ។

តែសម្មតិកម្មបែបនេះទទួលបរាជ័យក្រោមការពិនិត្យពិច័យ ពីព្រោះមូលហេតុដែលជម្រុញឲ្យធ្វើបែបនេះ ទោះជាថាយ៉ាងក៏ដោយ ក៏វាមិនរាប់បញ្ចូលបណ្តាសាវក ដែលមិនបានចូលរួមក្នុងព្រឹត្តិការណ៍នយោបាយដែលបានកើតឡើងក្រោយពីព្រះសាស្តាបានចូលទិវង្គតនោះទេ ហើយក៏មិនបានចូលរួមក្នុងការប្រជុំនៅសាគីហ្វាស្ទ័ទេ ។ បណ្តាសាវកទាំងនោះ



គេបានចាត់ទុកសម្តីទាំងនេះជាសម្តីរបស់អ៊ីម៉ាំអាលីដែរ គឺ៖ "ខ្ញុំមានឯកសិទ្ធិពីរសម្រាប់ចូលផ្ទះព្រះសាស្តា ឯកសិទ្ធិមួយក្នុងពេលយប់ ឯកសិទ្ធិមួយទៀតក្នុងពេលថ្ងៃ ។"

អាល់-នីសាអ៊ី (النسائي) បានលើកយកសម្តីមួយទៀតរបស់អ៊ីម៉ាំអាលី គឺ៖ "បើខ្ញុំសួរព្រះសាស្តា ព្រះអង្គឆ្លើយតបខ្ញុំ ។ បើខ្ញុំមិននិយាយទេ ព្រះអង្គជាអ្នកចាប់ផ្តើម[បង្ហាត់បង្រៀនខ្ញុំ] ។[46]" អាល់-ហ្គាគីមបានធ្វើសេចក្តីរាយការណ៍ដូចនេះដែរ ។

យោលតាមអាល់-នីសាអ៊ី (النسائي) ទៀត អ៊ូម សាឡាម៉ាស្ទ័បានស្បថថា អាលីជាមុស្លីមចុងក្រោយបង្អស់ដែលបានឃើញព្រះសាស្តា ហើយព្រះនាងអ៊ូម សាឡាម៉ាស្ទ័មានសវនីយ៍ថា៖ "ព្រឹកថ្ងៃព្រះសាសនៈទូតចូលទិវង្គត ព្រះអង្គរង់ចាំអាលីត្រឡប់មកវិញ ។ ព្រះអង្គបានចាត់បញ្ជូនទៅបំពេញបេសកកម្មមួយ តាមខ្ញុំដឹង ព្រះអង្គបានសួរបីដងថា៖ "អាលីមកវិញហើយឬនៅ ?" អាលីបានមកដល់វិញមុនថ្ងៃរះ ។ លុះអាលីចូលជួបយើងយល់ថាព្រះសាស្តាមានរឿងសម្ងាត់ប្រាប់អាលី ។ ដូច្នេះហើយបានជាយើងចេញពីក្នុងផ្ទះ ។ កាលនោះគឺនៅឯផ្ទះរបស់អ៊ែស្ហាស្ទ័ ។ ខ្ញុំបានចេញពីផ្ទះក្រោយគេ ។ ខ្ញុំបានអង្គុយពីក្រោយទ្វារ ។ ក្នុងចំណោមអ្នកជំនួយទាំងអស់ ខ្ញុំនៅជិតទ្វារជាងគេ ។ ខ្ញុំបានឃើញអាលីចូលទៅជិតព្រះអង្គ ។ អាលីជាបុគ្គលចុងក្រោយបង្អស់ដែលបានជួបព្រះសាស្តា ។ ព្រះសាស្តាបានប្រាប់អាថ៌កំបាំងព្រះអង្គឲ្យអាលីដឹង ហើយបានប្រាប់រឿង

46 កំណាត់របស់អ្នកបកប្រែ ។

មកពិភាក្សាពេលណាអ៊ុលីមិនមានសំណួរសួរព្រះអង្គ ។ ព្រះសាស្ដាសន្ទនាជាមួយអ៊ុលីច្រើនម៉ោង ដើម្បីធ្វើឲ្យអ៊ុលីយល់គំនិតព្រះប្រកាសិត និងបញ្ហាដែលព្រះប្រកាសិតអាចជួបប្រទះ និងយល់វិធីប្រកបកិច្ចការនានា... ព្រះសាស្ដាតែងតែធ្វើដូច្នេះលុះដល់អវសានព្រះជន្មដ៏ថ្លៃថ្នូរ ។

អាល់-ហ៊ាគីម (الحاكم) បានថ្លែងនៅក្នុងតម្រាលោក "អាល់-មុសតាដ្រ៉ក់ (الْمُسْتَدْرَك)"តមកពី អាប៊ូ អ៊ីសហ៊ាក់ (أبو إسحاق) ដែលបានថ្លែងអំពីរឿងនេះថា៖ "កាលខ្ញុំបានសួរគ្គុស្នាំ អ៊ីបនូ អាល់-អ៊ុប់បាស់ (قُثَم بن العباس) ថាតើអ៊ុលីបានស្នងព្រះសាស្ដាដូចម្ដេច ? លោកបានប្រាប់ខ្ញុំថា៖ "ពីព្រោះអ៊ុលីជាបុគ្គលដំបូងបង្អស់ ក្នុងចំណោមអស់ទាំងយើង ដែលតាមព្រះសាស្ដា ហើយជាបុគ្គលប្ដេជ្ញាចិត្តតោងព្រះសាស្ដាជាប់ជាទីបំផុត ។""

ហ៊្វលីយ៉ាស្ទ អាល់-អៅលីយ៉ាអ៊្ (حلية الأولياء) បាននាំមកនូវសេចក្ដីរាយការណ៍របស់អ៊ីបនូ អ៊ុប់បាស់ថា៖ "យើងសូមប្រាប់ថា ព្រះសាស្ដាបានប្រាប់អ៊ុលីនូវការសម្ងាត់ចិតសិបដែលព្រះអង្គមិនប្រាប់អ្នកណាឡើយ ។"

អាល់-នីសាអ៊ី (النسائي) បានលើកយកសេចក្ដីរាយការណ៍របស់អ៊ីម៉ាំអ៊ុលីតមកពីអ៊ីបនូ អ៊ុប់បាស់ថា៖ "សម្រាប់ព្រះសាសនៈទូតអល់ឡោះហ៍ ខ្ញុំមានឋានៈមួយដែលពុំមានអ្នកណាមាន ។ ខ្ញុំបានទៅជួបព្រះសាស្ដារាល់យប់ ។ បើព្រះអង្គកំពុងតែស្ញ៍ឡាត់ ព្រះអង្គថ្វាយសេចក្ដីរុងរឿងចំពោះអល់ឡោះហ៍[45] ហើយខ្ញុំចូល ។ បើព្រះអង្គមិនកំពុងស្ញ៍ឡាត់ទេ ព្រះអង្គអញ្ជើញខ្ញុំចូល ។"

[45] ពោលគឺ ដើម្បីអនុញ្ញាតឲ្យខ្ញុំចូលជួបដោយព្រះអង្គមិនផ្អាកស្ញ៍ឡាត់ ។



បានដកខ្លួនឆ្ងាយពីព្រឹត្តិការណ៍ទាំងនេះ ។ បើនិយាយអំពីចំនួន មុស្លីមទាំងនេះជាភាគធំនៃគ្រប់សង្គម ទោះជាសង្គមទាំងនោះមានកម្រិតនយោបាយប៉ុណ្ណាក៏ដោយ ។ ប្រសិនបើទស្សនៈ *ស៊្ទីរ៉* ត្រូវផ្សាយដោយព្រះសាស្ដាតាមវិធានការដែលយើងបានបញ្ជាក់ហើយនោះមែន វាប្រាកដជាមិនមានលាក់ទុកនូវឆន្ទៈនយោបាយទេ តែវាប្រាកដជាសាយចេញទៅជាធម្មតាតាមរយៈបណ្ដាសាវក ដូចព្រះវចនៈព្រះសាស្ដាដែលថ្លែងអំពីគុណសម្បត្តិរបស់អ៊ីម៉ាំអ៊ុលី ព្រមទាំងលក្ខណៈសម្បត្តិព្រះអង្គជាព្រះរាជានុសិទ្ធិ (وصي គឺអ្នកស្នងរាជ្យតពីព្រះសាស្ដា) លេចឮតាមបណ្ដាសាវកទាំងនេះនោះដែរ ។ ហេតុអ្វីឆន្ទៈនយោបាយមិនរាំងរាហ៊ាឌីស្ទរាប់រយរបស់ព្រះសាស្ដា ដែលស្ដីអំពីគុណសម្បត្តិរបស់អ៊ុលី អំពីឋានៈជាព្រះរាជានុសិទ្ធិនិងអាជ្ញាធររបស់អ៊ុលី មិនឲ្យលេចឮមកដល់យើងតាមរយៈបណ្ដាសាវក ទោះបីហ៊ាឌីស្ទទាំងនេះពុំផ្ដល់ផលប្រយោជន៍ល្អដល់ស្ថានការណ៍ធំសម័យនោះឡើយក្ដី តែឆន្ទៈនយោបាយនោះបែរជារាំងហ៊ាឌីស្ទទាក់ទងនឹងទស្សនៈ *ស៊្ទីរ៉* មិនឲ្យបានមកដល់យើងវិញ ! តើនេះមិនមែនមតិផ្ទុយពីធម្មតាដែលមិនអាចអត់ទ្រាំបានទេ ! អស្ចារ្យលើសពីនេះ សូម្បីតែបណ្ដាអ្នកដែលជាតំណាងនិន្នាការធំជាងគេសម័យមុននោះក៏ពុំបានលើកយកពាក្យស៊្ទីរ៉មកប្រើជាសំអាងទេដែរ ដែលជាស្នាដៃរបស់ព្រះសាស្ដានោះ ពេលពួកគេប្រឆាំងគ្នាជាញឹកញយដោយសារតែខ្វែងមតិនយោបាយខណៈពួកគេកំពុងស្ថិតនៅក្នុងស្ថានភាពមួយ ដែលលើកយកពាក្យនេះមកប្រើអាចធ្វើឲ្យពួកគេមានប្រៀបលើគេ ។ យើងសូមលើកយកឧទាហរណ៍មួយមកអធិប្បាយ ។ ត្តុល់ហ៊ាស្ទ៉បានប្រឆាំងការតែងតាំងអ៊ុម៉ារជាអ្នកស្នងអំណាចដោយអាប៊ូ បាការ ហើយបានសម្ដែងការមិនពេញចិត្តជាសារធារណៈ ប៉ុន្តែលោកមិនបានលើកយក *ស៊្ទីរ៉* មកប្រើទេ ដើម្បីប្រឆាំងការតែងតាំងនេះ ដោយបញ្ជាក់ឲ្យឃើញថាអាកប្បកិរិយា

របស់អាប៊ូ បាការផ្ទុយពីហ្វាឌីស្សព្រះសាស្តាពាក់ព័ន្ធនឹង *ស៊ូរ៉* និងការជ្រើសរើស ។ ប្រសិនបើពាក្យសំអាងបែបនេះមានមូលដ្ឋានមាំមួន (គឺជាការពិតមែន) តើលោកតូល់ហ្វាស្ស៍អាចខកខានលើកយកវាមកប្រើបានទេ ?

II) ប្រសិនបើព្រះសាស្តាបានសម្រេចព្រះហឫទ័យ ផ្ទេរភារកិច្ចបន្តសកម្មភាពផ្លាស់ប្តូរក្នុងសាសនាអ៊ីស្លាមឲ្យទៅបុគ្គលជំនាន់មុនមែន ដែលរួមមានពួកភៀសខ្លួន (គឺពួកមូហ្វាឃ្ជីរីន) និងពួកអ្នកគាំទ្រ (គឺពួកអាន់ស្វារ) ដែលជាសាវកនោះ ព្រះអង្គចាំបាច់ត្រូវកែនមនុស្សជំនាន់នេះយ៉ាងច្រើនមកហ្វឹកហ្វឺនទាំងផ្នែកសាសនា ទាំងផ្នែកប្រាជ្ញាដើម្បីនឹងឲ្យមនុស្សជំនាន់នេះស្ទាត់ជំនាញផ្នែកទ្រឹស្តី[សាសនាអ៊ីស្លាម] ហើយចេះប្រែទ្រឹស្តីទាំងនេះជាទង្វើនៅពេលក្រោយយ៉ាងប្រុងប្រយ័ត្ន ចេះរកមធ្យោបាយស្របតាមព្រះរាជសារ ដើម្បីដោះស្រាយបញ្ហានានាដែលព្រះប្រកាសិតនឹងជួបប្រទះជាដរាបរៀងទៅ ។ សកម្មភាពកំណែនយ៉ាងពេញទំហឹងនិងទូទៅបែបនេះទើបចាំបាច់ជាងគេជ្បិតព្រះសាស្តា ដែលបានទាយទុកមុនថាអាណាចក្រព្រះចៅអធិរាជកយ់ស្វារ (قيصر Caesar) និងព្រះចៅអធិរាជគូរូស្ស (كورش cyrus) នឹងរលំនោះ បានដឹងច្បាស់ថាព្រះប្រការសិតនឹងនាំមកនូវចម្បាំងច្រើន ដូច្នេះអ៊ុមម៉ាត់ត្រូវត្រៀមខ្លួនបំពេញភារកិច្ចបង្ហាត់បង្រៀនប្រជារាស្ត្រដែលច្បាំងចាញ់អ៊ីស្លាម ត្រូវការពារខ្លួនទល់នឹងគ្រោះថ្នាក់ដែលកើតមានឡើងមកពីចេញមុខទៅរកពិភពលោកនេះ ត្រូវប្រើបញ្ញត្តិនីតិអ៊ីស្លាមក្នុងប្រទេសដែលវាយយកបាន និងចំពោះប្រជារាស្ត្រប្រទេសទាំងនោះ ។ ក៏ប៉ុន្តែ ទោះបីមនុស្សជំនាន់មុនទៀងត្រង់ជាងគេក្នុងចំណោមជំនាន់មនុស្ស ដែលបានទទួលព្រះប្រកាសិតជាកេរដំណែលជាបន្តបន្ទាប់ក្រោយៗមក ហើយព្រមលះបង់ជាងគេក្នុងចំណោមជំនាន់មនុស្សទាំងនោះក៏ដោយ ក៏គេពុំឃើញមានស្រមោលនៃការប្រុងប្រៀប



ហ្វាឌីស្សព្រះសាស្តាត្រូវគ្នា(នឹងមធ្យោបាយទីបីនេះ) ដែលអះអាងថាព្រះអង្គបានធ្វើការបំពាក់បំប៉ន អប់រំសាវកម្នាក់ផ្នែកសាសនាដោយផ្ទាល់ ហើយបានធ្វើការបំពាក់បំប៉នបណ្តុះបណ្តាលផ្នែកទ្រឹស្តីជាពិសេស ដើម្បីនឹងរៀបចំខ្លួនសាវកនេះទទួលភារកិច្ចអាជ្ញាធរផ្នែកប្រាជ្ញា (ជាគំរូប្រាជ្ញាជាន់ខ្ពស់) និងទទួលភារកិច្ចគ្រប់គ្រងផ្នែកនយោបាយ(នៃវិសោធនការ) ហើយព្រះអង្គបានប្រគល់ភារកិច្ចនេះ ព្រមទាំងអនាគតព្រះប្រកាសិតឲ្យទៅសាវករូបនេះនោះ សឲ្យឃើញថាព្រះសាស្តា-មគ្គទេសក៍បានជ្រើសរើសយកមធ្យោបាយ (ឬមាគ៌ា) ទីបី ដូចយើងបានដឹងស្រាប់ហើយ ជាមធ្យោបាយតែមួយគត់ដែលមានសុពលភាព (គឺបានការ) ដែលស្ថានការប្រភេទនេះទាមទារ ។

សាវកដែលកំពុងនិយាយដល់នេះពុំមែនអ្នកណាក្រៅពីអ៊ុលី អ៊ីបនូ អាប៊ីត៌លិបទេ ដែលត្រូវតែងតាំងឡើងដោយហេតុព្រះអង្គចាក់ឫសយ៉ាងជ្រាលជ្រៅនៅក្នុងព្រះប្រកាសិត ព្រោះព្រះអង្គជាបុគ្គលដំបូងបង្អស់ដែលប្រយុទ្ធដើម្បីអ៊ីស្លាមទល់នឹងសត្រូវទាំងអស់របស់អ៊ីស្លាម ព្រះអង្គត្រូវព្រះសាស្តាចិញ្ចឹម ហើយបានបែរមុខទៅរកពិភពលោកនៅឯផ្ទះព្រះសាស្តា ព្រះអង្គធាត់ធំនៅក្បែរព្រះសាស្តា ជិតស្និទ្ធជាមួយព្រះសាស្តាគ្រប់ពេលវេលា ហើយព្រះអង្គយល់ខ្សែបន្ទាត់ព្រះសាស្តា ។ ក្រៅពីអ៊ុលីពុំមានអ្នកណាអាចមានគុណសម្បត្តិទាំងនេះទេ ។

ភ័ស្តុតាងច្រើនបញ្ជាក់បន្ថែមពីលើអំណះអំណាងថា ព្រះសាស្តាព្យាយាមផ្តល់ការបំពាក់បំប៉នអប់រំផ្នែកសាសនាដល់អនាគតអ៊ីម៉ាំអ៊ុលី ។ ដូច្នេះ គេដឹងថាព្រះសាសនៈទូតបានពន្យល់អ៊ុលីជាញឹកញយអំពីទស្សនៈ និងការពិតនានានៃព្រះប្រកាសិត ។ ព្រះអង្គផ្តើមគំនិតយករឿងឬគំនិតណាមួយ

ក្នុងចំណោមមធ្យោបាយទាំងបីដែលលេចឡើងសម្រាប់ព្រះសាស្ដា មានតែមធ្យោបាយទីបីនេះទេដែលទំនងជាត្រូវនឹងប្រភេទស្ថានភាពជាង សមហេតុផលជាងដោយមើលកាលៈទេសៈព្រះប្រកាសិត និងអ្នកតាមព្រះប្រកាសិតនេះ ហើយសមរម្យនឹងគោលជំហររបស់ព្រះសាសនៈទូត ។ មធ្យោបាយទីបី សម្រាប់ព្រះសាស្ដា គឺជ្រើសយកគោលជំហរសកម្ម[44]រឿងអនាគតព្រះប្រកាសិតក្រោយពីព្រះអង្គចូលទិវង្គត ដោយតែងតាំង តាមព្រះបញ្ញាអល់ឡោះហ៍ នូវមនុស្សម្នាក់ដែលត្រូវជ្រើសរើសអាស្រ័យលើការយល់ដឹងអង្គភាពប្រកាសិតយ៉ាងជ្រួតជ្រាបឥតទាស់ និងដោយបំពាក់បំប៉នអប់រំមនុស្សនេះយ៉ាងពិសេសឲ្យទៅជាអ្នកគ្រប់គ្រង ដឹកនាំសាសនា ដើម្បីនឹងឲ្យមនុស្សនេះអាចទៅជាតំណាងអាជ្ញាធរផ្នែកប្រាជ្ញា និងជាតំណាងការដឹកនាំផ្នែកនយោបាយនៃវិសោធនការបាន ដើម្បីនឹងឲ្យមនុស្សនេះអាចបន្ត (អត់ពីព្រះសាសនៈទូតទៅ) ការគ្រប់គ្រងអ៊ុមម៉ាត្ហ៍បាន ដោយមានការគាំទ្រពីសំណាក់ប្រជារាស្ត្រ ដែលប្រកបដោយសម្បជញ្ញៈ រួមមានពួកអាន់ស្វារនិងពួកមូហាជ្ជីរីន ហើយអាចបន្តការលើកស្ទួយលទ្ធិនៃអ៊ុមម៉ាត្ហ៍នេះបាន ដើម្បីនឹងឲ្យអ៊ុមម៉ាត្ហ៍នេះឈានដល់កម្រិតមួយដែលអាចទទួលភារកិច្ចគ្រប់គ្រងដោយខ្លួនឯងបាន ។

មធ្យោបាយទីបីនេះ ដូចបានឃើញស្រាប់ហើយ ជាមធ្យោបាយមួយគត់ដែលអាចអភិរក្សអនាគតព្រះប្រកាសិត និងការពារវិសោធនការកុំឲ្យលម្អៀងបាននៅលើខ្សែបន្ទាត់អភិវឌ្ឍន៍របស់វា ។ នេះគឺអ្វីដែលបានកើតឡើងមែន ។

[44] ពោលគឺ ចុះដៃប្រតិបត្តិការ មិននៅស្ងៀមក្នុងរឿងអនាគតព្រះប្រកាសិតទេ ។



ពិសេសទេ ដែលអាចធ្វើឲ្យមនុស្សជំនាន់មុននោះមានសមត្ថភាពទទួលខុសត្រូវព្រះប្រកាសិតបាន ហើយអាចយល់បានយ៉ាងជ្រាលជ្រៅនូវទស្សនៈប្រកាសិតនោះ ។

សូមកត់សម្គាល់អំពីរឿងនេះថា ចំនួនហាឌីស្សព្រះសាស្ដាដែលបណ្ដាសាវកបានធ្វើសេចក្ដីរាយការណ៍ទាក់ទងនឹងវិស័យច្បាប់នោះ សរុបមិនលើសពីពីរបីរយទេ ចំណែកឯចំនួនសាវកវិញ យោលតាមតម្រាប្រវត្តិសាស្ត្រ មានប្រមាណ ១២០០០ នាក់ដែលបានរស់នៅជាមួយព្រះសាស្ដាទាំងយប់ទាំងថ្ងៃក្នុងស្រុកតែមួយនិងក្នុងម៉ាស់ជ្ជិដតែមួយ ។ ពេលគេធ្វើការប្រៀបធៀបតួលេខទាំងពីរនេះ តើគេអាចសង្កេតឃើញមានសញ្ញាបញ្ជាក់ប្រាប់ថាមានការប្រុងប្រៀបពិសេស ដើម្បីគ្រប់គ្រងអំណាចអ៊ីស្លាមទេ ?[27]

សូមលើកឡើងនូវឧទាហរណ៍មួយទៀត ដែលបំភ្លឺបន្ថែមពីលើការអះអាងរបស់យើងដែលថាគ្មានការរៀបចំបែបនេះទេនោះ ។ ការពិតគេដឹងថា

[27] ហាឌីស្សព្រះសាស្ដាគឺសម្ដីណាមួយដែលព្រះសាស្ដាបានថា នៅចំពោះមុខបណ្ដាសាសនិកជន សាសនិកជនទាំងនេះបានចងចាំសម្ដីនោះទុកអនុវត្តិតាម ។ ដូច្នេះ បើព្រះសាស្ដាបានបង្កើតយុទ្ធនាការអប់រំនិងឃោសនា ដើម្បីរៀបចំសាវកចំនួន ១២០០០ នាក់ឲ្យប្រុងប្រៀបខ្លួនទទួលភារកិច្ចដឹកនាំរដ្ឋអ៊ីស្លាមមែននោះព្រះអង្គប្រាកដជាបានថ្លែងអំពីច្បាប់អ៊ីស្លាមរឿងរដ្ឋាភិបាល វែងជាងហាឌីស្សពីរបីរយនោះដែលកំពុងសង្ស័យនោះទៅទៀត ហើយប្រាកដជាមានសម្ដីយ៉ាងច្រើនដែលព្រះសាស្ដាបានថានោះ បើផ្ដោតទៅលើសារៈសំខាន់របស់រឿងនេះ ទៅលើចំនួនសាវកយ៉ាងច្រើននោះដែលអាចចងចាំសម្ដីទាំងនេះបាន ទៅលើពេលវេលាដែលព្រះសាស្ដាចំណាយសម្រាប់ពួកគេទាំងនេះ ។ កំណត់របស់អ្នកបកប្រែ ។

បណ្ដាសាវកចៀសវាងចេញមុខសួរព្រះសាស្ដា ដល់ថ្នាក់លុះសាវកណាមួយចង់សន្ទនាជាមួយព្រះអង្គអំពីរឿងមួយ សាវករូបនោះពឹងអ្នកដែលមកសូមជួបព្រះសាស្ដា (គឺបុរសអាក្រ៉ូប៊ដែលមកពីក្រៅស្រុក) សង្ឃឹមថាអ្នកនោះនឹងសួរសំណួរដែលខ្លួនចង់សួរដើម្បីនឹងដឹងចម្លើយ ។ ពួកសាវកទាំងនោះយល់ឃើញថា សួរអំពីការដោះស្រាយបញ្ហាដែលមិនទាន់កើតឡើងទេនោះជាការឥតប្រយោជន៍ ។ សម្ដីខាងក្រោមនេះដែលអ៊ូម៉ារបានថ្លែងពីលើវេទិកាជាភ័ស្ដុតាងបញ្ជាក់ចំណុចនេះ គឺ៖

"សូមស្បថចំពោះអល់ឡោះហ្វ៍ ខ្ញុំហាមសួរអំពីអ្វីដែលមិនកើតមានឡើង ព្រោះព្រះសាស្ដាបានពន្យល់អំពីអ្វីដែលកើតមានស្រាប់ហើយ ។[28]" "មិនអនុញ្ញាតឲ្យសាកសួរអំពីអ្វីដែលមិនកើតមាននោះទេ ។ អល់ឡោះហ្វ៍បានសម្រេចអ្វីដែលកើតមានហើយ ។"

អ៊ីបនូ អ៊ូម៉ារបានឆ្លើយតបបុរសម្នាក់ដែលបានមកសួរលោកអំពីបញ្ហាមួយថា៖ "កុំសួរអំពីរឿងដែលមិនបានកើតឡើង ព្រោះខ្ញុំបានឮអ៊ូម៉ារ អ៊ីបនូអាល់-ខុត្ត៍ត្វប់ដាក់បណ្ដាសាបុគ្គលដែលសួរអំពីរឿង ដែលមិនទាន់កើតឡើងនៅឡើយ ។"[29]

ដូចនេះដែរ លុះគេបានសួរអាប៊ី ប៊ិន កាអ៊្កប់ (أبي بن كعب) អំពីរឿងមួយលោកបានតបថា៖ "រឿងដែលលោកសួរខ្ញុំនោះកើតឡើងហើយឬនៅ ?" អ្នកនោះបានតបថា៖ "មិនទាន់កើតឡើងទេ ។" "សូមរង់ចាំឲ្យរឿងនោះ

[28] ស៊ូណាន់ អាល់-ដ្ខារ៉ាមី (سنن الدارمي), ក្បាលទី ១ ទំព័រ ៥០ ។

[29] ដូច 25 ដែរ ។



សត្រូវចាស់របស់អ៊ីស្លាម - តែលើកនេះវាយប្រហារពីខាងក្នុង ពុំមែនពីខាងក្រៅព្រះប្រកាសិតទេ - ពួកសត្រូវដែលបានលបចូលបន្ដិចម្ដងៗទៅក្នុងមណ្ឌលអំណាចហើយបានឆក់យកការគ្រប់គ្រងយ៉ាងព្រហើន និងឃោរឃៅពេលគណៈដឹកនាំធ្វេសស្មារតី ។ ពួកសត្រូវប្រញាប់បង្ខំអ៊ុមម៉ាត់ព្រមទាំងបណ្ដាអ្នកជំនាន់មុនឲ្យលះបង់ចោលឥស្សរជនភាព និងការដឹកអ៊ុមម៉ាត់នោះ ។ បន្ទាប់មក ការដឹកនាំព្រះរាជសារក្លាយទៅជាកម្មសិទ្ធិស្ងួពូជ (ដែលបង្អាប់សេចក្ដីថ្នូររបស់អ្នកមានសទ្ធា កាប់សម្លាប់ជនស្លូតត្រង់បំផ្លាញទ្រព្យរបស់អ៊ុមម៉ាត់ ព្យូរទណ្ឌកម្មស្របច្បាប់ ធ្វើឲ្យប្រព័ន្ធច្បាប់គាំងកាន់ក្ដាប់ដោគវាសនាពួកមុស្លីមតាមតែក្បាលចិត្ត) ទ្រព្យដែលវាយបានមកពីសត្រូវនិងទ្រព្យសម្បត្តិសាធារណៈ ទៅជាកម្មសិទ្ធិឯកជនរបស់ពួកគួរ៉យ់ស្ទ៍ ខ៊្លីហ្វាស្វ៊ក្លាយទៅជាបាល់ដែលពួកកូនក្មេងអ្វម៉ៃយ៉ាស្វ៊លេង ។

ដូច្នេះ វិសោធនការព្រះប្រកាសិតក្រោយពីព្រះសាស្ដាបានចូលទិវង្គតនិងលទ្ធផលដែលបានឈានទៅដល់ម្ភៃប្រាំឆ្នាំក្រោយមកនោះ បញ្ជាក់អះអាងបន្ថែម ។
សេចក្ដីសម្រេចដែលយើងបានដកស្រង់ឡើងខាងលើនេះ ដែលថា៖ "ប្រគល់ការគ្រប់គ្រង" (ឬអ៊ីម៉ាម៉ាស្វ៊) ផ្នែកប្រាជ្ញានិងផ្នែកនយោបាយឲ្យទៅមនុស្សជំនាន់អាន់ស្វ៊ារនិងមូហ្វាយ៊ីរីន ក្រោយពីព្រះសាស្ដាបានចូលទិវង្គតភ្លាម ជាវិធានការតក់ក្រហល់ពេក ។ អាស្រ័យហេតុនេះ មិនសមហេតុផលទេ ដែលគិតថាព្រះសាស្ដាបានជ្រើសយកវិធានការបែបនេះ ។

## មធ្យោបាយទី ៣

នេះមិនគ្រប់គ្រាន់ទេ ដើម្បីអប់រំជំនាន់មនុស្សដែលបានរស់នៅតែដប់ឆ្នាំក្នុងវិសោធនការកែប្រែ ឲ្យមានកម្រិតសម្បជញ្ញៈ ឲ្យមានកម្រិតវត្ថុវិស័យភាព (គឺមានលក្ខណៈស្របតាមការពិត) ឲ្យមានកម្រិតសេរីភាពពីសំណល់អតីតកាល ឲ្យមានកម្រិតយល់ជ្រាបទិន្នន័យព្រះរាជសារថ្មីដែលអាចធ្វើឲ្យអ៊ុមម៉ាត្ធ៍នេះ មានសមត្ថភាពជាអាណាព្យាបាលព្រះប្រការសិតនិងជាអ្នកបន្តភារកិច្ចដោយគ្មានអ្នកដឹកនាំប្រតិបត្តិការកែប្រែ ។ ដើម្បីនឹងឲ្យអ៊ុមម៉ាត្ធ៍ឈានទៅដល់កម្រិតមួយដែលបញ្ជាក់ថា អាចទទួលអាណាព្យាបាលភាពនេះបាន អ៊ុមម៉ាត្ធ៍នេះត្រូវនៅក្រោមការត្រួតត្រាយូរជាងនេះ (គឺយូរជាងដប់ទសវត្សរ៍) ។ ការសមហេតុសមផលនៃសារផ្សាយលទ្ធិទាំងអស់ស្ថិតនៅត្រង់ចំណុចនេះឯង ។

តែអំណះអំណាងនេះមិនត្រឹមតែបកស្រាយវិចារណកិច្ចសាមញ្ញទេ ។ តែអំណះអំណាងនេះសម្តែងឲ្យឃើញការពិតដែរ ដែលព្រឹត្តិការណ៍កើតឡើងក្រោយពីព្រះសាស្តា-អគ្គមគ្គទេសក៍បានចូលទិវង្គតនោះ បញ្ជាក់អះអាងបន្ថែម គឺការពិតដែលលេចឡើងច្បាស់ក្រឡែត កន្លះសតវត្សក្រោយមក (ឬតិចជាងនេះ) តាមរយៈការអនុវត្តន៍នយោបាយ (ការគ្រប់គ្រង ឬត្រួតត្រាព្រះប្រកាសិត) ដោយមនុស្សជំនាន់មូហាយិរីននិងអាន់ស្វារ ។ ការពិត ស្ទើរម្ភៃឆ្នាំក្រោយពីមនុស្សជំនាន់នេះបានត្រួតត្រាព្រះប្រកាសិត "ខ៊ុលីហ្វាស្វ៍ដែលបានទទួលការដឹកនាំល្អ"[43]និងវិសោធនការសាសនាបានចាប់ផ្តើមរលំ ក្រោមការវាយប្រហារយ៉ាងដំណំរបស់

[43] ""ខ៊ុលីហ្វាស្វ៍ដែលបានទទួលការដឹកនាំល្អ" អាល់-ខ៊ុឡាហ្វាស្វ៍ អាល់-រ៉ស្ស៊ីដ្វាស្វ៍ គឺខ៊ុលីហ្វាស្វ៍របស់ស្តេចខ៊ុលិហ្វមុនបួនរូបដែលបានស្នងព្រះសាស្តា (មាន អាប៊ូបាការ, អ៊ុំម៉ារ, អ៊ុស្មម៉ាន, អ៊ុាលី) ។



កើតឡើងសិន ។"[30]

ថ្ងៃមួយ កាលអ៊ុំម៉ារសូត្រគួរអាន លោកបានឈប់ត្រង់ស៊ូរ៉ោះត៍នេះ៖ *យើងបានធ្វើឲ្យគ្រាប់ពូជដុះនៅក្នុងនោះ ចម្ការទំពាំងបាយជូរ ចំណីសត្វ ដើមស្រៃទូន គាលព្រឹក្ស ច្បារដែលមានរុក្ខជាតិញឹក ផលានុផលនិងស្មៅ*[31] ដោយនឹកក្នុងចិត្តថា៖ "យើងយល់ទាំងអស់នេះហើយ តែ "ស្មៅ" មានន័យថាអ្វី ?" ហើយបានអារកាត់ដោយខ្លួនឯងថា៖ "ព្រះអើយ នេះជាការនឿយហត់ឥតប្រយោជន៍ ។ បើអស់លោកមិនដឹងថា "ស្មៅ" មានន័យថាអ្វីទេនោះ មិនសំខាន់ទេ ។ ចូរស្វែងរកអ្វីដែលអល់ឡោះហ្វ៍បានពន្យល់អស់លោកនៅក្នុងព្រះគម្ពីរ ហើយចូរធ្វើតាមទៅ ។ ចំណែកឯអ្វីដែលអស់លោកមិនដឹងស្គាល់ទេនោះ ចូរទុករឿងនោះឲ្យអល់ឡោះហ្វ៍ ។"

ដូច្នេះឧទាហរណ៍ទាំងនេះសឲ្យឃើញថា បណ្តាសាវករមែងតែសួរសំណួរពាក់ព័ន្ធនឹងបញ្ហាចំៗតែប៉ុណ្ណោះ ។ និន្នាការនេះឯងជាមូលហេតុបណ្តាលឲ្យមានចំនួនហ្ហាឌីស្សតិច ដែលពួកសាវកទាំងនេះបានថ្លែងតមកពីព្រះសាស្តាពាក់ព័ន្ធនឹងច្បាប់ ហើយជាមូលហេតុធ្វើឲ្យពួកមុស្លីមបែរទៅរកប្រភពច្បាប់ផ្សេងពីគួរអាននិងស៊ូណាស្វ៍ ដូចជា "اِسْتِحْسَان" (អ៊ីសទៀហ្សាន គឺវិនិច្ឆ័យប្រុងប្រយ័ត្ន)[32] "قياس" (គ្ហីយ៉ាស់ ការប្រៀបធៀប)[33] មានច្រើនប្រភេទអ៊ីជ្ទីហ្វាដ្ធ៍ទៀត (اِجْتِهاد គឺការវិនិច្ឆ័យដោយខ្លួន

[30] ស៊ូណាន់ អាល់-ដ្ធារ៉ាមី (سنن الدارمي), ក្បាលទី ១ ទំព័រ ៥៦ ។

[31] ស៊ូរ៉ោះត៍ 80 អ៊ុាបាសា អាយ៉ាស្វ៍ 27-31 ។

[32] ការលម្អៀងដើម្បីធ្វើល្អ ។

[33] ការគិតដោយប្រើការប្រៀបធៀប ។

ឯង) នៅក្នុងប្រភេទអ៊ីច្ទីហ្វាដ៉ុទាំងនេះតួអង្គបុគ្គលមុច្តាហ៊្វិដ្ (គឺនីតិបណ្ឌិត គឺអ្នកប្រាជ្ញខាងច្បាប់) មានមុខងារដើរតួ នាំឲ្យលក្ខណៈបុគ្គលមនុស្ស ចំណូលចិត្តមនុស្សនិងមនោគតិពិសេសរបស់មនុស្សជ្រាបចូលបានទៅក្នុងច្បាប់[របស់អល់ឡោះហ្ទ៍عز وجل]

និន្នាការនេះផ្ទុយពីកិច្ចរៀបចំបេសកកម្មពិសេសផ្នែកសាសនា ដែលតម្រូវឲ្យមានចលនាអប់រំវិស័យវប្បធម៌ ហើយតម្រូវឲ្យចាប់អារម្មណ៍អំពីបញ្ហានានាដែលថ្នាក់ដឹកនាំនឹងជួបប្រទះនៅពេលឆាប់ៗ ហើយថ្នាក់ដឹកនាំត្រូវរកមធ្យោបាយដោះស្រាយបញ្ហាទាំងនោះឲ្យស្របតាមច្បាប់អ៊ីស្លាម ។

ដូចបណ្តាសាវកបានចៀសវាងសាកសួរព្រះសាស្តា ដោយខ្លួនឯងផ្ទាល់នោះដែរ ដូចគ្នាដែរបណ្តាសាវកមិនកត់ត្រាទុកនូវព្រះវចនៈរបស់ព្រះសាស្តានិងស៊ុណាស៊ុព្រះអង្គទេ ថ្វីបើស៊ុណាស៊ុនេះជាប្រភពទីពីរនៃច្បាប់អ៊ីស្លាម ហើយការកត់ត្រាទុកនូវស៊ុណាស៊ុនេះជាមធ្យោបាយតែមួយគត់ដើម្បីអភិរក្សនិងការពារវាកុំឲ្យបាត់បង់និងកុំឲ្យលំអៀងបាន ។

អាល់-ហ្វារ៉ាវី (الهروي) បានថ្លែងអំពីរឿងនេះនៅក្នុងតម្រារបស់លោក "ស៊្មំ អាល់-កាឡាំ" ថា យ៉ាស៊្យ៉ា អ៊ីបនូ សាអ៊ុដ់បានធ្វើសេចក្តីរាយការណ៍តមកពីអ៊ុប់ឌុលឡោះហ្វ៍ អ៊ីបនូ ឌីណារ៍ថា៖ "ទាំងបណ្តាសាវក ទាំងបណ្តាអ្នកតាម (التابعين អាល់-តាប៊ីអ៊ីន)[34] ពុំបានកត់ត្រាហ្ទាឌីស្ស៊ុរបស់ព្រះសាស្តាទេ ។ ពួកគេគ្រាន់តែទន្ទេញរត់មាត់ ហើយចងចាំទុកប៉ុណ្ណោះ ។"

[34] អ្នកតាម ភាសាអារ៉ាប់ តាប៊ីអ៊ីន ពហុវចនៈរបស់ តាប៊ីអ៊ុ ជាបណ្តាសាវករបស់បណ្តាសាវក ។



ទ្រទ្រង់ព្រះប្រការសិតបាន ពេលព្រះសាស្តានៅរស់និងពេលក្រោយពីព្រះសាស្តាចូលទិវង្គត ។

សម្មតិកម្មណាដែលមានគោលបំណងធ្វើឲ្យគេជឿថា ព្រះសាស្តាបានប្រព្រឹត្តិដើម្បីផ្ទេរការដឹកនាំ និងអាណាព្យាបាលភាពព្រះប្រការសិតឲ្យទៅបុគ្គលជំនាន់មូហ្វាយ៉ិរីននិងអាន់ស្វ៊ារដោយផ្ទាល់ ពេលអត់ពីព្រះអង្គនោះ សម្មតិកម្មនោះចោទដោយវាទរហិត[41]ព្រះអគ្គមគ្គទេសក៍សាសនាវាងវៃបំផុតក្នុងប្រវត្តិវិសោធនការបដិវត្ត (នៃការកែប្រែ) ថាគ្មានព្រះសមត្ថភាពញែកកម្រិតសម្បជញ្ញៈដែលគេត្រូវការ នៅក្នុងសំណាក់ប្រជារាស្ត្រព្រះប្រកាសិត ឲ្យដាច់ឡែកពីកម្រិតសម្បជញ្ញៈដែលគេត្រូវការនៅក្នុងសំណាក់ដឹកនាំព្រះប្រការសិត ឬដាច់ឡែកពីអ៊ីម៉ាម៉ាស៊ុ[42]ព្រះអង្គ (ជំនាន់មុន) ផ្នែកមនោគមវិជ្ជានិងផ្នែកនយោបាយ ។

III. ព្រះប្រកាសិតជាប្រតិបត្តិការកែប្រែនិងជារបៀបរស់នៅថ្មី ។ បានសេចក្តីថាស្ថាបនាអ៊ុមម៉ាត់ុឡើងវិញ និងដកឫសនិងសំណល់យ៉ាហ្ទ៊ីលីយ៉ាស៊ុចេញ (جاهِلِيّة គឺសង្គមមុនសាសនាអ៊ីស្លាម) ។

អ៊ុមម៉ាត់ុអ៊ីស្លាម (គឺអង្គភាពអ៊ីស្លាម) ជាទូទៅ បានស្គាល់ប្រតិបត្តិការកែប្រែនេះតែមួយទសវត្សរ៍ទេយ៉ាងច្រើន ។ ប៉ុន្តែ តាមធម្ម តាមការសមហេតុសមផលនៃសារផ្សាយលទ្ធិនិងតាមចលនាបដិវត្ត(កែប្រែ) រយៈពេលដ៏ខ្លី

[41] គឺមិនបាច់ថែងឲ្យច្បាស់ ។

[42] តាមន័យដើមរបស់ពាក្យ អ៊ីមុាំ មានន័យថាអ្នកដែលដើរមុខគេ អ្នកដែលនៅមុខគេ គឺអ្នកដែលដឹកនាំគេ ។

វិសោធនការមានគ្រប់ច្បាប់ទូទៅ ដែលព្រះអង្គបានចាត់ត្រៀមហើយ ។ ដូច្នេះ ដើម្បីដឹកនាំវិសោធនការនេះត្រូវយល់ជ្រួតជ្រាបជាចាំបាច់គ្រប់កម្រិតនិងគ្រប់ប្រការនៃព្រះរាជសារ និងត្រូវដឹងគោលគំនិតនៃព្រះរាជសារយ៉ាងជ្រាលជ្រៅ ។ ពុំនោះទេ គេអាចបកស្រាយស្វ័យស័ត្យ (គឺសម្ដីត្រឹមត្រូវ) និងឧបធារណ៍[39]តាមតែគំនិតខ្លួនឯង បណ្ដាលឲ្យវិសោធនការដែលកំពុងតែដំណើរការនោះទទួលបរាជ័យ ហើយនេះគឺហានិភ័យធំបំផុត ពីព្រោះអ៊ីស្លាមជាព្រះរាជសារចុងក្រោយ ឬ "ព្រះអវសានសារ" អាស្រ័យហេតុនេះព្រះរាជសារត្រូវតែលាតសន្ធឹងរហូតកាល ហួសព្រំដែន "កាលិក" (គឺកាលវេលា) ហួសព្រំដែន "ភូមិភាគ" និង ហួសព្រំដែន "ជាតិ" ។ ដូច្នេះហើយបានជាមិនត្រូវឲ្យការដឹកនាំព្រះរាជសារនេះ ដែលជាគ្រឹះនៃភាពទូលំទូលាយនេះស្ថិតនៅលើគោលការណ៍ "សាកល្បងនិងកំហុស" គោលការណ៍នេះមាននូវសមាច័យ[40]កំហុស (រហូតតាមកាលវេលា) លទ្ធផលចុងក្រោយគឺការកើតមាននូវវិបត្តិប្រេះឆា បណ្ដាលឲ្យវិសោធនការរលុះអស់ន័យ ។

គេអាចសម្រេចសេចក្ដីបានថា សរុប ចលនាអប់រំដែលព្រះសាស្ដាបានយកមកប្រើលើពួកមូហាយីរីននិងពួកអាន់ស្វារនោះ មិនសម្រាប់រៀបចំប្រុងប្រៀបផ្នែកអារម្មណ៍ ផ្នែកប្រាជ្ញានិងផ្នែកនយោបាយ ដើម្បីអនាគតព្រះប្រកាសិត និងបន្តកិច្ចកែប្រែដែលព្រះសានៈទូតបានចាប់ផ្ដើមនោះទេ តែសម្រាប់សាងមូលដ្ឋានប្រជារាស្ត្រផ្នែកសតិសម្បជញ្ញៈ ដែលអាចនឹង

[39] គឺគោលការណ៍ជាបឋមដែលត្រូវថាពិត ឬត្រូវទទួលយកជាមូលដ្ឋានសម្រាប់ផ្ដល់ហេតុផល ។
[40] គឺការកើនឡើង ការប្រមូលផ្ដុំ (ពោលគឺ មានច្រើនឡើងៗ) ។



យោលតាមតម្រា "ត៉ូបាកូត់" (طبقات) របស់លោកអ៊ីបនូ សាអុាដ់ ស្ដេចខ៉ូលិហ្វទីពីរ (គឺអ៊ូម៉ារ) បានប្រើពេលគិតមួយខែដើម្បីសម្រេចរឿងស៊ូណាស់ព្រះសាស្ដា ។ ទីបំផុតលោកបានហាមកត់ត្រាទុកស៊ូណាស់ព្រះសាស្ដា ។ បន្ទាប់មកស៊ូណាស់នេះ ដែលជាឯកសារយោងសំខាន់បំផុតនៃសាសនាអ៊ីស្លាម បន្ទាប់ពីព្រះគម្ពីរគួរអាន បាននៅក្នុងដណ្ដាប់ដៃនៃជោគវាសនាអស់រយៈពេល ២៥០ ឆ្នាំ រងហានិភ័យត្រូវបំភ្លេចចោល ជួនកាលត្រូវបន្លែបន្លំ ជួនកាលអ្នកចងចាំហ្វាឌីស្ស[35]នោះបានទទួលមរណភាព ។

ទោះជាដូច្នេះក៏ដោយ តើគេអាចស្មានបានដូម្ដេចទៅ ទោះជាមួយភ្លែតក៏ដោយ ថាបណ្ដាអ្នកនិយមនិន្នាការឆោតឆៅនេះ បើនេះការឆោតឆៅមែននោះ គឺបណ្ដាអ្នកដែលរើសអើងសួរអំពីបញ្ហាមុនបញ្ហានោះនឹងកើតឡើង ហើយមិនព្រមកត់ត្រាស៊ូណាស់ព្រះសាស្ដាទុក ពេលស៊ូណាស់ត្រូវបានចែងហើយនោះ មានសមត្ថភាពគ្រប់គ្រាន់ដើម្បីដឹកនាំព្រះរាជសារថ្មីក្នុងដំណាក់កាលសំខាន់បំផុតនិងពិបាកបំផុត ក្នុងការឈានទៅមុខដ៏យូរ ? អាក្រក់លើសនោះទៀត តើគេអាចស្មានបានដូចម្ដេចទៅថាព្រះសាស្ដាបណ្ដោយឲ្យស៊ូណាស់ព្រះអង្គរាត់រាយ ដោយគ្មានការកត់ត្រាទុក គ្មានការបញ្ជាក់យ៉ាងហ្មត់ចត់ ព្រមទាំងដាក់បញ្ជាឲ្យសាសនិកជនអនុវត្តិតាមយ៉ាងខ្ជាប់ខ្ជួននោះ ?

បើព្រះអង្គបានធ្វើផែនការរៀបចំពួកមុស្លីមទៅរកទស្សនៈ *ស៊ីរ៉* មែននោះ តើចាំបាច់មែនទេត្រូវតែបង្កើត *ស៊ីរ៉* ជារូបរាងឡើង ថ្លែងបញ្ជាក់ស៊ូណាស់

[35] អាល់-ហ្វាហ្វីឌូន គឺអ្នកចងចាំហ្វាឌីស្សព្រះសាស្ដាជាប់ក្នុងចិត្តដើម្បីផ្ទេរឲ្យទៅមនុស្សឯទៀត ។

ដែលនៅក្នុងការទាក់ទាញចិត្ត (គឺពួកអាល់-មូអាល់ឡាហ្វាស្ហ៊ូ គូលូប៊ូហ៊ុម) ដែលជាមនុស្សជំនាន់នេះមួយភាគធំនៅឡើយ - ទោះជាពួកនេះមានចំនួនច្រើនក្តី ឬជាជនវិសេសវិសាលក្នុងប្រវត្តិសាស្ត្រក្តី - ហើយដែលមានឥទ្ធិពលអាក្រក់ដល់ថ្នាក់គួរអានចែងអំពីរឿងនេះ ត្រង់កន្លែងគួរអានចែងអំពីពួកលាក់ពុតត្បុត អំពីផែនការណ៍ក្បត់និងចរិតរបស់ពួកនេះ ។ ពិតមែន មនុស្សជំនាន់នេះមានបុគ្គលត្រឹមត្រូវណាស់ពីរបីនាក់ដូចជាសាល់ម៉ាន, អាប៊ូ ស្ហារ៉ (أبو ذر), អ៊ុំម៉ារ៉ ។ល ។ វិសោធនការអ៊ីស្លាមដែលបានច្របាច់បុគ្គលទាំងនេះឲ្យជ្រាបចូលជាសាច់មួយ ជាមួយការបង្វឹកនោះ (គឺបានចេះដឹងថ្មីក) បានអប់រំបុគ្គលទាំងនេះឲ្យចេះដឹងបេសកកម្មសាសនាដល់កម្រិតខ្ពស់បំផុត ។ តែវត្តមានបុគ្គលត្រឹមត្រូវអនេកពីរបីរូបនេះ នៅក្នុងចំណោមមនុស្សជំនាន់នេះនោះមិនបញ្ជាក់ថាមនុស្សជំនាន់នេះបានឈានដល់កម្រិតចំណេះ ដែលសមនឹងបានទទួលបេសកកម្មដឹកនាំព្រះប្រកាសិតអាស្រ័យមូលដ្ឋាន *ស៊្ហូរ៉* នោះទេ ។

ទោះបីមានមនុស្សជំនាន់នេះ ដែលបានទៅដល់ការអប់រំផ្នែកមនោគមវិជ្ជាកម្រិតខ្ពស់ក៏ដោយ ពួកគេភាគច្រើនមិនមានគុណសម្បត្តិដែលគេត្រូវការដែលអាចស្មានបានថា ពួកគេមានសមត្ថភាពបំពេញបេសកកម្មដឹកនាំវិសោធនការនោះទេផ្នែកប្រាជ្ញានិងផ្នែកវប្បធម៌ ទោះបីពួកគេមានភក្តីភាពជំពាក់ចិត្តខ្លាំងនិងស្មោះត្រង់ចំពោះអ៊ីស្លាមក៏ដោយ ។ ពីព្រោះអ៊ីស្លាមមិនមែនទ្រឹស្តីមនុស្ស ដែលអាចទៅជាច្បាស់លាស់បានអាស្រ័យលើប្រាជ្ញាតាមរយៈការហ្វឹកហាត់និងការអនុវត្តន៍ ហើយទស្សនៈអ៊ីស្លាមអាចទៅជាច្បាស់លាស់បានតាមរយៈការពិសោធន៍នោះទេ ។ ជាចំបង អ៊ីស្លាមជាព្រះរាជសាររបស់ព្រះ នៅក្នុងព្រះរាជសារនេះបទបញ្ញត្តិនិងការយល់ដឹងត្រូវបានកំណត់រួចស្រេចជាមុនហើយ ហើយអល់ឡោះហ្វ៍បានតម្រូវឲ្យ



ព្រះអង្គដើម្បីនឹងឲ្យ *ស៊្ហូរ៉* ដើរទៅតាមទិសដៅទៀងទាត់និងជាក់លាក់ ចាកផុតពីកបិចិត្ត (គឺ ចិត្តសាវ៉ា វើរុះ ចិត្តមិនប្រាកដត្រង់ណា ម្តងដូច្នេះ ម្តងដូច្នោះ) ?

សេចក្តីពន្យល់បំភ្លឺមួយគត់ ដែលសមហេតុផលអំពីឥរិយាបថព្រះសាស្តានោះ មិនមែនសេចក្តីពន្យល់បំភ្លឺមួយនេះទេឬ នោះគឺព្រះអង្គបានរៀបចំអ៊ីម៉ាំអ៊ុាលីជាអាជ្ញាធរជាន់ខ្ពស់ ជាអ្នកដឹកនាំវិសោធនការអ៊ីស្លាមក្រោយពីព្រះអង្គ ដោយអប់រំអ៊ីម៉ាំអ៊ុាលីឲ្យចេះដឹង "អភិញ្ញារាប់ពាន់ជំពូក" ដោយផ្ទេរស៊្ហូណាស្ហ៊ូព្រះអង្គទាំងមូលឲ្យទៅអ៊ីម៉ាំអ៊ុាលី ? ពីព្រោះចំណុចពិសេសដាច់គេឬពិសេសដាច់ពហុនិន្នាការ បានសេចក្តីថាពិសេសដាច់បណ្តាអ្នកដែលបានចោលការកត់ត្រាទុកនូវហ៊ាឌីស្ហព្រះសាស្តានោះ គឺចំណុចដែលស្ថិតនៅលើខ្លួនព្រះរាជកុលដ្ឋានអាស្ហ៊ុលុល-បៃត៍ ។ មែន យោលតាមសេចក្តីរាយការណ៍ទទួលបានមកពីអ៊ីម៉ាំអាស្ហ៊ុលុល-បៃត៍ បុគ្គលទាំងនេះខិតខំ តាំងដើមមកម្ល៉េះ កត់ត្រាទុកនូវហ៊ាឌីស្ហទាំងអស់របស់ព្រះសាស្តា ។ យោលតាមសេចក្តីរាយការណ៍នេះ បុគ្គលទាំងនេះបានថែរក្សាទុកនូវក្រាំងធំមួយ ដែលមានចំណារស៊្ហូណាស្ហ៊ូទាំងអស់របស់ព្រះសាស្តា (គឺទង្វើវិស័យច្បាប់សាសនា) សរសេរតាមព្រះសាស្តាប្រាប់ ឲ្យសរសេរដោយដៃអ៊ីម៉ាំ អ៊ុាលី អ៊ីបនូ អាប៊ី ត៊ូលិបផ្ទាល់តែម្តង ។

ព្រឹត្តិការណ៍ដែលបានកើតឡើង ក្រោយពីព្រះសាស្តាបានចូលទិវង្គតសឲ្យឃើញថាជំនាន់ពួកមូហ្វាឃ្ជីរីននិងពួកអាន់ស្ហារ មិនមាននូវបញ្ញត្តិច្បាស់លាស់ទេពាក់ព័ន្ធនឹងបញ្ហាច្រើន ដែលព្រះប្រកាសិតនឹងត្រូវជួបប្រទះដោយឥតចៀសបានក្រោយពីព្រះមគ្គទេសក៏ចូលទិវង្គត ដល់ថ្នាក់ស្តេចខ៊ុលិហ្វដែលត្រូវគេតែងតាំង និងទីប្រឹក្សាមិនដឹងលើកយកច្បាប់

ផ្ទុយទៅវិញ ភាគនេះនៃអ៊ុមម៉ាត់មានទំនាក់ទំនងយ៉ាងជិតស្និទ្ធបំផុតជាមួយភាគឯទៀតនៃអ៊ុមម៉ាត់ ។
ភាគនេះនៃអ៊ុមម៉ាត់មានឥទ្ធិពលលើភាគឯទៀត ហើយទទួលរងឥទ្ធិពលពីសំណាក់ភាគឯទៀតនៃអ៊ុមម៉ាត់ ។

បានឃើញប្រការទាំងប្រាំមួយនេះហើយ យើងអាចកត់សម្គាល់បានថាការអប់រំរបស់ព្រះសាស្ដាប្រកបដោយជោគជ័យធំអនេក ការអប់រំនេះបានអនុវត្តិន្ទូវការកែប្រែឥតប្រៀបបាន បានបង្ហាត់ហ្វឹកហ្វឺនមនុស្សមួយជំនាន់ដែលឆ្លើយតបតាមគោលដៅព្រះសាស្ដា ដើម្បីបង្កបង្កើតមូលដ្ឋានប្រជារាស្ត្រដែលត្រៀមខ្លួននៅអបអម និងជួយគាំទ្រការដឹកនាំវិសោធនការថ្មី ។ ដូច្នេះហើយបានជាគេឃើញថាមនុស្សជំនាន់នេះបានបំពេញមុខងារខ្លួនបានយ៉ាងល្អ គឺមុខងារជាមូលដ្ឋានប្រជារាស្ត្រឥតខ្ចោះ ដរាបណាព្រះសាស្ដាជាអ្នកដឹកនាំព្រះរាជសារ ។ បើថ្នាក់ដឹកនាំនេះកាន់យកយ៉ាងខ្ជាប់ខ្ជួននូវមាគ៌ាដែលអស់ឡោះហ៍បានគូសស្រាប់ហើយនោះ ក្រោយពីព្រះសាស្ដាបានចូលទិវង្គត មូលដ្ឋានប្រាកដជានៅតែបំពេញមុខងារខ្លួនបានយ៉ាងសុក្រឹតឥតខ្ចោះ ។ តែមិនបានសេចក្ដីថាមូលដ្ឋាននេះបានប្រុងខ្លួនជាស្រេចដើម្បីធានាការដឹកនាំវិសោធនការថ្មីដោយខ្លួនឯងទេ ។ ពីព្រោះការប្រុងប្រៀបខ្លួនបែបនេះ តម្រូវឲ្យមនុស្សជំនាន់នេះមានអារម្មណ៍រលាយជ្រួតជ្រាបជាសាច់មួយជាមួយព្រះរាជសារ (គឺយល់ព្រះរាជសារច្បាស់លាស់) តម្រូវឲ្យមានការជឿជាក់យ៉ាងខ្លាំងទៅលើព្រះរាជសារនេះ តម្រូវឲ្យមានការចេះដឹងយ៉ាងច្រើនអំពីបញ្ញត្តិរបស់ព្រះរាជសារនេះ អំពីទស្សនាទាននិងគោលទស្សនៈនានារបស់ព្រះរាជសារនេះផ្នែកជីវិត តម្រូវឲ្យមានការជម្រះបោសសំអាតនៅក្នុងជួរមុស្លីម ដើម្បីកម្ចាត់ពួកមានពុតត្បុត ពួកឈ្លានពានចូលមកខាងក្នុងនិងជនកំចោកធ្វើវិទ្ធង្សនាការ ពួក



ណាមួយមកប្រើឲ្យត្រូវទេ នៅក្នុងទឹកដីយ៉ាងធំដែលអ៊ីស្លាមវាយយកបាននោះ មិនដឹងថាតើត្រូវបែងចែកទឹកដីទាំងនេះឲ្យទៅយុទ្ធជន ឬដាក់ជាទានឲ្យទៅមុស្លីមដែលមានសទ្ធាជ្រះថ្លាទេ ។ តើគេអាចស្មានបានទេថាកាលនោះ ព្រះសាស្ដាបានប្រាប់ពួកមុស្លីមថានឹងវាយយកទឹកដីរបស់គូរូស្ទ (كورش cyrus) និងកយ់ស្វារ (قيصر Caesar) ថាព្រះអង្គនឹងផ្ទេរអាណាព្យាបាលភាពព្រះប្រការសិត និងការដឹកនាំចម្បាំងនោះឲ្យមនុស្សជំនាន់ពួកមូហាឃ្ជីរីនិងពួកអាន់ស្វារ ដោយពុំបានប្រាប់ពួកគេឲ្យដឹងនូវច្បាប់សម្រាប់យកមកប្រើ នៅក្នុងទឹកដីដ៏ធំនៃពិភពលោកដែលអ៊ីស្លាមនឹងវាតទៅលើនោះ ?

--

អន់លើសពីនោះទៅទៀតគឺ យើងអាចឃើញបានថាមនុស្សជំនាន់ព្រះសាស្ដាមិនដឹងច្បាស់និងជាក់លាក់ទេ ទោះជាអំពីរឿងសាសនាក៏ដោយ ជាក់ស្ដែងគឺរឿងស្វ៍ឡាត់ឲ្យមនុស្សស្លាប់ ។ ទោះជាស្វ៍ឡាត់នេះជាទង្វើផ្នែកសាសនាដែលព្រះសាស្ដាបានធ្វើរាប់រយដងជាសាធារណៈ នៅចំពោះមុខហ្វូងមនុស្សដែលបានចូលរួមក្នុងពិធីបុណ្យសព និងក្នុងស្វ៍ឡាត់ក៏ដោយ ក៏បណ្ដាសាវកភាគច្រើនហាក់ដូចជាមិនយល់ឃើញថាជាការចាំបាច់ត្រូវចេះដឹងរបៀបស្វ៍ឡាត់ឲ្យសពយ៉ាងត្រឹមត្រូវទេ ដរាបណាមានព្រះសាស្ដាធ្វើពិធីស្វ៍ឡាត់នេះ ដោយព្រះអង្គផ្ទាល់ហើយនោះ ហើយដរាបណាបណ្ដាសាវកទាំងនោះ អាចធ្វើតាមកាយវិការព្រះអង្គបានមួយជំហានម្ដងៗ យ៉ាងព្រងើយកន្តើយ ។ ភ័ស្ដុតាងបញ្ជាក់ចំណុចនេះគឺមិនយូរប៉ុន្មាន បណ្ដាសាវកទាំងនោះមិនមូលមតិគ្នារឿងចំនួនរ៉ក់អ៊ាត់

តាក់បៀរ[36] នៅក្នុងស្វ៊ឡាត់នេះ ។

យោលតាមលោក អាល់-ត៏ហ្ហាវី (الطحاوي) ដែលបានថ្លែងតមកពី អ៊ីបរ៉ហ៊ីម ថា៖ "ព្រះសាស្តាបានចូលទិវង្គត ។ ពួកមុស្លីមមិនយល់ស្របគ្នារឿងចំនួនរ៉ក់អាត់តាក់បៀរដែលត្រូវសូត្រឲ្យសព ។ ម្នាក់ថា៖ "ខ្ញុំបានឮព្រះសាសនៈទូតអល់ឡោះហ្ម៍ធ្វើប្រាំពីរតាក់បៀរ ។" ម្នាក់ទៀតបានថា៖ "ខ្ញុំបានឮព្រះសាសនៈទូតអល់ឡោះហ្ម៍ធ្វើប្រាំតាក់បៀរ ។" ពួកគេនៅតែមិនត្រូវរូវគ្នាលុះអាប៊ូ បាការស្លាប់ ។ លុះអ៊ុម៉ារឡើងកាន់ខ៊ុលីហ្វាស៊ុ បានដឹងរឿងមិនមូលមតិគ្នានេះ លោកបារម្ភ ។ លោកបានប្រជុំសាវកព្រះសាសនៈទូតអល់ឡោះហ្ម៍ពីរបីនាក់ ហើយបានប្រាប់ពួកសាវកនោះថា៖ "អស់លោកបណ្ដាសាវកព្រះសាសនៈទូតអល់ឡោះហ្ម៍ ពេលអស់លោកខ្វែងមតិគ្នាមនុស្សម្នាតាមអស់លោកនៅក្នុងការខ្វែងមតិនោះ ។ ពេលអស់លោកត្រូវរូវគ្នារឿងអ្វីមួយ មនុស្សម្នាក៏ត្រូវរូវគ្នាដែរ ។ ដូច្នេះចូរអស់លោកពិនិត្យមើលថាតើអស់លោកត្រូវរូវគ្នាត្រង់ណាខ្លះ ។" ហាក់ដូចជាលោកបានដាស់ពួកគេពីដំណេក ។ ពួកគេបានថា៖ "លោកនិយាយត្រូវ ។"[37]

រឿងនេះបញ្ជាក់ឲ្យដឹងថាបណ្ដាសាវកពឹងផ្អែកលើរូបព្រះសាស្តា កាលព្រះអង្គនៅមានព្រះជន្ម ហើយពួកគេមិនគិតថាចាំបាច់ត្រូវសិក្សាឲ្យចេះដឹងយ៉ាងថ្នឹករឿងលក្ខខណ្ឌនិងបែបបទរបស់ច្បាប់សាសនាទេ ដរាបណាព្រះអង្គជាអ្នកទទួលភារៈរឿងនេះ ។

[36] គឺការបួងសួងអល់ឡោះហ្ម៍ដោយថា៖ "អល់ឡ៉ហ្ហ៍ អាក់បារ៍" (الله أَكْبَر អល់ឡោះហ្ម៍ទ្រង់មហាធំថ្កើង) ។

[37] អ៊ុមដាស៊ុ អាល់-ក៏វី (عُمْدَة القَارِي) IV/129



អាចលើកស្ទួយអ៊ុមម៉ាត់បានដល់កម្រិតមួយ ដែលអ៊ុមម៉ាត់នេះអាចដឹកនាំព្រះរាជសារបានដោយខ្លួនឯងភ្លាមៗទេ ។ យើងអធិប្បាយចំណុចនេះក្នុងប្រការខាងមុខដើម្បីបង្ហាញឲ្យឃើញថា ផ្ទេរភារកិច្ចដឹកនាំវិសោធនការនៃការកែប្រែឲ្យទៅព្រះរាជានុសិទ្ធិនៃអ៊ីម៉ាំអាស្ហ៍លុល-បៃត៍ និងខ៊ុលីហ្វាស៊ុ អ៊ីម៉ាំអាលីនោះជាការចាំបាច់ ដែលការសមហេតុផលក្នុងចលនាបដិវត្តទាមទារឲ្យធ្វើរហូតពេញមួយប្រវត្តិសាស្ត្រ ។

៦) ភាគច្រើននៃអង្គភាពអ៊ីស្លាម ពេលអត់ពីព្រះសាស្តាទៅ រួមជាមុស្លីមដែលគេហៅថាមុស្លីមចាញ់ចម្បាំង ពោលគឺ ពួកដែលកាន់សាសនាអ៊ីស្លាមក្រោយពីវាយយកម៉ាក់កាស៊ុបាន និងពេលព្រះរាជសារថ្មីទៅជាម្ចាស់ស្ថានការផ្ទេកនយោបាយនិងយោធានៅក្នុងឧបទ្វីបអារ៉ាប់ ។ ព្រះសាស្តាមានទំនាក់ទំនងតិចណាស់ជាមួយមុស្លីមទាំងនេះ ក្នុងអំឡុងពេលចន្លោះពេលវាយយកម៉ាក់កាស៊ុបាននិងពេលអត់ព្រះអង្គ ។ ដូចគ្នាដែរទំនាក់ទំនងតិចនេះដែលព្រះអង្គមានជាមួយពួកមុស្លីមខាងលើនេះ គឺទំនាក់ទំនងក្នុងឋានៈជាអភិបាលដែនដី ព្រោះកាលនោះរដ្ឋអ៊ីស្លាមកំពុងតែឆ្លងកាត់ដំណាក់កាលពិសេស ។ នៅក្នុងដំណាក់កាលនេះឯងដែលគំនិត "អាល់-មូអាល់ឡាហ្វាស៊ុ គ្លូលូប៊ូហ៊ុម"[38]បានលេចឡើងហើយបាននៅក្នុងច្បាប់ស្ហាកាត់និងនៅក្នុងច្រើនផ្នែកទៀត ។
ក៏ប៉ុន្តែភាគនេះនៃអ៊ុមម៉ាត់មិន ដាច់ឡែកពីភាគឯទៀតនៃអ៊ុមម៉ាត់ទេ ។

[38] អ្នកដែលនៅក្នុងការទាក់ទាញចិត្ត អាល់-មូអាល់ឡាហ្វាស៊ុ គ្លូលូប៊ូហ៊ុម ។ មានន័យត្រង់ថា អ្នកដែលគេកំពុងទាក់ទាញចិត្ត កំពុងតែធ្វើឲ្យចិត្តស្រឡាញ់ កំពុងធ្វើចិត្តទន់ ។ ជនទាំងនេះគឺជនដែលធ្វើបាបពួកមុស្លីមកាលអ៊ីស្លាមទើបនឹងកើតឡើង ។ ដើម្បីកុំឲ្យជនទាំងនេះឈ្លានពាន ពួកមុស្លីមសាកល្បងធ្វើឲ្យពួកគេទន់ចិត្តដោយឲ្យប្រាក់ឲ្យពួកគេ ។

ទៅក្នុងច្រើនវិស័យទស្សនៈ ។ គ្រាន់តែពិនិត្យមើលគួរអានរុងរឿង ទើបឃើញទំហំនៃអត្ថន័យទស្សនៈប្រតិកិរិយា (គឺប្រឆាំង ការកែប្រែសាសនា) ហើយឃើញថាព្រះគម្ពីរបានប្រយ័តប្រយែង ដោយថែងបំភ្លឺអំពីទស្សនៈប្រតិកិរិយានេះនិងឆ្លើយបដិសេធ ។

៥) គោលដៅដែលព្រះបរមគ្រូ (គឺព្រះសាស្តា) សំដៅទៅរក និយាយសរុបហើយនៅក្នុងអំឡុងពេលនោះ គឺបង្កបង្កើតមូលដ្ឋានប្រជារាស្ត្រដែលត្រឹមត្រូវដើម្បីនឹងអាចរួមចិត្តគំនិតជាមួយការដឹកនាំព្រះរាជសារបាន [ក្នុងពេលព្រះអង្គមានព្រះជន្មនិងក្នុងពេលអត់ពីព្រះអង្គ] ហើយអាចបន្តវិសោធនការអ៊ីស្លាមតទៅមុខទៀតបាន ។ គោលដៅ (ការឆ្លង) របស់ព្រះសាស្តាសម័យនោះ ពុំមែននាំអ៊ុមម៉ាត់ទៅកាន់កម្រិតមួយដែលអ៊ុមម៉ាត់នេះអាចទទួលភារកិច្ចដឹកនាំព្រះប្រកាសិតបាន ដោយខ្លួនឯងនោះទេ ពោលគឺ ទៅកាន់កម្រិតមួយដែលអ៊ុមម៉ាត់នេះយល់ជាក់ព្រះរាជសារដោយការចេះដឹងវិជ្ជាធម្មសាស្ត្រនៃលក្ខន្តិក [របស់ព្រះរាជសារ]យ៉ាងជ្រាលជ្រៅនិងទាំងស្រុង និងដោយការលាយចូលគ្នាជាសាច់មួយជាមួយទស្សនាទាននៃព្រះរាជសារនោះយ៉ាងបរិបូរ (គឺយល់ជ្រួតជ្រាបឥតទាស់មួយអន្លើឡើយ) ។ ការកំណត់គោលដៅសម្រាប់អំឡុងពេលនោះតាមវិធីដែលយើងបានថ្លែងខាងលើនេះជាការសមហេតុផលមែន ហើយទាមទារឲ្យធ្វើចលនាផ្លាស់ប្តូរមួយប្រភេទ ។ ពីព្រោះគេអាចកំណត់គោលដៅបានអាស្រ័យតែមធ្យោបាយប្រតិបត្តិដែលគេមាន ដែលអាចធ្វើបានទេ មិនមានមធ្យោបាយប្រតិបត្តិក្នុងករណីមួយដូចករណីដែលអ៊ីស្លាមបានជួបប្រទះហើយនោះ ក្រៅពីក្របខណ្ឌដែលយើងបានថ្លែងហើយនោះទេ ព្រោះចន្លោះសីលធម៌ អារម្មណ៍ ប្រាជ្ញានិងសង្គមរវាងព្រះរាជសារថ្មីនិងការពិតត្រូវកាឡៃដែលរាលដាលលុបលើ នាសម័យនោះ មិន



គេអាចជំទាស់ការពណ៌នាអំពីបណ្តាសាវកបែបនេះ - ជាមួយព្រឹត្តិការណ៍នានាដែលឆ្លុះបញ្ចាំងនូវការខ្វះខាតសមត្ថភាពដឹកនាំព្រះប្រកាសិត - ថាវាផ្ទុយពីអ្វីៗដែលយើងទាំងអស់គ្នាដឹងស្រាប់ហើយនោះ ពោលគឺ ការអប់រំដែលព្រះសាស្តាបានធ្វើចំពោះបណ្តាសាវកនោះ បានទទួលជ័យជំនះយ៉ាងធំ ហើយអាចធ្វើឲ្យកកើតឡើងបាននូវអ្នកបំពេញបេសកកម្មសាសនាអស្ចារ្យមួយជំនាន់ !

យើងសូមឆ្លើយតបការយល់ជំទាស់នេះថា ពិពណ៌នាពិតដែលយើងបានធ្វើឡើងអំពីមនុស្សជំនាន់មុននោះ មិនប្រឆាំងសេចក្តីកោតសរសើរដ៏ខ្ពង់ខ្ពស់របស់យើងចំពោះចលនាអប់រំ ដែលព្រះសាសនៈទូតបានប្រតិបត្តិអស់មួយជីវិតដ៏រុងរឿងរបស់ព្រះអង្គនោះទេ ។ ពីព្រោះព្រមនឹងការជឿជាក់ថាចលនាអប់រំរបស់ព្រះសាស្តា ជាគំរូនៃការអប់រំរបស់ព្រះដ៏ឧត្តុង្គឧត្តម និងជាតួយ៉ាងនៃវ៉ាហ៊ីបញ្ជាក់សាស្តាភាពពេញមួយប្រវត្តិសកម្មភាពរបស់ព្រះសាស្តានោះ យើងយល់ឃើញថាដើម្បីឈានទៅដល់ជំនឿនេះ ហើយធ្វើការវាយតម្លៃឲ្យបានត្រឹមត្រូវអំពីលទ្ធផលនៃការអប់រំនេះ ចាំបាច់ត្រូវចៀសវាងបែងចែកលទ្ធផលនេះចេញពីព្រឹត្តិការណ៍ និងឧប្បត្តិហេតុនានាដែលកើតឡើងក្នុងចលនាអប់រំ ហើយត្រូវមើលបរិមាណដាច់ឡែកពីគុណភាព ។ ដើមពន្យល់ យើងសូមលើកយកឧទាហរណ៍មួយមកអធិប្បាយដូចតទៅ ។ ពេលយើងចង់វែកញែកឲ្យឃើញសមត្ថភាពពិតប្រាកដរបស់គ្រូបង្រៀនភាសានិងអក្សរសាស្ត្រអង់គ្លេស យើងមិនគ្រាន់តែពិនិត្យកម្រិតចំណេះ ដែលសិស្សរបស់គ្រូនោះបានទទួលជោគជ័យក្នុងការសិក្សាមុខវិជ្ជានោះប៉ុណ្ណោះទេ តែយើងត្រូវដឹងអំពីចំនួនមុខវិជ្ជាដែលគ្រូនោះបានបង្រៀនសិស្សនោះ ត្រូវដឹងអំពីកម្រិតចំណេះរបស់សិស្ស

នោះក្នុងមុខវិជ្ជានោះ មុនសិស្សនោះបានចាប់ផ្ដើមសិក្សាមុខវិជ្ជាទាំងនោះ ត្រូវដឹងថាតើសិស្សទាំងនោះជិតស្និទ្ធ ឬមិនជិតស្និទ្ធនឹងបរិយាកាសភាសា និងអក្សរសាស្ត្រអង់គ្លេសឬទេ ត្រូវដឹងអំពីការលំបាកសរុបនិងឧបសគ្គពិសេសដែលកិច្ចអប់រំសិក្សាបានជួបប្រទះ ត្រូវដឹងអំពីគោលដៅដែលគ្រូបានកំណត់ជាស្រេចពេលបង្ហាត់បង្រៀនសិស្សភាសានោះ និងអក្សរសាស្ត្រនោះ ត្រូវដឹងអំពីមេគុណច្បាស់លាស់នៃលទ្ធផលចុងក្រោយនៃកិច្ចអប់រំសិក្សាដែលកំពុងត្រូវពិនិត្យនោះ ប្រៀបធៀបនឹងកិច្ចអប់រំសិក្សាឯទៀត ។

សូមបែរមករកប្រធានបទវាយតម្លៃកិច្ចអប់រំសិក្សា ចាត់ចែងដោយព្រះសាស្ដានោះវិញ ។ ក្នុងវិស័យនេះ យើងត្រូវយកចិត្តទុកដាក់អំពីប្រការដូចតទៅគឺ៖

១) រយៈពេលខ្លីដែលព្រះសាស្ដាអាចប្រតិបត្តិកិច្ចអប់រំសិក្សា ។ រយៈពេលនេះមិនលើសពីពីរទសវត្សរ៍ (គឺ ២០ ឆ្នាំ) ទេ សម្រាប់បណ្ដាសាវកកម្រដែលបាននៅអមព្រះអង្គតាំងពីដើមនោះ ។ មួយទសវត្សរ៍ សម្រាប់បណ្ដាអាន់ស្វ៉ារភាគច្រើន ។ បីឬបួនឆ្នាំ សម្រាប់មុស្លីមដ៏ច្រើនដែលបានផ្លាស់សាសនាមកកាន់តាមព្រះរាជសារអ៊ីស្លាម ចាប់តាំងពីពេលសម្រុះសម្រួលនៅឯហ៊្វូដៃប៊ីយ៉ាស្វ៉ (الحديبية) មកដល់ពេលវាយដណ្ដើមយកម៉ាក់កាស្វ៉ ។

២) ស្ថានភាពដើមដែលបណ្ដាសាវកទាំងនេះបានរស់នៅ ផ្នែកប្រាជ្ញា ផ្នែកចិត្ត ផ្នែកសាសនានិងចរិយា មុនព្រះសាស្ដាបានចាប់ផ្ដើមបំពេញបេសកកម្មសាស្ដា (គឺមុនព្រះសាស្ដាបានទទួលវ៉ាហ៊ីជារ៉ស៊ូល) ភាពឆោតឆៅ សយម្ភូតភាព (គឺការពេញចិត្តធ្វើពីខ្លួនឯង) និងកង្វះខាតដែលផ្អុលលក្ខណៈនៃផ្នែកនានាក្នុងជីវិតពួកគេ ។ មិនបាច់អធិប្បាយបន្ថែមលើ



ប្រការចុងក្រោយនេះទេ ពីព្រោះ ពិតប្រាកដណាស់ បើគេដឹងច្បាស់ថាអ៊ីស្លាមមិនមែនស្ថិតនៅលើការផ្លាស់ប្ដូរសើៗក្នុងសង្គមនោះទេ តែស្ថិតនៅលើការកែប្រែឫសគល់ (គឺទាំងស្រុង) និងការស្ថាបនាខុសប្លែកពីធម្មតានៃអ៊ុមម៉ាត្ហ៍ថ្មី បានសេចក្ដីថាចន្លោះសីលធម៌រវាងស្ថានភាពមុនសកម្មភាពព្រះសាស្ដា និងស្ថានភាពថ្មីពេលព្រះអង្គបានចាប់ផ្ដើមធ្វើនោះធំណាស់ ។

៣) អំឡុងពេលដែលព្រះសាស្ដាបានផ្សាយព្រះរាជសារនោះ សម្បូរព្រឹត្តិការណ៍ សម្បូរការតស៊ូផ្នែកនយោបាយនិងយោធានៅតាមរណសិរ្សផ្សេងៗ ដូចច្នេះហើយបានលក្ខណៈទំនាក់ទំនងរវាងព្រះសាសនៈទូតនិងបណ្ដាសាវកព្រះអង្គនោះខុសពីលក្ខណៈទំនាក់ទំនងរវាងណាប៊ីអ៊ីសា និងបណ្ដាសាវកព្រះអង្គ ។ ទំនាក់ទំនងទីមួយមានលក្ខណៈពិសេសនៅត្រង់ចំណុចព្រះសាស្ដាជាព្រះគ្រូ (គឺអ្នកបង្ហាត់ អ្នកបង្រៀន អ្នកអប់រំ) ជាមេបញ្ជាការទ័ពនិងជាប្រមុខរដ្ឋ ទំនាក់ទំនងទីពីរមានលក្ខណៈពិសេសត្រង់ចំណុចមុខងាររបស់ណាប៊ីអ៊ីសាដែលជាគ្រូបង្រៀន និងជាអ្នកអប់រំប្រុងប្រៀបនិងលះបង់ខ្លួនចាំបង្ហាត់បង្រៀនសិស្សរបស់ខ្លួន ។

៤) ដំណើរវប្លាតកើតដល់ពួកមុស្លីម ការប្រឈមមុខនឹង "ជនគម្ពីរ" និងបណ្ដាអ្នកកាន់សាសនាផ្សេងទៀត ដែលពួកមុស្លីមប្រទះដែលនៅជិតខាងពួកគេ ។ មែន ទំនាក់ទំនងជាអចិន្ត្រៃយ៍រវាងអ៊ីស្លាមនិងទស្សនៈដែលបណ្ដាគូប្រឆាំងរបស់ព្រះរាជសារថ្មីបានផ្សព្វផ្សាយពាសពេញនោះ គឺពួកអ្នកនិយមសាសនាដើម ជាប្រភពនៃសេចក្ដីបារម្ភនិងការរំជើបរំជួលជានិច្ចមួយ ហើយបានបណ្ដាល ដូចគេបានដឹងស្រាប់ហើយ ឲ្យមាននូវចលនាទស្សនៈអ៊ីសរ៉ាអ៊ីលជ្រាបចូល ដោយអចេតនាឬដោយការព្យាបាទ